# ព្រឹត្តិបត្រមេធាវី

លេខ ១៩

ខែ តុលា-ធ្នូ ឆ្នាំ ២០១៨

រក្សាសិទ្ធិ © 2018 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយក៏មិនឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

ទំព័រ

# មាតិកា


**សារពីប្រធានគណៈមេធាវី** ........ III


## រដ្ឋប្បវេណី


**បណ្តឹងតវ៉ារបស់តតិយជន** ........ 1

១. សេចក្តីផ្តើម ........ 1

២. តើនរណាជាភាគីនៃបណ្តឹងតវ៉ារបស់តតិយជន? ........ 2

៣. តើបណ្តឹងតវ៉ារបស់តតិយជនអាចត្រូវបានដាក់ និងទទួល នៅពេលណា? ........ 3

៤. តើបណ្តឹងតវ៉ារបស់តតិយជនត្រូវសរសេរដូចម្តេច? ........ 11

៥. សេចក្តីសន្និដ្ឋាន ........ 19


## ព្រហ្មទណ្ឌ


**គោលការណ៍សន្មត់ថាមិនមានទោស** ........ 23

**ការបដិសេធភស្តុតាង៖ ករណីការថតសម្លេងតាមទូរស័ព្ទ** ........ 33

**មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ** ........ 39

១–សេចក្តីផ្តើម ........ 39

២ –ខ្លឹមសារ ........ 40

២.១ –អំពីអង្គការអយ្យការ ........ 40

២.២– តំណាងអយ្យការ និង តំណាងមហាអយ្យការ ........ 41

៣ –សេចក្តីសន្និដ្ឋាន ........ 49

## ផ្នែកពាណិជ្ជកម្ម

**ការតែងតាំងមជ្ឈត្តករផ្នែកពាណិជ្ជកម្ម** ........ 53

១. សេចក្តីផ្តើម ........ 53

២. ដំណើរការតែងតាំងមជ្ឈត្តករ ........ 54

៣. សេចក្តីសន្និដ្ឋាន ........ 60

**សេចក្តីជូនដំណឹងអំពីការកែតម្រូវអត្ថបទដែលបានចុះផ្សាយ** ........ 63

## សកម្មភាពរបស់គណៈមេធាវី

១. កិច្ចប្រជុំផ្ទៃក្នុង ........ 67

២. កិច្ចប្រជុំគណៈកម្មការជំនាញ ........ 69

៣. ទំនាក់ទំនងជាតិ និងអន្តរជាតិ ........ 74

៣.១ ទំនាក់ទំនងជាតិ ........ 74

៣.២ ទំនាក់ទំនងអន្តរជាតិ ........ 81

សន្និសីទអន្តរជាតិស្តីពី "ធ្វើឲ្យការប្រកបវិជ្ជាជីវៈរបស់លោកអ្នកទៅជាសកល ៖ ឱកាស និងការប្រឈម" ........ 81

កម្ពុជាធ្វើជាម្ចាស់ផ្ទះសន្និសីទលើកទី៣១ នៃសមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៅខេត្តសៀមរាប ........ 82

ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី ១២ និងជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី៩ ........ 89

# សារពីប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ១៩ សម្រាប់ត្រីមាសទី៤ ខែតុលា-ធ្នូ ឆ្នាំ២០១៨។ ព្រឹត្តិបត្រមេធាវីនេះបានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធដែលបានរួមចំណែកវិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធានបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃ គណៈមេធាវី ដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា រដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការបកស្រាយច្បាប់ជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបាន ជ្រាបពីកិច្ចដំណើរ ការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** នៃ**ផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។

ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការ មួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃ ការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំ ច នព្វស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

**សួន វិសាល**
ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# រដ្ឋប្បវេណី

# បណ្តឹងតវ៉ារបស់តតិយជន

**លោកមេធាវី អ៊ុវ ប៉ូលី***

## ១. សេចក្តីផ្តើម

ការធ្វើបណ្តឹងជាសិទ្ធិរបស់ភាគី ប្រសិនបើភាគីយល់ថា សិទ្ធិរបស់ខ្លួនជាអាទិ៍ ត្រូវបានបំពាន និងមានបំណងសង្គ្រោះសិទ្ធិនោះតាមផ្លូវតុលាការ។ ការអនុវត្តសិទ្ធិរបស់ភាគីនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ ឬនីតិវិធីអនុវត្តរក្សាការពារ ពេលខ្លះបានប៉ះពាល់ដល់សិទ្ធិ ឬផលប្រយោជន៍របស់តតិយជន ដោយសារការពិនិត្យស្រាវជ្រាវទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុល ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈខាងក្រៅប៉ុណ្ណោះ ហើយលក្ខណៈសារធាតុនៃសិទ្ធិមិនត្រូវបានស្រាវជ្រាវលម្អិតនោះទេ។ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីពុំមានផ្តល់អត្ថន័យតតិយជនជាបុគ្គលបែបណានោះទេ។ នៅក្នុងសន្ទានុក្រមរដ្ឋប្បវេណីបានពន្យល់ពាក្យតតិយជនថា ជាបុគ្គលទីបី ឬបុគ្គលដែលមិនមែនជាភាគី នៅក្នុងទំនាក់ទំនងគតិយុត្ត ឬបុគ្គលមិនមែនជាភាគីនៅក្នុងរឿងក្តីរដ្ឋប្បវេណី។

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងដែលតតិយជនប្តឹងតវ៉ាប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ដោយអះអាងថាកម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្តនៅក្រោមច្បាប់សារធាតុនោះទេ ប៉ុន្តែជាទ្រព្យសម្បត្តិរបស់តតិយជន ហើយទាមទារឲ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិទាំងនោះ (មាត្រា៣៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ បណ្តឹងតវ៉ារបស់តតិយជន ជាវិធីមួយដែលក្រមនីតិវិធីបានចែងដើម្បីសង្គ្រោះសិទ្ធិរបស់តតិយជន។ បណ្តឹងតវ៉ារបស់តតិយជនមិនមែនជាវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារ ដែលតតិយជនចង់ឲ្យសម្រេចតាមរយៈការអនុវត្តដោយបង្ខំនោះទេ។

បណ្តឹងតវ៉ារបស់តតិយជនអាចយកទៅអនុវត្តបាន ចំពោះការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ដូចជា ការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារឲ្យសងជាប្រាក់ ឬសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិ ឬការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុ ឬការឲ្យធ្វើសកម្មភាពជាកំណត់ជាអាទិ៍។ បណ្តឹងតវ៉ារបស់តតិយជនអាចធ្វើបាន ឬមិនបានអាស្រ័យទៅលើប្រភេទសិទ្ធិរបស់តតិយជនដែលមានចំពោះការអនុវត្តដោយបង្ខំថាតើសិទ្ធិនោះនឹងប៉ះពាល់ឬយ៉ាងណា ប្រសិនបើមានការអនុវត្តដោយបង្ខំហើយមានភាពចាំបាច់ និងផលប្រយោជន៍នៅក្នុងការដកចេញនូវការអនុវត្តឬទេ? ភាពចាំបាច់នៃការដកចេញជាស្ថានភាព ប្រសិនបើការអនុវត្តដោយបង្ខំត្រូវបានបន្តនឹង

---

*លោកមេធាវី អ៊ុវ ប៉ូលី ជាគ្រូបង្រៀនច្បាប់រដ្ឋប្បវេណីនៃសាលាមេធាវី និងជាប្រធានគណៈកម្មការកិច្ចការរដ្ឋប្បវេណីនៃគណៈមេធាវី

បណ្តាលឲ្យសិទ្ធិរបស់តតិយជនត្រូវបានបាត់បង់។ ផលប្រយោជន៍នៃការដកចេញ គឺជាស្ថានភាពកម្មវត្ថុនៃការអនុវត្តមានមួយផ្នែក ឬទាំងមូលជាទ្រព្យសម្បត្តិ (កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត) របស់តតិយជន ហើយមានលក្ខណៈមិនត្រឹមត្រូវ ដែលអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្តសម្រេចសិទ្ធិរបស់ខ្លួននៅក្នុងទំនាក់ទំនងធៀបនឹងតតិយជន។

បណ្តឹងតវ៉ារបស់តតិយជន ជាការប្រឆាំងនឹងការអនុវត្តដោយបង្ខំ ដោយតតិយជននឹងអះអាងអំពីកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ទ្រព្យសម្បត្តិ ក្នុងករណីភាគច្រើន សិទ្ធិរបស់តតិយជន គឺកម្មសិទ្ធិ។ **"សិទ្ធិផ្សេងទៀត"**ដែលរាំងស្ទះការធ្វើអនុប្បទានឬប្រគល់ទ្រព្យសម្បត្តិជាសិទ្ធិដែលអាចអះអាងចំពោះម្ចាស់បំណុលនៃការអនុវត្ត ដូចជាសិទ្ធិកាន់កាប់ (មាត្រា២២៧ នៃក្រមរដ្ឋប្បវេណី) សិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា២២៤ នៃក្រមរដ្ឋប្បវេណី) ផលុបភោគ (មាត្រា២៥៦ នៃក្រមរដ្ឋប្បវេណី) សិទ្ធិប្រើប្រាស់(មាត្រា២៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) សិទ្ធិអាស្រ័យនៅ(មាត្រា២៧៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) សេវភាព (មាត្រា២៨៥ នៃក្រមរដ្ឋប្បវេណី) ភតិសន្យា (មាត្រា៥៩៦ នៃក្រមរដ្ឋប្បវេណី) សិទ្ធិឃាត់ទុក (មាត្រា៧៧៤ នៃក្រមរដ្ឋប្បវេណី) ឬសិទ្ធិលើការបញ្ចាំ (មាត្រា៨១៦ នៃក្រមរដ្ឋប្បវេណី)ជាអាទិ៍។

ផ្អែកតាមមាត្រា**៣៦៥** នៃក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ជាក់អំពីមូលដ្ឋាននៃ បណ្តឹងតវ៉ារបស់តតិយជនថា "**តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ**"។ ឈរលើហេតុផលនេះ សម្រាប់តតិយជនអាចនឹងអះអាងអំពីមូលហេតុនៃបណ្តឹងតវ៉ា នៅពេលមានមូលហេតុបី ទី១ តតិយជនអាចរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយអះអាងអំពីកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ទី២ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់តតិយជនអាចតតាំងនឹងការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្ត និងទី៣ អត្ថិភាពនៃការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារដែលបានប៉ះពាល់ដល់កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់តតិយជន។\

## ២. តើនរណាជាភាគីនៃបណ្តឹងតវ៉ារបស់តតិយជន?

នៅក្នុងសំណុំរឿងបណ្តឹងតវ៉ារបស់តតិយជន បុគ្គលដែលអាចក្លាយជាដើមចោទត្រូវតែជាតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ទ្រព្យសម្បត្តិ។ ភាគច្រើនបំផុតសិទ្ធិរបស់តតិយជនជាកម្មសិទ្ធិ។ សិទ្ធិទាំងនោះត្រូវតែជាសិទ្ធិដែលអាចរងនូវការបំពាន ដោយសារការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្ត

ប្រសិនបើការអនុវត្តដោយបង្ខំនៅតែបន្ត។ បុគ្គលដែលអាចក្លាយជាចុងចម្លើយ គឺម្ចាស់បំណុល នៃការអនុវត្តមិនមែនអាជ្ញាសាលា ឬស្ថាប័នអនុវត្ត ឬតុលាការអនុវត្តនោះទេ។ ចំណែកកូនបំណុលនៃការអនុវត្ត ពុំមានលក្ខណៈសម្បត្តិជាដើមចោទ ឬចុងចម្លើយនៃបណ្ដឹងតវ៉ារបស់តតិយជននោះទេ ដោយសារកម្មវត្ថុនៃការអនុវត្តដោយបង្ខំដែលអាចត្រូវបានដកចេញមិនមែនជាទ្រព្យសម្បត្តិរបស់ខ្លួន មានន័យថា ខ្លួនគ្មានផលប្រយោជន៍នៃបណ្ដឹងក្នុងការទាមទារឲ្យដកចេញ ហើយក៏ពុំមានភាពចាំបាច់ឲ្យកូនបំណុលនៃការអនុវត្ត ក្លាយជាចុងចម្លើយនៅក្នុងករណីនេះផងដែរ។

ឧទាហរណ៍1៖ C បានលក់ដី និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិដីមក B។ បន្ទាប់មក C យល់ថា B បានឆបោកខ្លួន ហេតុនេះ C បានលុបចោលកិច្ចសន្យា ដោយផ្អែកលើការឆបោក (មាត្រា៣៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ក្រោយពីការលុបចោល C មិនទាន់ទទួលបានការចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យខ្លួនវិញនៅឡើយទេ។ A គឺជាម្ចាស់បំណុលរបស់ B និងបានរឹបអូសយកដីខាងលើដែលចុះបញ្ជីក្រោមឈ្មោះរបស់ B ។ C បានដាក់ពាក្យបណ្ដឹង ក្នុងនាមជាតតិយជនប្រឆាំងនឹង A ផ្អែកលើកម្មសិទ្ធិរបស់ខ្លួន។

ឧទាហរណ៍2៖ B បានលក់កុំព្យូទ័រមួយគ្រឿងទៅឲ្យ C ហើយបានផ្ទេរការកាន់កាប់កុំព្យូទ័រនោះដោយកិច្ចព្រមព្រៀង គឺមិនបានប្រគល់កុំព្យូទ័រជាក់ស្ដែងទេ(មាត្រា២២៩កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ A ជាម្ចាស់បំណុលរបស់ B បានរឹបអូសយកកុំព្យូទ័រដែល B បានកំពុងកាន់កាប់។ C បានដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជនប្រឆាំងនឹង A ផ្អែកលើកម្មសិទ្ធិរបស់គាត់។

## ៣. តើបណ្ដឹងតវ៉ារបស់តតិយជនអាចត្រូវបានដាក់ និងទទួល នៅពេលណា?

### ៣.១ អត្ថិភាពនៃការអនុវត្តដោយបង្ខំ

ជាគោលការណ៍ នៅពេលមានផលប្រយោជន៍ក្នុងការធ្វើបណ្ដឹង (មាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)កើតឡើងនៅក្រោយការចាប់ផ្ដើមការអនុវត្ត ដោយបង្ខំចំពោះកម្មវត្ថុដែលពាក់ព័ន្ធ។ ក្នុងករណីកម្មវត្ថុនៃការអនុវត្តដោយបង្ខំត្រូវបានបញ្ជាក់ ដូចជាការប្រគល់វត្ថុជាក់លាក់ណាមួយនោះ ប្រសិនបើមានការផ្ដល់រូបមន្តអនុវត្ត (មាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) នោះនឹងមានការទទួលស្គាល់ថា ការខូចខាតនឹងកើតមានឡើង នៅពេលការអនុវត្តដោយបង្ខំលេចចេញជាក់ស្ដែង និងពេលនោះផលប្រយោជន៍នៃការដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជននឹងត្រូវបានទទួលស្គាល់។

តតិយជនយល់ថាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដែលបានចាប់ផ្តើមអនុវត្តនោះ មានមួយផ្នែក ឬទាំងមូល ជាកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់ខ្លួន។

បណ្តឹងតវ៉ារបស់តតិយជនត្រូវបានទទួលស្គាល់ថា ជាវិធីដែលតតិយជនអាចសង្គ្រោះនូវសិទ្ធិរបស់ខ្លួនពីការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុល ហេតុនេះ នៅពេលដែលការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុដែលពាក់ព័ន្ធនោះត្រូវបានបញ្ចប់ ហើយផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនក៏ត្រូវរលត់ដែរ។ ប្រសិនបើ តតិយជននៅតែដាក់បណ្តឹងទៀត បណ្តឹងនោះនឹងត្រូវលើកចោល ដោយហេតុថា កម្មវត្ថុនោះត្រូវបានចាត់ចែងរួចហើយនាំឲ្យលែងមានភាពចាំបាច់ក្នុងការការពារផលប្រយោជន៍របស់តតិយជន ចំពោះទំនាក់ទំនង ឬសិទ្ធិនោះទៀតហើយ។

ឧទាហរណ៍៖ C មានរថយន្តមួយគ្រឿងបានជួលទៅឲ្យ B។ A គឺជាម្ចាស់បំណុលរបស់ B និងបានរឹបអូសយករថយន្តដែល B កំពុងកាន់កាប់។ C បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយចំពោះ A ទៅសាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែ C មិនបានដាក់ពាក្យសុំផ្អាកការអនុវត្តជាបណ្តោះអាសន្ន (មាត្រា៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ខណៈពេលដែលបណ្តឹងតវ៉ាដោយតតិយជនកំពុងត្រូវបានចាត់ការ ការអនុវត្តដោយបង្ខំនៅតែបន្ត ហើយរថយន្តនេះត្រូវបានលក់ទៅឱ្យ D តាមរយៈការលក់ដោយបង្ខំ រួចលោកDបានបង់ប្រាក់លក់ទិញទៅតុលាការទីបំផុតលុយនេះត្រូវបានប្រគល់ទៅឲ្យម្ចាស់បំណុលរបស់ B។

ចំណុចនេះការអនុវត្តដោយបង្ខំបានបញ្ចប់ ពាក្យសុំផ្អាកជាបណ្តោះនូវការអនុវត្តដោយបង្ខំមិនមានប្រសិទ្ធភាព។ ដូចនេះបណ្តឹងតវ៉ាដោយតតិយជនបាត់បង់ផលប្រយោជន៍នៃបណ្តឹងនាំឲ្យបណ្តឹងតវ៉ារបស់តតិយជននឹងត្រូវលើកចោល។

បណ្តឹងតវ៉ារបស់តតិយជនជាស្ថានភាព តតិយជនអះអាងថា កម្មវត្ថុនៃការអនុវត្តដោយបង្ខំមិនត្រឹមត្រូវដើម្បីសម្រេចនូវសិទ្ធិរបស់ម្ចាស់បំណុល ដោយមានទំនាក់ទំនងទៅនឹងសិទ្ធិរបស់ខ្លួន។ មួយវិញទៀត របៀបនៃការពិចារណាប្រភេទនៃសិទ្ធិរបស់តតិយជនចំពោះកម្មវត្ថុនៃការអនុវត្តថាតើសិទ្ធិនោះត្រូវខូចខាតដោយសារការអនុវត្តដោយបង្ខំ ឬយ៉ាងណា? តើមានភាពចាំបាច់ និងមានផលប្រយោជន៍ឬទេ ក្នុងការដកចេញនូវការអនុវត្ត?

## ៣.២ តតិយជនអះអាងអំពីកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដែលរារាំងដល់ការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ

ជាទូទៅ សិទ្ធិរារាំងការអនុវត្តដោយបង្ខំរបស់តតិយជន គឺជាកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ប៉ុន្តែភាគច្រើន តតិយជនអះអាងអំពីកម្មសិទ្ធិ។ សិទ្ធិកាន់កាប់ក៏ត្រូវបានការពារ ហើយក៏ជាសិទ្ធិដែលនាំឲ្យមានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជនផងដែរ។ ប្រសិនបើ តតិយជនកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត តាមច្បាប់ត្រូវមានការយល់ព្រមពីតតិយជននោះ ទើបអាជ្ញាសាលាអាចរឹបអូសបាន (មាត្រា៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប៉ុន្តែប្រសិនបើអាជ្ញាសាលាធ្វើការរឹបអូសចលនវត្ថុដោយគ្មានការយល់ព្រម តតិយជនអាចទាមទារឲ្យមានការសង្គ្រោះតាមវិធីនៃការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយផ្អែកលើការបំពានច្បាប់នៃនីតិវិធីអនុវត្តដោយបង្ខំ ឬដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន (មាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយផ្អែកលើការបំពានសិទ្ធិកាន់កាប់។

ក្នុងករណីការរឹបអូសអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្ត A ត្រូវភ្ជាប់នូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីដែលឈ្មោះរបស់កូនបំណុលត្រូវបានចុះបញ្ជីជាកម្មសិទ្ធិករ ឬត្រូវបញ្ជាក់ថា កូនបំណុលជាកម្មសិទ្ធិករ (មាត្រា៤១៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប្រសិនបើ A បានដាក់ពាក្យសុំរឹបអូសដីរបស់ B កម្មសិទ្ធិករដែលបានចុះបញ្ជីដីជា C ហើយ A មិនបានបញ្ជាក់ពីកម្មសិទ្ធិរបស់ B លើដីទេ នោះតុលាការមិនត្រូវចេញដីកាសម្រេចរឹបអូសដីនោះទេ ព្រោះពាក្យសុំមិនគោរពតាមមាត្រា ៤១៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើតុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសដីដោយមានកំហុស នោះដីកាសម្រេចនឹងខុសច្បាប់ ***ហេតុនេះ តតិយជនអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន (មាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។***

ផ្ទុយទៅវិញ ប្រសិនបើកម្មសិទ្ធិករដែលបានចុះបញ្ជីដីគឺជា B ហើយម្ចាស់បំណុលរបស់ B ដែលជា A បានដាក់ពាក្យសុំរឹបអូសដី នោះតុលាការអនុវត្តអាចចេញដីកាសម្រេចរឹបអូសដីបាន មិនថានរណាជាកម្មសិទ្ធិករនៃដីនោះទេ។ ក្នុងករណីនេះ ទោះបីជាកម្មសិទ្ធិករពិតប្រាកដមិនមែនជា B ប៉ុន្តែជា C ក៏ដោយ ក៏ដីកាសម្រេចនៅតែស្របច្បាប់ដែរ ព្រោះ A បានដាក់នូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី មានឈ្មោះរបស់ B ត្រូវបានចុះបញ្ជីថាជាកម្មសិទ្ធិករ។ ដូច្នេះ C មិនអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (មាត្រា៣៨៤ នៃក្រមនីតិវិធី

រដ្ឋប្បវេណី)បានទេ ប៉ុន្តែអាចដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជនបាន (មាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### ៣.៣ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់តតិយជនដែលអាចតតាំងនឹងការអនុវត្តរបស់ម្ចាស់បំណុលនៃការអនុវត្ត

ស្ថានភាពសម្រាប់ពិចារណានៃសិទ្ធិរបស់តតិយជនដែលអាចតតាំងនឹងការអនុវត្តរបស់ម្ចាស់បំណុលនៃការអនុវត្ត មានដូចខាងក្រោមនេះ៖

**ទី១ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឲ្យសងជាប្រាក់**

ប្រសិនបើខ្លឹមសារនៃការអនុវត្តដោយបង្ខំគ្មានគោលបំណងឲ្យសងជាប្រាក់ ដូចជា ការបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តប្រគល់វត្ថុជាក់លាក់ (កម្មវត្ថុនៃការអនុវត្តដោយបង្ខំ) ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ដូចជា អចលនវត្ថុ ជាអាទិ៍ សិទ្ធិដែលរាំងស្ទះដល់ការប្រគល់អាចជាសិទ្ធិកាន់កាប់ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិជួលអចលនវត្ថុ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិឃាត់ទុក និងសិទ្ធិលើការបញ្ចាំ។ ប្រសិនបើ ការអនុវត្តដោយបង្ខំនៅតែបន្តអាចនឹងនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ប្រសិនបើ សិទ្ធិខាងលើនេះរបស់តតិយជនមានលក្ខណៈត្រឹមត្រូវតាមច្បាប់សារធាតុ។ ប៉ុន្តែឯកសិទ្ធិ (មាត្រា៧៨១ នៃក្រមរដ្ឋប្បវេណី) និងហ៊ីប៉ូតែក (មាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណី)ជាអាទិ៍ មិនស្ថិតនៅក្នុងសិទ្ធិផ្សេងៗទៀតនៃមាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ពីព្រោះទោះបីសិទ្ធិទាំងនេះទទួលបានការសងជាអាទិភាពក៏ពិតមែន ប៉ុន្តែម្ចាស់បំណុលហ៊ីប៉ូតែក ឬម្ចាស់បំណុលឯកសិទ្ធិមិនមានសិទ្ធិកាន់កាប់ ឬប្រើប្រាស់ ឬអាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហេតុនេះសិទ្ធិទាំងនេះមិនរារាំងក្នុងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។

ឧទាហរណ៍1៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំឲ្យប្រគល់អចលនវត្ថុ L ដែលស្ថិតក្រោមឈ្មោះ B (កូនបំណុលនៃការអនុវត្ត)។ អចលនវត្ថុ L ជាប់បន្ទុកហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែក C និងបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់។ ករណីនេះ C គ្មានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជននោះទេ ពីព្រោះសិទ្ធិរបស់ Cមិនត្រូវបានបំពានដោយសារការប្រគល់អចលនវត្ថុនោះទៅឲ្យ A ហើយសិទ្ធិរបស់Cនៅតែបន្តអត្ថិភាពលើអចលនវត្ថុផ្អែកលើអានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស (មាត្រា៧៧២ នៃក្រមរដ្ឋប្បវេណី)។ ***ផ្ទុយទៅវិញប្រសិនបើ C អះអាងអំពីកម្មសិទ្ធិនាំឲ្យ C មានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជន ពីព្រោះសិទ្ធិរបស់ C ត្រូវបានបំពាន និងអាចតតាំងចំពោះការប្រគល់អចលនវត្ថុនោះទៅឲ្យ A***។

ឧទាហរណ៍2៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំឲ្យប្រគល់អចលនវត្ថុ L ដែលស្ថិតក្រោមឈ្មោះ B (កូនបំណុលនៃការអនុវត្ត)។ ***<u>អចលនវត្ថុ L ជាប់សិទ្ធិជួលរបស់ C និង C កំពុងកាន់កាប់អចលនវត្ថុ L</u>***។ ករណីនេះ C មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ព្រោះសិទ្ធិរបស់ C អាចនឹងត្រូវបានបាត់បង់(ការកាន់កាប់ ការប្រើប្រាស់-អាស្រ័យផល) ប្រសិនបើការអនុវត្តដោយបង្ខំនៅតែបន្ត ហើយសិទ្ធិរបស់ C អាចតតាំងនឹងការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្ត (មាត្រា៥៩៨ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍3៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំឲ្យប្រគល់រថយន្តដែលស្ថិតក្រោមការកាន់កាប់របស់ B (កូនបំណុលនៃការអនុវត្ត)។ ***<u>រថយន្តនេះជាប់សិទ្ធិឃាត់ទុករបស់ C</u>***។ C បានជួលរថយន្តនេះឲ្យទៅ B។ B មិនបានបដិសេធក្នុងការប្រគល់រថយន្តឲ្យទៅអាជ្ញាសាលាតាមការអនុវត្តរបស់ A។ ករណីនេះ C មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ពីព្រោះសិទ្ធិរបស់ C ត្រូវរងប៉ះពាល់ដោយមិនអាចអាស្រ័យផល ដោយមានអាទិភាពពីវត្ថុឃាត់ទុក និងអាចបាត់បង់ការកាន់កាប់វត្ថុឃាត់ទុក បើការអនុវត្តដោយបង្ខំមិនត្រូវបានដកចេញ (មាត្រា៧៧៥ និង មាត្រា៥៧៦ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍4 ៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំឲ្យប្រគល់រថយន្តដែលស្ថិតក្រោមការកាន់កាប់របស់ B (កូនបំណុលនៃការអនុវត្ត)។ ***<u>រថយន្តនេះជាប់សិទ្ធិលើការបញ្ចាំរបស់ C</u>***។ C បានប្រគល់រថយន្តនេះឲ្យទៅBគ្រប់គ្រងក្នុងនាមខ្លួន។ B មិនបានបដិសេធក្នុងការប្រគល់រថយន្តឲ្យទៅអាជ្ញាសាលាតាមការអនុវត្តរបស់ A។ ករណីនេះ C មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ពីព្រោះសិទ្ធិរបស់ C ត្រូវរងប៉ះពាល់ ដោយមិនអាចប្រើប្រាស់ និងអាស្រ័យផល និងអាចបាត់បង់ការឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ បើការអនុវត្តដោយបង្ខំ មិនត្រូវបានដកចេញ(មាត្រា៨២១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍5៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំឲ្យប្រគល់រថយន្តដែលស្ថិតក្រោមការកាន់កាប់របស់ B (កូនបំណុលនៃការអនុវត្ត)។ **រថយន្តនេះជាប់សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ C**។ C បានកាន់កាប់រថយន្តនេះ C បានប្រគល់រថយន្តនេះ ឲ្យទៅ B ឲ្យគ្រប់គ្រងក្នុងនាមខ្លួន(C)។ B មិនបានបដិសេធក្នុងការប្រគល់រថយន្តឲ្យទៅអាជ្ញាសាលាតាមការអនុវត្តរបស់ A។ ករណីនេះ C មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ពីព្រោះសិទ្ធិរបស់ C ត្រូវរងប៉ះពាល់ ដោយសារ C អាចបាត់បង់ការកាន់កាប់វត្ថុដែលជាលក្ខខណ្ឌតតាំងជាមួយនឹងតតិយជន បើការអនុវត្តដោយបង្ខំមិនត្រូវបានដកចេញ (មាត្រា៨៩០ នៃក្រមរដ្ឋប្បវេណី)។

### ទី២ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់

ប្រសិនបើខ្លឹមសារនៃការអនុវត្តដោយបង្ខំមានគោលបំណងឲ្យសងជាប្រាក់ ជាការលក់ដោយបង្ខំនូវវត្ថុជាក់លាក់ណាមួយ (កម្មវត្ថុនៃការអនុវត្តដោយបង្ខំជាអចលនវត្ថុជាអាទិ៍) អាចនឹងត្រូវបានធ្វើឡើង ដើម្បីសម្រេចសិទ្ធិលើបំណុលរបស់ A ក្នុងនាមជាម្ចាស់បំណុលនៃការអនុវត្ត ចំពោះទ្រព្យសម្បត្តិទទួលខុសត្រូវរបស់ B ដែលជាកូនបំណុលនៃការអនុវត្ត ហើយ A យល់ថា អចលនវត្ថុ L ជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្ត។ ក្នុង ករណីនេះ ប្រសិនបើតតិយជន C អះអាងអំពីកម្មសិទ្ធិរបស់ខ្លួនចំពោះកម្មវត្ថុនៃការអនុវត្តដោយបង្ខំ នាំឲ្យមានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជន ពីព្រោះ ការអនុវត្តដោយបង្ខំបានបំពានសិទ្ធិរបស់ C ដោយសារកម្មវត្ថុនៃការអនុវត្តនេះមិនមែនជាទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត និងធ្វើឲ្យតតិយជនបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះ ហើយកម្មសិទ្ធិរបស់ C អាចតតាំងនឹងការអនុវត្តដោយបង្ខំ។ ផ្ទុយទៅវិញ ក្នុងករណីនេះ ប្រសិនបើតតិយជន អះអាងអំពីសិទ្ធិកាន់កាប់ ឬសិទ្ធិលើការបញ្ចាំ ឬផលុបភោគជាអាទិ៍ ការលក់ដោយបង្ខំចំពោះ អចលនវត្ថុនេះ មិនធ្វើឲ្យសិទ្ធិរបស់តតិយជនត្រូវបាត់បង់នោះទេ នាំឲ្យតតិយជននោះគ្មានមូល ហេតុនៃបណ្ដឹងតវ៉ារបស់តតិយជនឡើយ។

ឧទាហរណ៍1៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំរឹបអូសអចលនវត្ថុដែលបានចុះបញ្ជីក្រោមឈ្មោះ B (កូនបំណុលនៃការអនុវត្ត) ដើម្បីលក់ប្តូរជាប្រាក់សម្រេចសិទ្ធិលើបំណុលរបស់ខ្លួនដែលមានកំណត់ក្នុងសាលក្រមស្ថាពរ (បង្គាប់ឲ្យ B បង់ប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកឲ្យមក A) ជាអាទិ៍។ A យល់ថា អចលនវត្ថុ L ជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់ B ប៉ុន្តែតាមពិត កម្មសិទ្ធិករនៃអចលនវត្ថុពិតប្រាកដគឺ C។ ករណីនេះ តតិយជន C មានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជន ពីព្រោះការអនុវត្តដោយបង្ខំធ្វើ ឲ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់ខ្លួន។ ផ្ទុយទៅវិញ ប្រសិនបើ C អះអាងអំពីសិទ្ធិលើការបញ្ចាំចំពោះ អចលនវត្ថុ គឺCគ្មានមូលហេតុនៃបណ្ដឹងតវ៉ារបស់តតិយជននោះទេ ពីព្រោះការលក់ដោយបង្ខំចំពោះអចលនវត្ថុរបស់ Bគ្រាន់តែនាំឲ្យមានការផ្ទេរកម្មសិទ្ធិពី B ទៅអ្នកទិញតាមផ្លូវតុលាការប៉ុណ្ណោះ ដោយមិនមានការផ្ទេរការកាន់កាប់លើអចលនវត្ថុនោះទេ។ មួយវិញទៀត អ្នកទិញតាមផ្លូវតុលាការមិនមែនទទួលបានការផ្ទេរការកាន់កាប់ដោយស្វ័យប្រវត្តិនោះទេ គឺគ្រាន់តែទទួលបានការផ្ទេរកម្មសិទ្ធិប៉ុណ្ណោះ។ ហេតុនេះ ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុត្រូវបានផ្ទេរ ពីកូនបំណុលនៃការអនុវត្ត (កម្មសិទ្ធិករនៃវត្ថុ) ទៅឲ្យអ្នកទិញតាមផ្លូវតុលាការក៏ដោយ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំចំពោះអចលនវត្ថុ (តតិយជន C) នៅតែអាចបន្តកាន់កាប់អចលនវត្ថុនោះ រហូតទទួលបានការ

សងដដែល លើកលែងតែសិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់ បំណុលដែលមានអាទិភាពជាង ខ្លួន (មាត្រា៨២១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍2៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំរឹបអូសចលនវត្ថុរបស់ B (កូនបំណុលនៃការអនុវត្ត) ដើម្បីលក់ប្តូរជាប្រាក់សម្រេចសិទ្ធិលើ បំណុលរបស់ខ្លួនដែលមាន កំណត់ក្នុងសាលក្រមស្ថាពរ (បង្គាប់ឲ្យ B បង់ប្រាក់ចំនួន ១០.០០០ ដុល្លារ អាមេរិកឲ្យមក A) ជាអាទិ៍។ A យល់ថា រថយន្តនៅផ្ទះរបស់ B ជាទ្រព្យសម្បត្តិរបស់ B ប៉ុន្តែតាមពិត B ខ្ចីរថយន្ត របស់ C មកជិះនោះទេ។ ក្នុងករណីនេះ C មានមូលហេតុនៃបណ្តឹង តវ៉ារបស់តតិយជន ដោយ អះអាងអំពីកម្មសិទ្ធិ និងបញ្ជាក់ថាកម្មវត្ថុនៃការអនុវត្ត (រថយន្ត) មិនមែនជាទ្រព្យសម្បត្តិទទួល ខុសត្រូវរបស់កូនបំណុលនៃការអនុវត្តនោះទេ មានភាពចាំបាច់ និងផលប្រយោជន៍ក្នុងការដក ចេញនូវការអនុវត្តដោយបង្ខំ។ ផ្ទុយទៅវិញ ប្រសិនបើ C អះអាងអំពីសិទ្ធិជួលនៅលើរថយន្ត នាំឲ្យ C គ្មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ដោយហេតុថា សិទ្ធិរបស់ C មិនអាចត តាំងការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្ត (C មិន បានកាន់កាប់រថយន្ត)។

ឧទាហរណ៍3 ៖A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំរឹបអូសចលនវត្ថុរបស់ B (កូនបំណុលនៃការអនុវត្ត) ដើម្បីលក់ប្តូរជាប្រាក់សម្រេចសិទ្ធិលើបំណុលរបស់ខ្លួនដែលមាន កំណត់ក្នុងសាលក្រមស្ថាពរ (បង្គាប់ឲ្យ B បង់ប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកឲ្យមក A) ជាអាទិ៍។ A យល់ថា រថយន្តនៅផ្ទះរបស់ B ជាទ្រព្យសម្បត្តិរបស់ B ប៉ុន្តែតាមពិត B បានលក់ រថយន្តនេះឲ្យទៅ C រួចហើយ ប៉ុន្តែ B មិនទាន់បានប្រគល់ C ។ ក្នុងករណីនេះ C មានមូល ហេតុនៃបណ្តឹងតវ៉ារបស់តតិយជន ដោយអះអាងអំពីកម្មសិទ្ធិ និងបញ្ជាក់ថាកម្មវត្ថុនៃការអនុវត្ត (រថយន្ត)មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូន បំណុលនៃការអនុវត្តនោះទេ មាន ភាពចាំបាច់ និងផលប្រយោជន៍ក្នុងការដកចេញនូវការអនុវត្តដោយបង្ខំ។ ទោះបីជាតតិយជន មិនបានកាន់កាប់ជាក់ស្តែងក៏ដោយ ប៉ុន្តែការកាន់កាប់ដោយប្រយោលមានអត្ថិភាពតាមរយៈការ ប្តូរលក្ខណៈនៃការកាន់កាប់ (មាត្រា១៣៤ កថាខណ្ឌទី២ និងមាត្រា២៩៩ កថាខណ្ឌទី២ នៃក្រម រដ្ឋប្បវេណី) ហេតុនេះលទ្ធកម្មកម្មសិទ្ធិរបស់ C អាចតតាំងនឹងការអនុវត្តរបស់ម្ចាស់បំណុលនៃ ការអនុវត្ត A បាន។

### ទី៣ ការអនុវត្តសិទ្ធិប្រាតិភោគ

ប្រសិនបើខ្លឹមសារនៃការអនុវត្តដោយបង្ខំជាការអនុវត្តសិទ្ធិប្រាតិភោគ តាមរយៈការ លក់ ដោយបង្ខំនូវវត្ថុជាក់លាក់ណាមួយ (កម្មវត្ថុនៃការអនុវត្តដោយបង្ខំជាអចលនវត្ថុជាអាទិ៍) អាចនឹងត្រូវបានធ្វើឡើង ដើម្បីសម្រេចសិទ្ធិលើបំណុលរបស់ A ក្នុងនាមជាម្ចាស់បំណុលនៃការ

អនុវត្ត ចំពោះទ្រព្យសម្បត្តិទទួលខុសត្រូវរបស់ B ដែលជាកូនបំណុលនៃការអនុវត្ត ហើយ A យល់ថាអចលនវត្ថុ L ជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូន បំណុលនៃការអនុវត្តដែល ត្រូវបានដាក់ប្រាតិភោគដើម្បីធានាសិទ្ធិលើបំណុលក្រោមរូបភាពជាហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំជាអាទិ៍។ ក្នុងករណីនេះ ប្រសិនបើ តតិយជន C អះអាងអំពីកម្ម សិទ្ធិរបស់ខ្លួនចំពោះ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ នាំឲ្យមានមូលហេតុនៃការធ្វើបណ្តឹងតវ៉ារបស់តតិយជន ពីព្រោះការអនុវត្តដោយបង្ខំបានបំពានសិទ្ធិរបស់ C ដោយសារកម្មវត្ថុនៃការអនុវត្តនេះមិនមែនជាទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត និងធ្វើឲ្យតតិយជនបាត់បង់កម្មសិទ្ធិលើ អចលនវត្ថុនោះ ប្រសិនបើការអនុវត្តដោយបង្ខំនៅតែបន្ត។ ផ្ទុយទៅវិញក្នុងករណីនេះ ប្រសិនបើតតិយជនអះអាងអំពីសិទ្ធិកាន់កាប់ ឬសិទ្ធិលើការបញ្ចាំ ឬផលុបភោគជាអាទិ៍ ការលក់ដោយបង្ខំចំពោះអចលនវត្ថុនេះមិនធ្វើឲ្យបាត់បង់សិទ្ធិរបស់តតិយជននោះទេ។

ឧទាហរណ៍1៖ A (ម្ចាស់បំណុល នៃការអនុវត្ត) បានដាក់ពាក្យសុំរឹបអូសអចលនវត្ថុដែលបានចុះបញ្ជីក្រោមឈ្មោះ B (កូនបំណុលនៃការអនុវត្ត) ដើម្បីលក់ប្តូរជាប្រាក់សម្រេចសិទ្ធិលើបំណុលរបស់ខ្លួនដែលត្រូវបានធានាដោយប្រាតិភោគ (វិសាលភាពនៃហ៊ីប៉ូតែកដែលត្រូវបានធានាមានចំនួន ១០.000 ដុល្លារអាមេរិក)ជាអាទិ៍។ A យល់ថាអចលនវត្ថុ L ជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់ B ប៉ុន្តែតាមពិតកម្មសិទ្ធិករនៃអចលនវត្ថុពិតប្រាកដគឺC។ ករណីនេះតតិយជន C មានមូលដ្ឋាននៃបណ្តឹងតវ៉ារបស់តតិយជន ពីព្រោះការអនុវត្តដោយបង្ខំធ្វើឲ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់ខ្លួន។ ផ្ទុយទៅវិញ ប្រសិនបើ C អះអាងអំពីសិទ្ធិលើ ការបញ្ចាំចំពោះអចលនវត្ថុ គឺ C គ្មានមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជននោះទេ ពីព្រោះការលក់ដោយបង្ខំចំពោះអចលនវត្ថុរបស់ A គឺការផ្ទេរកម្មសិទ្ធិពី B ទៅអ្នកទិញតាមផ្លូវតុលាការប៉ុណ្ណោះ ដោយសិទ្ធិរបស់ C មិនត្រូវបានបាត់បង់នោះទេ។ មួយវិញទៀត អ្នកទិញតាមផ្លូវតុលាការមិនមែនទទួលបានការផ្ទេរការកាន់កាប់ដោយស្វ័យប្រវត្តិនោះទេ គឺគ្រាន់តែទទួលបានការផ្ទេរកម្មសិទ្ធិប៉ុណ្ណោះ។ ហេតុនេះទោះបីជាកម្មសិទ្ធិលើអចលនវត្ថុត្រូវបានផ្ទេរពីកូនបំណុលនៃការអនុវត្ត (កម្មសិទ្ធិករនៃវត្ថុ) ទៅឲ្យអ្នកទិញតាមផ្លូវតុលាការក៏ដោយ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំចំពោះអចលនវត្ថុ (តតិយជន C) នៅតែអាចបន្តកាន់កាប់អចលនវត្ថុនោះ រហូតទទួលបានការសងដដែល លើកលែងតែសិទ្ធិនេះមិនអាចតតាំងចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួន (មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍2៖ A (ម្ចាស់បំណុលនៃការអនុវត្ត) បានដាក់ពាក្យសុំរឹបអូសអចលនវត្ថុដែលបានចុះបញ្ជីក្រោមឈ្មោះB(កូនបំណុលនៃការអនុវត្ត) ដើម្បីលក់ប្តូរជាប្រាក់សម្រេចសិទ្ធិ

លើបំណុលរបស់ខ្លួនដែលត្រូវបានធានាដោយប្រាតិភោគ (វិសាលភាពនៃហ៊ីប៉ូតែកដែលត្រូវបានធានាមានចំនួន ១០.០០០ ដុល្លារអាមេរិក)ជាអាទិ៍។ A យល់ថា អចលនវត្ថុ L ដែលមានអាគារជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់B។ ប៉ុន្តែតាមពិតកម្មសិទ្ធិករនៃអាគារពិតប្រាកដគឺ C ដោយ C បានសាងសង់អាគារផ្អែកលើសិទ្ធិជួល។ ករណីនេះ តតិយជន C មានមូលដ្ឋាននៃបណ្ដឹងតវ៉ារបស់តតិយជន ពីព្រោះការអនុវត្តដោយបង្ខំធ្វើឲ្យប៉ះពាល់ដល់កម្មសិទ្ធិនៃអាគាររបស់ខ្លួនដែលតម្រូវឲ្យដកចេញនូវការអនុវត្តដោយបង្ខំមួយផ្នែក(មាត្រា៤៤៧ នៃក្រមរដ្ឋប្បវេណី)។

## ៤. តើបណ្ដឹងតវ៉ារបស់តតិយជនត្រូវសរសេរដូចម្ដេច?

តតិយជនត្រូវដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន ទៅតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ឬតុលាការដែលអាជ្ញាសាលាស្ថិតនៅក្រោម (ស្ថាប័នអនុវត្ត) នោះស្ថិតនៅ ដោយបង់ប្រាក់ប្រដាប់ក្ដីដូចនឹងបណ្ដឹងធម្មតាផងដែរ ប៉ុន្តែចំពោះពន្ធដាក់ពាក្យសុំត្រូវបង់តែ១/២នៃពន្ធដាក់ពាក្យសុំនៅក្នុងបណ្ដឹងធម្មតា (ប្រកាសលេខ៥៤ កយប្រក/០៩ ទំព័រ១៨ និង១៩)។ ជាគោលការណ៍ តុលាការអាចចេញសាលក្រមបានទាល់តែមានពាក្យបណ្ដឹង និងការទាមទារ តុលាការមិនអាចចេញអ្វីហួសពីការទាមទាររបស់ភាគីនេះឡើយ (មាត្រា១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ពាក្យបណ្ដឹងត្រូវតែគោរពតាមមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយ<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញគឺ ៖</u>

ការអនុវត្តដោយបង្ខំដែលចុងចម្លើយ A បានដាក់ដោយផ្អែកលើអនុសារសាលក្រមដែលមានរូបមន្តអនុវត្តក្នុងរឿងក្ដី (បញ្ជាក់រឿងក្ដីនៃសាលក្រមដែលបានដាក់ពាក្យសុំអនុវត្ត) ចុះថ្ងៃខែឆ្នាំ លើទ្រព្យសម្បត្តិ (អត្តសញ្ញាណទ្រព្យសម្បត្តិ) ***<u>មិនត្រូវបានអនុញ្ញាត</u>***។

<u>អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ</u>

កម្មវត្ថុនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬទាំងមូល គឺជាកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់ដើមចោទដែលអាចរារាំងដល់ការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុ។

**<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ</u>**(មាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

១) ចុងចម្លើយ A បានដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅសាលាដំបូងរាជធានីភ្នំពេញ ដោយផ្អែកលើសាលក្រម (រឿងក្ដីលេខ ចុះថ្ងៃទីខែឆ្នាំ........របស់សាលាដំបូងរាជធានីភ្នំពេញ) ហើយតុលាការអនុវត្តបានរឹបអូសអចលនវត្ថុដែលបាន រៀបរាប់ក្នុងបញ្ជីទ្រព្យសម្បត្តិ។

២) ដើមចោទ C ជាកម្មសិទ្ធិករនៃទ្រព្យដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិ។ (នៅក្នុងការអនុវត្តជាក់ស្តែង C ត្រូវរៀបរាប់លម្អិតបន្ថែមទៀតអំពីរបៀបដែលគាត់បានទទួលកម្មសិទ្ធិលើអចលនវត្ថុនោះ)។

**គំរូនៃពាក្យបណ្តឹងតវ៉ារបស់តតិយជន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

**ដើមចោទ** ៖ ឈ្មោះ C ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១២ ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ "ដើមចោទ"** ៖ មេធាវី P ជាមេធាវីនៃក្រុមហ៊ុនមេធាវី ..................ដែលមានអាសយដ្ឋានស្ថិតនៅ.....................................................។

**ចុងចម្លើយ** ៖ ឈ្មោះ A ភេទស្រី អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

**១.** ការអនុវត្តដោយបង្ខំដែលចុងចម្លើយ A បានដាក់ដោយផ្អែកលើអនុសារសា លក្រមដែលមានរូបមន្តអនុវត្តចំពោះ B ក្នុងរឿងក្តី (សំណុំរឿងអនុវត្តលេខ ១០ ចុះថ្ងៃទី ១០ កញ្ញា ២០១៥) លើអចលនវត្ថុជាដីដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០៣ ផ្លូវលេខ០៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៣១២ មិនត្រូវបានអនុញ្ញាត

**២.** ប្រាក់ប្រដាបក្តីជាបន្ទុករបស់ A

**ខ.អង្គហេតុចាំបាច់ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ខ.១ ការចាប់ផ្ដើមនីតិវិធីនៃការអនុវត្តដោយបង្ខំ (ឬនីតិវិធីនៃការចាត់ចែងរក្សាការពារ)

ខ.២ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់ដើមចោទដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ទ្រព្យសម្បត្តិ

-

ខ.៣ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់ដើមចោទអាចតតាំងនឹងការអនុវត្តដោយបង្ខំ

-

**គ.ភស្តុតាង**

-

សេចក្ដីដូចជម្រាបជូនខាងលើ សូម**លោកប្រធាន** មេត្តាសម្រេច តាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៨

**អ្នកតំណាងដោយអាណត្តិ**

**P**

## តើបណ្ដឹងតវ៉ារបស់តតិយជនមានអានុភាពផ្អាកការអនុវត្តដោយបង្ខំឬទេ?

ពាក្យបណ្ដឹងតវ៉ារបស់តតិយជន មិនមានអានុភាពផ្អាកដោយស្វ័យប្រវត្តិនូវការអនុវត្តនោះទេ ហើយក៏មិនរារាំងការបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។ ក្នុងករណីតតិយជនបានដាក់បណ្ដឹងតវ៉ារបស់តតិយជន ដោយផ្អែកលើភាពជាម្ចាស់សិទ្ធិរបស់គាត់ ប៉ុន្តែនីតិវិធីនៃការអនុវត្តដោយបង្ខំនៅតែបន្ត តើនឹងមានអ្វីកើតឡើង?

ក្នុងករណីនេះ ការអនុវត្តដោយបង្ខំអាចត្រូវបានបញ្ចប់ មុនពេលសាលក្រមលើបណ្ដឹងតវ៉ារបស់តតិយជនបានចេញ ហើយបណ្ដឹងតវ៉ារបស់តតិយជនក្លាយជាគ្មានប្រយោជន៍។ ដូច្នេះ ដើម្បីការពារតតិយជន ក្រមនីតិវិធីរដ្ឋប្បវេណីបានបង្កើតយន្តការសង្គ្រោះបឋមមួយ ដោយបានផ្ដល់នូវមធ្យោបាយ ឬវិធាននៃការផ្អាកការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន តាមរយៈការសុំដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្ត (មាត្រា៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ បើតតិយជនអាចធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការតវ៉ា នោះតុលាការអាចចេញដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំមួយរយៈដោយឲ្យដាក់ ឬមិនឲ្យដាក់ប្រាតិភោគរហូតដល់ពេលចេញ

សាលក្រមចុងក្រោយ។ ក្នុងករណីតតិយជនដាក់ពាក្យសុំលុបចោលការចាត់ចែងការអនុវត្ត បើតុលាការពិនិត្យឃើញថាមានសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការតវ៉ា និងមានលទ្ធភាពជាក់ស្ដែងក្នុងការដាក់ប្រាតិភោគ តុលាការនឹងចេញដីកាសម្រេចបង្គាប់ឲ្យដាក់ប្រាតិភោគ និងប្រសិនបើ តតិយជនបានដាក់ប្រាតិភោគតាមខ្លឹមសារនៃដីកាសម្រេចបង្គាប់ឲ្យដាក់ប្រាតិភោគ តុលាការនឹងចេញដីកាសម្រេចលុបចោល នូវការចាត់ចែងការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ។

តតិយជនអាចដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន រួមគ្នាជាមួយនឹងបណ្ដឹងតវ៉ារបស់តតិយជនបាន ឬអាចដាក់ពាក្យសុំនោះបន្ទាប់ ឬក្រោយពីដាក់ពាក្យបណ្ដឹង មានន័យថា ក្នុងអំឡុងពេលដែលបណ្ដឹងតវ៉ារបស់តតិយជនកំពុងចាត់ការ។ ប្រសិនបើតតិយជនបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិជាអាទិ៍ របស់ខ្លួនបានជោគជ័យ តុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន។ ដីកាសម្រេចនេះជាឯកសារ នៃមាត្រា៣៧០ កថាខណ្ឌ២ ចំណុចក នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះ បើតតិយជន ដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត តុលាការអនុវត្តនឹងផ្អាកការអនុវត្ត។ ប្រសិនបើតុលាការចេញដីកាសម្រេចបង្គាប់ឲ្យលុបចោលការចាត់ចែងការអនុវត្តតាមមាត្រា ៣៦៧ កថាខណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចនេះជាឯកសារនៃមាត្រា មាត្រា៣៧០ កថាខណ្ឌ១ ចំណុចធ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះបើតតិយជនដាក់ដីកាសម្រេចនេះ ទៅតុលាការអនុវត្តតុលាការអនុវត្តនឹងលុបចោលការអនុវត្ត។

*ដូចបានឃើញខាងលើនេះនៅពេលដែលមានការដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន មេធាវីគប្បីដាក់ពាក្យសុំឲ្យផ្អាកការអនុវត្ត ឬពាក្យសុំលុបចោលការអនុវត្ត ពីព្រោះបណ្ដឹងតវ៉ារបស់តតិយជនមិននាំឲ្យនីតិវិធីអនុវត្តដោយបង្ខំត្រូវបានផ្អាក ឬលុបចោលដោយស្វ័យប្រវត្តិនោះទេ ហេតុនេះ មេធាវីត្រូវពិនិត្យចំណុចនេះដោយហ្មត់ចត់ រួមទាំងខ្លឹមសារនៃការស្នើសុំ។*

**គំរូនៃពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំឲ្យផ្អាកការអនុវត្តដោយបង្ខំ**

ឈ្មោះ C ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះ លេខ

១២ ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំផ្អាកការអនុវត្តដោយបង្ខំ ដែលចុងចម្លើយ A បានដាក់ ដោយផ្អែកលើអនុសារសាលក្រមដែលមានរូបមន្តអនុវត្តចំពោះ B ក្នុងរឿងក្តី (សំណុំរឿងអនុវត្តលេខ ១០ ចុះថ្ងៃទី១០ កញ្ញា ២០១៥) លើអចលនវត្ថុជាដីដែលមានទីតាំងស្ថិតនៅផ្ទះលេខ០៣ ផ្លូវលេខ ០៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៣១២។

**យោង** ៖-មាត្រា **៣៦៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ **៩០** ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៨

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទ សូមជម្រាបជូន ឯកឧត្តមប្រធានមេត្តាជ្រាបថា៖

.......................................................................................................................

.......................................................................................................................

.......................................................................................................................

## ក.ដំណើររឿង

-

-

-

## ខ.មូលហេតុនៃការតវ៉ា

-

-

-

## គ.សេចក្តីបញ្ជាក់ដំបូង

-

-

សេចក្ដីដូចជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាសម្រេច តាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៨

**ស្នាមម្រាមដៃ**

**C**

### ប្រសិនបើ បណ្ដឹងតវ៉ារបស់តតិយជនត្រូវបានដាក់ តើតុលាការត្រូវចាត់ការដូចម្ដេច?

សម្រាប់នីតិវិធីជំនុំជម្រះលើបណ្ដឹងតវ៉ារបស់តតិយជន គឺធ្វើដូចនីតិវិធីនៃការជម្រះក្ដីលើកទី១ដែរ។ តុលាការដែលទទួលពាក្យបណ្ដឹងត្រូវពិនិត្យពាក្យបណ្ដឹង។ តុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផល និងប្រកាសសាលក្រម ហើយចេញសាលក្រមចុងក្រោយ។

ក្នុងករណី តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ តុលាការត្រូវចេញសាលក្រម ដែលមានខ្លឹមសារថា៖

ការអនុវត្តដោយបង្ខំ ដែលធ្វើឡើងដោយចុងចម្លើយ A ដោយផ្អែកលើឯកសារចម្លងយថាភូតនៃអនុសារសាលក្រម ដែលភ្ជាប់ជាមួយរូបមន្តអនុវត្តនៃរឿងក្ដីលេខ.......ចុះថ្ងៃទីខែឆ្នាំរបស់តុលាការ...ទៅលើទ្រព្យសម្បត្តិដែលបានរៀបរាប់ក្នុងបញ្ជីទ្រព្យសម្បត្តិ***មិនត្រូវបានអនុញ្ញាត***។

តតិយជនដែលបានឈ្នះក្ដីអាចលុបចោលការអនុវត្តដោយបង្ខំ ឬការអនុវត្តដីកាសម្រេចរក្សាការពារ ដោយដាក់លិខិតយថាភូតនៃឯកសារទាំងនេះ ទៅតុលាការអនុវត្ត (មាត្រា៣៧០)។ សាលក្រម ឬសាលដីកាដែលដាក់ទៅតុលាការអនុវត្ត ជាទូទៅជាសេចក្ដីសម្រេចស្ថាពរ (មាត្រា១៩៣ និងមាត្រា១៩៤) ឬត្រូវបានប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន (មាត្រា១៩៦) ដោយមិនតម្រូវឲ្យភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះទេ។

### តើដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ(មាត្រា៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មានអានុភាពដល់ពេលណា បើសាលក្រមនៃបណ្ដឹងតវ៉ារបស់តតិយត្រូវបានចេញ ប៉ុន្តែមិនទាន់បានចូលជាស្ថាពរ?

បញ្ហានេះត្រូវដោះស្រាយតាម មាត្រា៣៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ អំពីបណ្ដឹងតវ៉ាចំពោះការទាមទារ បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត

ឬបណ្តឹងតវ៉ារបស់តតិយជន តុលាការដែលទទួលពាក្យបណ្តឹងអាចបង្គាប់ឲ្យធ្វើការចាត់ចែង ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារជាអាទិ៍) នៃក្រមនេះ ឬអាចលុបចោល ឬផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួច ហើយតាមបញ្ញត្តិនៃទី១ ឬកថាខណ្ឌទី២នោះបាន។ ការសម្រេចសេចក្តីនេះត្រូវមានអានុភាពចាប់ពីថ្ងៃដែលសាលក្រម ឬសាលដីកាចុងក្រោយអំពីបណ្តឹងដែលបានកំណត់នៅក្នុងមាត្រាខាងលើនេះត្រូវបានប្រកាស។

ដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ (មាត្រា៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ត្រូវបាត់បង់អានុភាពនៅពេលដែលតុលាការចេញសាលក្រម នៃបណ្តឹងតតវ៉ារបស់តតិយជនជាហេតុនាំឲ្យការអនុវត្តដោយបង្ខំត្រូវបានផ្អាកអាចចាប់ផ្តើមអនុវត្តដោយបង្ខំឡើងវិញ មុនពេលដែលសាលក្រមនៃបណ្តឹងតវ៉ារបស់តតិយជនចូលជាស្ថាពរ ហេតុនេះដើម្បីរារាំងនូវបញ្ហានេះ មាត្រា៣៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិថា "តុលាការអាចបង្គាប់ឲ្យធ្វើការចាត់ចែងអំពីដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ"។ មានន័យថា នៅក្នុងសេចក្តីសម្រេចរបស់តុលាការក្រៅអំពីការសម្រេចទៅលើខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារឲ្យតុលា-ការចេញ តុលាការត្រូវសម្រេចបន្ថែម ដែលមានខ្លឹមសារថា (១)ទទួលស្គាល់ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ ឬ(២)ផ្លាស់ប្តូរដីកាសម្រេចបង្គាប់ឲ្យអនុវត្តដោយបង្ខំ ឬ(៣)លុបចោលដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ។ សេចក្តីសម្រេចបន្ថែមនេះមានអានុភាពអនុវត្តភ្លាមៗ បន្ទាប់ពីតុលាការប្រកាសសាលក្រម។

ឧទាហរណ៍ ៖ តុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទនៃបណ្តឹងតវ៉ារបស់តតិយជន ហេតុនេះតុលាការត្រូវចេញសេចក្តីសម្រេចដូចខាងក្រោម៖

១.ការអនុវត្តដោយបង្ខំដែលធ្វើឡើង ដោយចុងចម្លើយដោយផ្អែកលើអនុសារៈសាលក្រម ដែលភ្ជាប់មកជាមួយរូបមន្តអនុវត្ត ចំពោះទ្រព្យសម្បត្តិដែលបានរៀបរាប់នៅក្នុងបញ្ជីទ្រព្យសម្បត្តិ (សំណុំរឿងលេខ............ចុះថ្ងៃទីខែឆ្នាំ របស់តុលាការ........) មិនត្រូវបានអនុញ្ញាត។

២.ទទួលស្គាល់ដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ

ជាធម្មតា សេចក្តីសម្រេចទី១ មានអានុភាពអនុវត្ត លុះត្រាតែសាលក្រមចូលជាស្ថាពរ ប៉ុន្តែសេចក្តីសម្រេចទី២មានអានុភាពអនុវត្តភ្លាមៗ នៅពេលសាលក្រមត្រូវបានប្រកាស នេះជាចំណុចពិសេស នៃសេចក្តីសម្រេចដែលទាក់ទងនឹងបណ្តឹងតវ៉ារបស់តតិយជន។ ក្នុងករណីនេះ ទោះបីជាមានឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អំពីសេចក្តីសម្រេចនេះក៏ដោយ

ការផ្អាកការអនុវត្តដោយបង្ខំ តាមរយៈដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំនៅតែបន្ត។ ប៉ុន្តែដើម្បីឲ្យតុលាការអនុវត្តបន្តផ្អាកការអនុវត្តដោយបង្ខំតាមខ្លឹមសារនៃសេចក្តីសម្រេចខាងលើភាគីឈ្នះក្តីត្រូវផ្ញើសេចក្តីសម្រេចនោះទៅតុលាការអនុវត្ត។

ឧទាហរណ៍៖ C បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ A ទៅសាលាដំបូងរាជធានីភ្នំពេញ និងបានដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ។ តុលាការបានចេញដីកាសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំ។ C បានដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត ហើយតុលាការអនុវត្តផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ បន្ទាប់ពីនោះ C បានឈ្នះបណ្តឹងតវ៉ារបស់តតិយជន។ ក្នុងករណីនេះសាលាដំបូងរាជធានីភ្នំពេញត្រូវចេញដីកាសម្រេចទទួលស្គាល់ "ឲ្យផ្អាកការអនុវត្តជាបណ្តោះអាសន្នចំពោះរឿងក្តីលេខ.... ចុះថ្ងៃទីខែឆ្នាំរបស់ឈ្មោះតុលាការ" នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម។ ពេលដែល C បានដាក់សាលក្រមនេះទៅតុលាការអនុវត្ត តុលាការអនុវត្តនឹងបន្តផ្អាកការអនុវត្តដោយបង្ខំ។

ផ្ទុយទៅវិញ ប្រសិនបើបណ្តឹងតវ៉ារបស់តតិយជនមិនទទួលបានជោគជ័យ តុលាការនឹងចេញសាលក្រមដែលមានខ្លឹមសារ ដូចខាងក្រោមនេះ ៖

**១.អនុញ្ញាតឲ្យអនុវត្តដោយបង្ខំ**

**២.លុបចោលដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ**

**៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ**

ឧទាហរណ៍៖ C បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនចំពោះ A ទៅសាលាដំបូងរាជធានីភ្នំពេញ និងដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ។ តុលាការបានចេញដីកាសម្រេចបង្គាប់ឲ្យផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ C បានដាក់ដីកាសម្រេចនេះទៅតុលាការអនុវត្ត ហើយតុលាការអនុវត្តផ្អាកជាបណ្តោះអាសន្ននៃការអនុវត្តដោយបង្ខំ។ បន្ទាប់មក C បានចាញ់ក្តីក្នុងបណ្តឹងតវ៉ារបស់តតិយជន។ ក្នុងករណីនេះ សាលាដំបូងរាជធានីភ្នំពេញត្រូវបង្គាប់ "លុបចោលដីកាសម្រេចផ្អាកការអនុវត្តជាបណ្តោះអាសន្ននៃរឿងក្តីអនុវត្តដោយបង្ខំលេខ.... ចុះថ្ងៃទីខែឆ្នាំរបស់ឈ្មោះតុលាការ" នៅក្នុងសេចក្តីសម្រេចបញ្ចប់។ នៅពេល A ដាក់សាលក្រមនេះទៅតុលាការអនុវត្ត តុលាការអនុវត្តត្រូវបន្តការអនុវត្តដោយបង្ខំ។

សាលក្រមនៃបណ្តឹងតវ៉ារបស់តតិយជន ជាសាលក្រមដែលមានគោលបំណងរំលត់អានុភាពអនុវត្តនៃការអនុវត្តជាក់លាក់ នៅក្នុងទំនាក់ទំនងលើកម្មវត្ថុជាក់លាក់ ដោយធ្វើការផ្លាស់ប្តូរទំនាក់ទំនងគតិយុត្តនៃច្បាប់នីតិវិធី ហេតុនេះសាលក្រមនៃបណ្តឹងតវ៉ារបស់តតិយជនជាសាលក្រមនៃការបង្កើត កែប្រែ រំលត់ទំនាក់ទំនងគតិយុត្ត។ ប៉ុន្តែមិនមែនជាសាលក្រមនៃ

ការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទនោះទេ ពីព្រោះខ្លឹមសារនៃសេចក្តីសម្រេចបញ្ជាប់ គឺមិនបានទទួលស្គាល់ ឬមិនទទួលស្គាល់សិទ្ធិរបស់ដើមចោទ ឬបដិសេធសិទ្ធិរបស់ចុងចម្លើយនោះទេ ប៉ុន្តែធ្វើការវិនិច្ឆ័យថាតើការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលនៃការអនុវត្តមានលក្ខណៈត្រឹមត្រូវឬទេ ថាតើជាទ្រព្យសម្បត្តិរបស់កូនបំណុល? ថាតើគប្បីអនុញ្ញាតសម្រេចសិទ្ធិរបស់ម្ចាស់បំណុលឬទេ បើការពិតទ្រព្យសម្បត្តិនោះជារបស់តតិយជនជាអាទិ៍។

## ៥. សេចក្តីសន្និដ្ឋាន

បណ្តឹងតវ៉ារបស់តតិយជនអាចត្រូវបានធ្វើឡើងប្រឆាំងនឹងការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារ ប្រសិនបើការអនុវត្តនោះបានធ្វើឲ្យខូចផលប្រយោជន៍របស់តតិយជន ដែលមានលក្ខណៈមិនសមរម្យ និងមិនត្រឹមត្រូវតាមច្បាប់ក្នុងការអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្តសម្រេចសិទ្ធិរបស់ខ្លួន នៅក្នុងទំនាក់ទំនងធៀបនឹងតតិយជន។ តតិយជនអាចធ្វើបណ្តឹងនេះជោគជ័យលុះត្រាតែមានមូលហេតុបី ទី១៖ តតិយជនអាចរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយអះអាងអំពីកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត។ ទី២៖ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់តតិយជនអាចតតាំងនឹងការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្ត និងទី៣៖ អត្ថិភាពនៃការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារដែលបានប៉ះពាល់ដល់កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតរបស់តតិយជន។

នៅពេលបណ្តឹងតវ៉ារបស់តតិយជនត្រូវបានដំណើរការ គឺអនុវត្តនីតិវិធីដូចបណ្តឹងរដ្ឋប្បវេណីទូទៅ ដោយតុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ ការប្រកាសសាលក្រម និងការចេញសាលក្រម ហេតុនេះបណ្តឹងតវ៉ារបស់តតិយជននៅពេលដាក់ ក៏បង់ប្រាក់ប្រដាប់ក្តីផងដែរ ប៉ុន្តែការបង់ពន្ធដាក់ពាក្យសុំ គឺ១/២ នៃការបង់ពន្ធដាក់ពាក្យសុំនៃបណ្តឹងធម្មតា ប្រសិនបើអះអាងអំពីកម្មសិទ្ធិ។ ប៉ុន្តែ បើអះអាងអំពីសិទ្ធិផ្សេងទៀត គឺ ១/៣ នៃការបង់ពន្ធដាក់ពាក្យសុំនៃបណ្តឹងធម្មតា។ ប្រសិនបើតម្លៃកម្មវត្ថុនៃការអនុវត្តដោយបង្ខំមានទំហំច្រើនជាងសិទ្ធិរបស់តតិយជន តម្លៃមូលដ្ឋាននៃការគណនាពន្ធដាក់ពាក្យសុំ គឺតម្លៃនៃផលប្រយោជន៍របស់តតិយជន។

បណ្តឹងនេះ តតិយជនអាចដាក់ទៅស្ថាប័នអនុវត្តដែលទទួលបន្ទុកអនុវត្តនូវវត្ថុដែលជាកម្មវត្ថុមានទំនាក់ទំនងផលប្រយោជន៍របស់តតិយជន ដោយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ការអនុវត្តដោយបង្ខំមិនត្រូវបានអនុញ្ញាត។ នៅពេលបណ្តឹងនេះត្រូវ

បានដាក់នីតិវិធីអនុវត្តដោយបង្ខំមិនត្រូវបានផ្អាក ឬលុបចោលដោយស្វ័យប្រវត្តិនោះទេ ហេតុនេះ តតិយជនត្រូវដាក់ពាក្យសុំផ្អាក ឬលុបចោលការអនុវត្តហើយប្រសិនបើតុលាការចេញដីកាសម្រេចផ្អាកការអនុវត្តជាអាទិ៍ ទើបការអនុវត្តដោយបង្ខំត្រូវបានផ្អាកមួយរយៈ រហូតដល់ពេលមានការសម្រេចជាថ្មី។ នៅក្នុងសាលក្រមនៃបណ្ដឹងតវ៉ារបស់តតិយជនមានលក្ខណៈពិសេសខុសពីសាលក្រមទូទៅ ប្រសិនបើតុលាការទទួលស្គាល់បណ្ដឹងតវ៉ារបស់តតិយជន តុលាការនឹងសម្រេចចំនួន ០៣ (បី) ចំណុចចម្បង ដែលមានខ្លឹមសារថា ទី១ ការអនុវត្តដោយបង្ខំមិនត្រូវបានអនុញ្ញាត ទី២ ទទួលស្គាល់ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ និងទី៣ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ៕

# ព្រហ្មទណ្ឌ

# គោលការណ៍សន្មត់ថាមិនមានទោស

**(Presumption of Innocence)**

**ដោយលោកមេធាវី មាស ប៉ូរ៉ា***

## ១. សេចក្តីផ្តើម

មានអង្គហេតុមួយដែលប៉ូលីសបានឃាត់ខ្លួនជនសង្ស័យពីបទប្លន់ រួចថតរូបផ្សាយតាមទូរទស្សន៍ជាមួយសេចក្តីថ្លែងការណ៍ថា ជននោះជាឃាតករ។ សាធារណជនមួយចំនួនបានចែករំលែករូបថតជនសង្ស័យតាមប្រព័ន្ធបណ្តាញសង្គម Facebook។ បន្ថែមពីលើនេះពិធីករទូរស្សន៍បានធ្វើបទអត្ថាធិប្បាយអះអាង ជួនកាលបំផ្លើសថាជននោះពិតជាឃាតករ។ ចៅក្រមសម្រេចសេចក្តីអាចនឹងទទួលសម្ពាធពីសារព័ត៌មានទាំងនេះ។ អង្គហេតុនៅមានបន្តទៀត ក៏ប៉ុន្តែតើការធ្វើយ៉ាងនេះធ្វើឲ្យឧក្រិដ្ឋជនរាងចាលឬទេ? វាអាចដូចនេះ ក៏ប៉ុន្តែវាអាចមានវិធានការសមស្របប្រកបដោយការថ្លឹងថ្លែងផ្សេងទៀតដែលមិននាំឲ្យមានផលអវិជ្ជមាន និងនាំឲ្យជនប្រព្រឹត្តមានការរាងចាល។

អត្ថបទនេះនឹងលើកយកគោលការណ៍ពាក់ព័ន្ធមួយ គឺ "ការសន្មត់ទុកថាមិនមានទោសដរាបណាមិនទាន់មានសាលក្រមជាស្ថាពរ"។ គោលការណ៍នេះមានចែងក្នុងច្បាប់ធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ក៏ប៉ុន្តែមិនមានការស្រាវជ្រាវអំពីខ្លឹមសារ និងការដឹងលឺជាទូទៅទេ។ ជាមួយនឹងការបង្ហាញអំពីវិសាលភាពព្រមទាំងអង្គហេតុដែលអាចនាំឲ្យប៉ះពាល់ដល់គោលការណ៍នេះ អត្ថបទនឹងធ្វើការបង្ហាញអំពីផលវិបាកនៃអំពើខាងផ្លូវច្បាប់ និងសង្គមមុននឹងធ្វើសេចក្តីសង្ខេបរួម និងអនុសាសន៍ប្រសិនបើមាន។

## ២. ខ្លឹមសារ

មុននឹងលម្អិត សូមពិនិត្យមាត្រាចំនួន២ ដែលពាក់ព័ន្ធ៖ "*ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបាន*

---

* អ្នកនិពន្ធជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។ អរគុណ និស្សិត **ហ៊ុន ស៊ាងហាក់** ដែលបានជួយពិនិត្យមើលអក្ខរាវិរុទ្ធ ក្នុងអត្ថបទនេះ។

*កំណត់ស្របតាមច្បាប់"។*[1] *មាត្រា៣៨៖ "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។*[2]

មាត្រា១៤ ប្រើពាក្យ "ជនជាប់ចោទ" "ក្នុងរឿងព្រហ្មទណ្ឌ" និង"ច្បាប់"។ នេះខុសពីមាត្រា៣៨ ដែលមិនបានរំលេចនូវពាក្យ "ព្រហ្មទណ្ឌ"។ មាត្រា៣៨ សំដៅលើការកាត់ទោសដោយតុលាការ ទោះបីជាមិនបានចែងថា តុលាការធម្មតា ឬរាប់ចូលតុលាការយោធា។ ការយោងទៅដល់ស្ថាប័ននេះខុសពីមាត្រា១៤ ដែលអះអាងអំពីការកាត់ទោសតាមច្បាប់ដោយមិនយោងដល់ស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យសេចក្តី។ "ច្បាប់" ក្នុងន័យនេះទំនងរាប់បញ្ចូលច្បាប់បង្កើតឡើងដោយសភា ក្នុងប្រទេសស៊ីវិលឡ និងច្បាប់ ដែលបង្កើតដោយចៅក្រម ក្នុងប្រទេសកុំម៉ុនឡ។[3] ច្បាប់ទំនងសំដៅលើច្បាប់ ដែលត្រូវបានធ្វើឡើង តាមនីតិវិធីត្រឹមត្រូវ និងមានខ្លឹមសារស្របតាមវិធានអន្តរជាតិផងដែរ។ មាត្រាទាំងពីរបានប្រើពាក្យ "ជនជាប់ចោទ" ដែលតាមន័យច្បាប់កម្ពុជា ជនដែលត្រូវបានដាក់ក្រោមការពិនិត្យ (accused/put under judicial investigation) រួចហើយ។[4] ប្រសិនបើជាដូចនេះមែន គោលការណ៍សន្មត់ជាមុននេះនឹងមិនអនុវត្តចំពោះជនសង្ស័យទេ។ ក្នុងន័យនេះគេអាចផ្សព្វផ្សាយរូបភាពជនសង្ស័យដោយមិនខ្វល់អំពីគោលការណ៍នេះ។ ក៏ប៉ុន្តែការបកស្រាយចង្អៀតអាចនាំឲ្យមានការអនុវត្តច្បាប់ ឬគោលការណ៍មិនស្មើភាពគ្នារវាងជនសង្ស័យ និងជនត្រូវចោទ។ ខ្លឹមសារនៃមាត្រា ១៤ និង៣៨ អាចទូលាយ ឬចង្អៀត ឬផ្ទុយគ្នា។ អាស្រ័យហេតុនេះវិធីបកស្រាយមួយដ៏សមស្របគឺការបកស្រាយតាមគោលបំណងនៃច្បាប់ ដើម្បីបញ្ចៀសនូវលទ្ធផលផ្ទុយគ្នា។ មាត្រានៃកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយចែងនូវសិទ្ធិ និងធានានូវសិទ្ធិដល់ជនគ្រប់រូបដោយគ្មានរើសអើង។[5] ដូចនេះគោលការណ៍នេះក៏នឹងត្រូវអនុវត្តសម្រាប់ការពារជនសង្ស័យ និងជនត្រូវចោទផងដែរ។

---

[1] Everyone charged with a criminal offence shall have the right to be presumed innocent until proved guilty according to law, Article 14 of the International Covenant on Civil and Political Rights, ICCPR, UN, Treaty Series, Vol. 999, p. 171.

[2] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣។

[3] តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក, យោបល់លេខ OC6/86 ចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ ១៩៨៦ ស្តីពី ពាក្យ "ច្បាប់" ក្នុងមាត្រា ៣០ នៃ អនុសញ្ញាអាមេរិក ស្តីពី សិទ្ធិមនុស្ស, កថាខណ្ឌទី ២០ និង ២១។

[4] សន្ធានុក្រម ទំព័រ ១ ឧបសម្ព័ន្ធនៃវិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ រកបាននៅ https://www.eccc.gov.kh/en/document/legal/internal-rules-rev9

[5] មាត្រា ២, ICCPR, *supra* note 1.

## ២.១. អង្គហេតុ ដែលនាំឲ្យរំលោភគោលការណ៍នេះ

**ក. ការឃុំខ្លួន៖** តាមគោលការណ៍សន្មត់ថាមានសេរីភាព (presumption of liberty) ទោះបីជា កម្រិតភស្តុតាងអនុវត្តសម្រាប់ការឃុំខ្លួនមានកម្រិតទាបក្តី ក៏ប៉ុន្តែការឃុំខ្លួនត្រូវតែចាំបាច់ និងត្រូវបង្ហាញថា ជនដែលត្រូវឃុំខ្លួនបានប្រព្រឹត្តបទល្មើស។[6] ការឃុំខ្លួនមានគោលបំណងរក្សាទុកឲ្យជនត្រូវចោទ ចូលខ្លួនមកក្នុងនីតិវិធីតុលាការ។ ប្រសិនបើមានយន្តការអាចធានាបានថាជននោះនឹងមកចូលរួមក្នុងដំណើរការនីតិវិធី តើចាំបាច់ត្រូវឃុំខ្លួនជនត្រូវចោទធ្វើអ្វីទៅ? ក្នុងន័យរក្សាភាពចាំបាច់នៃការឃុំខ្លួន ច្បាប់ និងយុត្តិសាស្ត្រ បានចែងតម្រូវឲ្យតុលាការពិនិត្យមើលជាទៀងទាត់ ថាតើមូលដ្ឋានសម្រាប់ការឃុំខ្លួនលែងមានឬនៅ? ក្នុងយុត្តិសាស្ត្រ *A v. Australia* គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានរកឃើញថា ប្រទេសអូស្ត្រាលី បានបំពានមាត្រា ៩ ស្តីពីការឃុំខ្លួន ដោយសារតុលាការមិនបានត្រួតពិនិត្យជាទៀងទាត់អំពីមូលដ្ឋាននៃការឃុំខ្លួន។[7] នេះដើម្បីកុំឲ្យការឃុំខ្លួនយូរ និងមិនសមហេតុផល។

ច្បាប់ព្រមទាំងសេចក្តីណែនាំបានចែងអំពីលក្ខខ័ណ្ឌនៃការឃុំខ្លួន ដូចជា៖ ការឃុំខ្លួនអនីតិជន ដាច់ដោយឡែកពីមនុស្សពេញវ័យ[8] ជនសង្ស័យនៅដោយឡែកពីពិរុទ្ធជន[9] ជនជាប់ឃុំឃាំងទទួលបានអាហារគ្រប់គ្រាន់ និងលំហាត់ប្រាណព្រមទាំងការទទួលការសួរសុខទុក្ខពីគ្រួសារ[10]ជាដើម។ បន្ថែមពីលើនេះ សំលៀកបំពាក់ពិរុទ្ធជន និងជនសង្ស័យត្រូវខុសគ្នា។[11] នេះជាវិធាន ហើយអ្នកសិក្សាស្រាវជ្រាវគួរកត់សំគាល់ថាការបំពានវិធានទាំងនេះមាន

---

6 *"ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់"*, មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧។

7 គ្រប់សេចក្តីសម្រេចឃុំខ្លួន ត្រូវទទួលបានការពិនិត្យឡើងវិញជាទៀងទាត់ (កថាខណ្ឌទី ៩.៤)។ ការពិនិត្យមើលភាពស្របច្បាប់នៃការឃុំឃាំង ដែលអាចនាំដល់ការដោះលែង មិនកម្រិតត្រឹមតែ ថាការឃុំឃាំងខុសនឹង ឬត្រូវច្បាប់ប៉ុណ្ណោះទេ។ ដោយសារការបន្តឃុំខ្លួន មិនចាំបាច់ទៀត គណៈកម្មាធិការ រកឃើញថា ការបន្តឃុំខ្លួនលោក *A* ដោយអាជ្ញាធរអូស្ត្រាលី ខុសនឹងមាត្រា ៩ នៃកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយឆ្នាំ ១៩៦៦ (កថាខណ្ឌទី ៩.៥)។

8 មាត្រា ១០ (២.ខ), ICCPR, *supra* note 1។ ច្បាប់ពន្ធនាគារកម្ពុជា ឆ្នាំ ២០១១, មាត្រា ២១។

9 មាត្រា ១០ (២.ក), ICCPR, *supra* note 1។ច្បាប់ពន្ធនាគារកម្ពុជា ឆ្នាំ ២០១១, មាត្រា ២៦។

10 គោលការណ៍ សម្រាប់ការពារបុគ្គលទាំងអស់ស្ថិតក្រោមទម្រង់ណាមួយនៃការឃុំខ្លួន ឬជាប់ពន្ធនាគារ ឆ្នាំ១៩៨៨, គោលការណ៍ទី១៩ អនុម័តដោយ General Assembly Resolution No 43/173 of 9 December 1988។ ច្បាប់ពន្ធនាគារកម្ពុជា ឆ្នាំ២០១១, មាត្រា ២៨។

11 Standard Minimum Rules for the Treatment of Prisoners, Economic and Social Council, Resolution 207 (LXII) of 13 May 1977, វិធាន ៨៨ (២) ។

លក្ខណៈមិនធ្ងន់ធ្ងរ នឹងមិនខុសសិទ្ធិមនុស្សទេ ប្រសិនបើមានហេតុផលឆ្លើយតបសមស្រប (យុត្តិកម្ម)។ ឧទាហរណ៍ បានដាក់ខ្នោះជនសង្ស័យដើម្បីជានាសន្តិសុខ។

ការបំពានខាងលើ អាចមិនមានហេតុផលក្នុងករណីទង្វើរបស់អាជ្ញាធរបានបង្ហាញអំពីភាពមិនខ្វល់ខ្វាយចំពោះការឃុំឃាំង ក្នុងអំឡុងពេលយូរ ឬឆាប់ ហើយការប្រព្រឹត្តលើជនជាប់ឃុំឃាំង មានលក្ខណៈអមនុស្សធម៌ ប្រៀបដូចជាការឃុំឃាំងសត្វ ឬដែលជាក់ស្តែងហាក់ទំនងឲ្យគេឃើញថាការប្រព្រឹត្តលើជននោះ ដូចជាជនមានទោស(presumed guilt) រួចទៅហើយ។ នេះទំនងជាមានការបំពានគោលការណ៍សន្មត់ថាមិនទាន់មានទោស។ ផ្អែកលើអង្គហេតុថាជនជាប់ឃុំមានសំលៀកបំពាក់ផ្ទាល់ខ្លួន ដែលអាចពាក់ជំនួសបានតែអាជ្ញាធរបង្ខំឲ្យពាក់សំលៀកបំពាក់សម្រាប់ពិរុទ្ធជនមកចូលរួមក្នុងសវនាការតុលាការ សិទ្ធិមនុស្សបានអះអាងថានេះបង្ហាញនូវចំណាប់អារម្មណ៍ ថាជនសង្ស័យមានទោសរួចទៅហើយ។ តុលាការបានសម្រេចថាមានការរំលោភមាត្រា ៦ នៃអនុសញ្ញា អឺរ៉ុប ស្តីពីសិទ្ធិមនុស្ស (គោលការណ៍សន្មត់មិនមានទោស)។

> *"..ពាក់ព័ន្ធនឹងការបង្ហាញខ្លួនរបស់អ្នកប្តឹង (ជនជាប់ចោទ) នៅមុខតុលាការក្នុងឯកសណ្ឋានជាទណ្ឌិត វាមានភាពច្បាស់លាស់ថា មានការបដិសេធរបស់ប្រធានសាលាឧទ្ធរណ៍ឲ្យអ្នកប្តឹងពាក់សំលៀកបំពាក់ផ្ទាល់ខ្លួន.... ដោយសារខ្វះភស្តុតាងបង្ហាញថា អ្នកប្តឹងមិនមានសំលៀកបំពាក់សមស្របផ្ទាល់ខ្លួន ការបដិសេធនេះ មិនមានហេតុផល និងទំនងជាធ្វើឲ្យសាធារណៈជនយល់ថា អ្នកប្តឹងមានទោសរួចទៅហើយ"។*[12]

**ខ. បន្ទុកនៃភស្តុតាង៖** តាមវិធានជាទូទៅ ជនដែលផ្តើមសកម្មភាពចោទជាអ្នកមានបន្ទុកដាក់ភស្តុតាង(burden of proof)[13]។ នេះគឺដៅលើរដ្ឋអាជ្ញា ឬព្រះរាជអាជ្ញាដែលជាអាជ្ញាធរកសាងសុំណុំរឿង និងចោទប្រកាន់។ ការតម្រូវដូចនេះជារឿងសត្យានុម័តហើយពិតជាត្រឹមត្រូវក្នុងដំណើរការក្តីព្រហ្មទណ្ឌ។ វាជាការមិនសមស្របទេ ដែលដាក់បន្ទុកដល់ជនត្រូវចោទឲ្យបង្ហាញភស្តុតាងថាខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចបានចោទ។ ដោយមិននិយាយដល់កម្រិតភស្តុតាង (standard of proof) ដែលជនត្រូវចោទត្រូវបំពេញ ការទាមទារឲ្យដាក់ភ័ស្តុតាងពិតជាមិនអាចទៅរួចទេ ពីព្រោះករណីខ្លះជនត្រូវចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំង ឬផ្សេងពីនេះគ្មានលទ្ធភាព ឬអំណាចក្នុងការរក និងទទួលភស្តុតាងទេ។ ជាក់ស្តែងក្នុងករណីបទរំលោភសេពសន្ថវៈ

[12] Human Rights Case Digest, Martinus Nijhoff Publishers, 18 HRCD [2007-2008], p. 668.

[13] សូមមើលអត្ថបទ ដោយ មាស បូរ៉ា ស្តីពី កម្រិតនិងបន្ទុកភស្តុតាង ក្នុងរឿងព្រហ្មទណ្ឌ, https://www.measboralaws.com/books-magazines/magazine/criminal-law

ដែលមានតែជនសង្ស័យ និងជនរងគ្រោះតែពីរនាក់។ តើគាត់អាចបង្ហាញភស្តុតាងដោះបន្ទុកដោយរបៀបណាបាន?

រដ្ឋអាជ្ញាត្រូវបង្ហាញភស្តុតាងក្នុងកម្រិតហួសពីវិមតិសង្ស័យ ប្រសិនបើមិនចង់ឲ្យមានការបំពានគោលការណ៍សន្មត់ទុកជាមុននេះ។ ព្រះរាជអាជ្ញាត្រូវបង្ហាញដោយជម្រះអស់មន្ទិលថាជនត្រូវចោទមិនបានប្រព្រឹត្តបទល្មើសទេ ដើម្បីឲ្យចៅក្រមសម្រេចរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាព។ ការតម្រូវឲ្យជនត្រូវចោទរកភស្តុតាងអះអាងថាមិនបានប្រព្រឹត្តបទល្មើសនឹងនាំឲ្យមានការរំលោភគោលការណ៍នេះហើយ។

**គ. សេចក្ដីថ្លែងការណ៍ដោយអាជ្ញាធរ៖** វិសាលភាពដើមនៃគោលការណ៍នេះ អនុវត្តចំពោះតែមន្ត្រីអនុវត្តច្បាប់ដូចជាប៉ូលីស។ ឧទាហរណ៍ក្នុងករណី ឃាត់ខ្លួនជនសង្ស័យរួចហើយ ប៉ូលីសធ្វើសន្និសីទកាសែតបញ្ជាក់យ៉ាងច្បាស់ថា ជនសង្ស័យពិតជាបានប្រព្រឹត្ត ឬហៅជនសង្ស័យថា "ជាឃាតករ" ជាដើម។ ក្នុងករណី ដែលអាជ្ញាធរគ្រាន់តែបង្ហាញព័ត៌មានធម្មតាប្រាប់សាធារណជន អំពីបច្ចុប្បន្នភាពនៃការស៊ើបអង្កេត នឹងមិនខុសនឹងគោលការណ៍នេះទេ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថាមេប៉ូលីស និងរដ្ឋអាជ្ញាដែលមានអំណាចនិងឥទ្ធិពលបាននិយាយក្នុងសារព័ត៌មាន ថាជនត្រូវចោទពិតជាបានប្រព្រឹត្តអំពើពុករលួយហើយសន្និដ្ឋានថា សេចក្ដីថ្លែងការណ៍នេះខុស នឹងគោលការណ៍សន្មត់ថាមិនទាន់មានទោស។

> *"តុលាការបានអះអាងថាសំដីរបស់រដ្ឋអាជ្ញាហាក់បង្ហាញច្បាស់ថាជនត្រូវចោទមានទោសក្នុងបទញុះញង់ឲ្យសាក្សីភូតកុហកលើកទឹកចិត្ត ឲ្យសាធារណជនពិចារណាថាពួកគេមានទោស វិនិច្ឆ័យសេចក្ដីជាមុន មុនការពិនិត្យអង្គហេតុដោយតុលាការមានសមត្ថកិច្ច"*។[14]

**ឃ. ការអត្ថាធិប្បាយរបស់ប្រព័ន្ធផ្សព្វផ្សាយ៖** ក្នុងន័យដើម សិទ្ធិមនុស្ស ចែងអំពីទំនាក់ទំនង រវាងអាជ្ញាធររដ្ឋ និង ប្រជាជន។[15] ប្រជាជនមានសិទ្ធិ ហើយរដ្ឋមានកាតព្វកិច្ចគោរពសិទ្ធិទាំងនោះ។ ប្រជាពលរដ្ឋ ជាជនរងគ្រោះនៃការបំពានសិទ្ធិដោយអាជ្ញាធរ។ ក៏ប៉ុន្តែឆ្លើយតបនឹងការអភិវឌ្ឍសង្គម ជនស៊ីវិល ឬនីតិបុគ្គល (ប្រព័ន្ធផ្សព្វផ្សាយ) អាចជាជនរងគ្រោះ ឬអ្នកបំពាន

---

[14] Human Rights Case Digest, Martinus Nijhoff Publishers, 18 HRCD [2007-2008], p. 668.

[15] Jurjen van Pelt, Obligations of the state concerning the human rights of citizens and non-citizens in Thomas Hobbes and John Locke (thesis), p. 20, https://dspace.library. uu.nl/bitstream/ handle/1874/40226 /Scriptie%20JvPelt.pdf?...

សិទ្ធិ[16]។ រដ្ឋត្រូវអន្តរាគមន៍ក្នុងករណីចុងក្រោយនេះ ផ្អែកតាមទ្រឹស្តី នៃកាតព្វកិច្ចវិជ្ជមាន (positive obligation)[17] និងការពារសិទ្ធិប្រជាពលរដ្ឋ តាមទ្រឹស្តីខ្លួនមានកាតព្វកិច្ចក្នុងកិច្ចសន្យាសង្គម (social contract)។[18]

នៅក្នុងផ្សារទំនើបមួយចំនួនមានផ្ទាំងបិទរូបថតរបស់មនុស្សចំណាស់ ឬក្មេងទាំងប្រុសទាំងស្រីដែលត្រូវបានចាប់ ដោយសារពួកគេបានលួចទំនិញក្នុងហាងដែលជួនកាលចំនួនបន្តិចបន្តួច និងមានតម្លៃថោក។រូបថតទាំងនោះត្រូវបានបិទនិងតាំងនៅដោយគ្មានពេលវេលាកំណត់មិនរំលងនូវភ្នែកសាធារណជន។

ប្រព័ន្ធផ្សព្វផ្សាយអាចដកស្រង់ខ្លឹមសារព័ត៌មានផ្តល់ដោយប៉ូលីស ឬផ្សព្វផ្សាយរូបភាពបង្ហាញថា ជនត្រូវបានឃាត់ខ្លួនមានទោសរួចទៅហើយ ឬធ្វើបទអត្ថាធិប្បាយថាជននោះមានទោស។ សាធារណជនបានចែករំលែកព័ត៌មាននេះបន្តដោយមិនបានពិចារណាថាព័ត៌មានខុស ឬបំពានសិទ្ធិអ្នកដទៃឡើយ។ នេះនាំឲ្យមានឥទ្ធិពលលើតុលាការក្នុងការសម្រេចក្តីនាពេលខាងមុខ។ អង្គហេតុទាំងពីរនេះដែលជាទង្វើរបស់នីតិបុគ្គល អាចនាំឲ្យមានការបំពានគោលការណ៍សន្ទត់ជាមុនថាគ្មានទោសផងដែរ។

### ២.២. កំណត់សំគាល់ ស្តីពី ផលវិបាក

អង្គហេតុខាងលើសុទ្ធតែអាចបង្កផលវិបាក។ ទោះបីជាយ៉ាងនេះក្តី ផ្នែកនេះលើកយកតែអង្គហេតុដែលត្រូវបានបន្តចែករំលែកតាមប្រព័ន្ធ Facebook និងលទ្ធភាព នៃការប៉ះដល់គោលការណ៍សន្ទត់ជាមុនថាគ្មានទោស។

ក្រុមមនុស្សបានឃាត់ខ្លួនបុគ្គលម្នាក់ដោយសារមូលហេតុថា គាត់ជាចោរលួចព្រមទាំងបានវាយគាត់ឲ្យមានរបួសទៀតផង។ ម្ចាស់គណនីបានធ្វើបទអត្ថាធិប្បាយច្បាស់ថា "ជនដែលត្រូវឃាត់ពិតជាចោរលួចមែន"។ ព័ត៌មានត្រូវបានចែករំលែកភ្លាមៗ។ មានអ្នកចូលមើលគណនី

[16] P.H.P.H.M.C. van Kempen, *Human Rights and Criminal Justice Applied to Legal Persons, Protection and Liability of Private and Public Juristic Entities under the ICCPR, ECHR, ACHR and AfChHPR*, 14 (3) Electronic Journal of Comparative Law, 2 (December 2010), http://www.ejcl.org.

[17] Jean-Francois Akandji-Kombe, កាតព្វកិច្ចវិជ្ជមាន ក្រោមអនុសញ្ញាអឺរ៉ុប ស្តីពី សិទ្ធិមនុស្ស, Human Rights Handbook No.7, 2007. Johannes van Aggelen, the Obligations Imposed by the International Covenants and Other Universal Human Rights Treaties, Including the Implementation by Domestic Court, *Ius Gentium.* Curitiba, vol. 8, n. 2, p. 333-361, jul./dez. 2017, para.10.

[18] Jean-Jacques Rousseau, the Social Contract, new text, 2010.

Facebook នោះរាប់ពាន់នាក់ដែលក្នុងនោះអាចមានបងប្អូនរបស់ជនសង្ស័យ ឬអ្នកជិតខាងរបស់គាត់ផងដែរ។

អត្ថបទនេះ សូមទុកបញ្ហានៃការព្រួតវាយជនសង្ស័យ ដោយក្រុមមនុស្សសម្រាប់ពិភាក្សានាពេលក្រោយ ដោយសារវាពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នករួមព្រួតវាយ។ ក្នុងរឿងនេះ យើងសន្មត់ថា ការលួចពិតជាកើតឡើងមែន។ ទោះបីវាមានការពិបាកក្នុងការទទួលថាស្គាល់ នូវសិទ្ធិជីវិតឯកជនរបស់ចោរ ក៏ប៉ុន្តែតាមទ្រឹស្តីនៃការដកហូតសិទ្ធិសេរីភាព ឬគោលការណ៍សមមាត្រ (principle of proportionate) វាទាមទារឲ្យមានវិធានការចាំបាច់ និងឆ្លើយតបដើម្បីសម្រេចគោលបំណងបំបាត់អំពើចោរកម្ម។ តើប៉ូលីស ប្រព័ន្ធផ្សព្វផ្សាយ ឬសាធារណជន ថតរូបជនសង្ស័យផ្សាយតាមទូរទស្សន៍ ឬFacebook ពិតជាធ្វើឲ្យចោររាងចាលឬទេ? តើមានមធ្យោបាយផ្សេងពីនេះដែលគោលបំណងនេះ នឹងសម្រេចហើយសិទ្ធិរបស់ជនសង្ស័យមិនត្រូវបានប៉ះពាល់ធ្ងន់ធ្ងរដែរឬទេ? ច្បាប់មិនបានចែងថា ជនល្មើសត្រូវតែប្រព្រឹត្តលើដូចសត្វធាតុនោះទេ។ ច្បាប់សិទ្ធិមនុស្សចែងផ្តល់សិទ្ធិទទួលបានការប្រព្រឹត្តដោយមនុស្សធម៌ និងសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌សូម្បីឧក្រិដ្ឋជន[19]។

វាអាចមានករណីដែលជននោះមិនបានប្រព្រឹត្ត ឬអាចនិយាយថា សាក្សីច្រឡំអត្តសញ្ញាណជនសង្ស័យ (mistaken eyewitness identification)។ នេះនាំឲ្យមានការកាត់ទោសមនុស្សស្លូតត្រង់ ហើយជនល្មើសពិតប្រាកដបានរួចខ្លួន។ វាពិតជាកើតមានហើយការកំណត់អត្តសញ្ញាណខុសជាមូលហេតុចម្បងដែលនាំឲ្យកើតមាន។[20]

មានឃាតកម្មមួយកើតមានឡើង ហើយប៉ូលីសបានឃាត់ខ្លួនយុវជនម្នាក់ដែលនៅក្បែរកន្លែងកើតហេតុ ដោយសារមានស្នាមប្រឡាប់ឈាម នៅលើអាវរបស់គាត់។ ត្រូវឬក៏ខុស វាអាស្រ័យលើភស្តុតាង។ ក៏ប៉ុន្តែវាអាចមានករណីថា ឈាមនោះមិនមែនជាឈាមរបស់ជនរងគ្រោះ ឬជាឈាមរបស់ជនរងគ្រោះប្រឡាក់លើអាវរបស់ឃាតករហើយឃាតករបានរត់មកប៉ះបុគ្គលនោះ។

ដោយសារតែសាធារណជនយល់ថា ជនសង្ស័យពិតជាឃាតករ តុលាការអាចសម្រេចថាជាឃាតករមែន។ ក្នុងករណីនេះតុលាការខ្លាចមានការរិះគន់សម្រេចមិនដោះលែងជននោះ។

[19] មាត្រា ១៤, ICCPR, *supra* note 1.

[20] Leverick, F., and Chalmers, J., *Causes of Wrongful Conviction*, *in* Chalmers, J., et al ed., Post-Corroboration Safeguards Review Report of the Academic Expert Group, 2014, p.33; Seri Irazola, Ph.D, Study of Victim Experiences of Wrongful Conviction, 2013, p.25.

តុលាការធ្វើការដោយអព្យាក្រឹត្យ និងវិជ្ជាជីវៈបានរកឃើញថាជនត្រូវឃាត់ខ្លួនមិនមែនជាឃាតករ ហើយសម្រេចដោះលែង។ តើអ្វីជាលទ្ធផល? គេអាចចាត់ទុកថា តុលាការពុករលួយ ឬបាត់បង់ជំនឿចិត្តលើតុលាការ។ ក្នុងករណីនេះ វាជារឿងអយុត្តិធម៌សម្រាប់តុលាការ។ ជនជាប់ចោទត្រូវបានដោះលែង ដោយសារកំហុសមិនត្រូវបានរកឃើញត្រូវអ្នកជិតខាងរើសអើងបងប្អូនអាចស្តីបន្ទោស។ នេះមិនគិតទាំងស្នាមរបួស ប្រាក់សម្រាប់ព្យាបាល ឬការខាតបង់ចំណូលនៅពេលខ្លួនត្រូវបានឃុំឃាំងដោយតុលាការទៀតផង។ ជាលទ្ធផល រដ្ឋត្រូវបានបង្ខំឲ្យសងជំងឺចិត្តដល់ជនស្លូតត្រង់ក្នុងករណីដែលតុលាការបានកាត់ទោសច្រឡំ។[21]

នេះហើយជាផលវិបាក។នេះហើយជាហេតុផលនៃវត្តមាននៃគោលការណ៍សន្មត់ជាមុនថាមិនមានទោស ក្នុងគោលបំណងដើម្បីឲ្យសាធារណជន និងតុលាការប្រព្រឹត្តឲ្យបានសមស្របព្រះរាជអាជ្ញាត្រូវខិតខំរកភស្តុតាងបំពេញបន្ទុករបស់ខ្លួនដើម្បីបង្ការកុំឲ្យអង្ករក្លាយជាបាយខ្លោចដែលហូបលែងបាន។

បន្ថែមពីលើផលវិបាកខាងលើ អង្គហេតុខាងលើ ក៏អាចបង្ហាញពីការបំពានសិទ្ធិជីវិតឯកជនផងដែរ។ តាមរយៈការវាយដំ ការឃុំខ្លួន វាអាចនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬក្រៅកិច្ចសន្យា ដោយសារការបំពារបំពានទាំងនោះមិនមានហេតុផល ឬលើសពីភាពចាំបាច់ និងមិនមានការអនុញ្ញាតដោយច្បាប់។ ការទទួលខុសត្រូវនេះពិតជាកើតមានរួចហើយ។ ក្នុងសំណុំរឿងអ្នកសារព័ត៌មាន គូសថ្លុកបង្ហាញការគាំទ្រសាទរដល់ពួកភេរវកម្មដែលបន្ទុះយន្តហោះលើអគារពាណិជ្ជកម្មសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០១ តុលាការបារាំងបានកាត់ទោសដាក់ពិន័យដល់អ្នកកាសែត និងម្ចាស់កាសែតដោយសារទង្វើរបស់គាត់ហួសព្រំដែននៃសេរីភាពបញ្ចេញមតិបំពារបំពានសិទ្ធិ និងបង្កចលាចលក្នុងសង្គម។[22]

ការបំពានគោលការណ៍នេះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ និងមិនមានទោសទណ្ឌទេ។ ក៏ប៉ុន្តែវាអាចជាការបំពានសិទ្ធិមនុស្ស។ តុលាការអាចរកឃើញ និងផ្តល់សំណងធម្មតាដល់ជនរងគ្រោះ ដូចក្នុងករណីការបំពានច្បាប់ព្រហ្មទណ្ឌដែរ។ ក្នុងន័យនេះ ការការពារសិទ្ធិមនុស្សជាការបំពេញបន្ថែមនូវចន្លោះខ្វះខាតក្នុងច្បាប់ព្រហ្មទណ្ឌ ហើយដែលធ្វើឲ្យអាជ្ញាធរ ឬ

---

[21] Benjamin N. Cardozo School of Law, An Innocence Project Report, Making Up for Lost Time: What the Wrong fully Convicted Endure and How to Provide Fair Compensation, ទំព័រ ៣។

[22] IRIS Themes, Freedom of Expression, and the Media and Journalists: Case-Law of the European Court of Human Rights, (European Court of Human Rights: Case of Leroy v. France), Vol. III, 2013, p. 210.

ជនបំពានសិទ្ធិរាងចាល ព្រមទាំងកែសម្រួលទង្វើខុសឆ្គងកុំឲ្យមាននាពេលអនាគត។ នេះជាដំណើរទៅរកយុត្តិធម៌សង្គមនាំឲ្យមានសន្តិភាពវិជ្ជមានពេញលេញ (positive peace)។

## ៣. សង្ខេប

ជាសរុប គោលការណ៍សន្មត់ថាមិនទាន់មានទោស ចែងផ្តល់នូវការការពារដល់ជនសង្ស័យ ក៏ដូចជាជនត្រូវចោទ។ គោលការណ៍នេះមានទំនាក់ទំនងនឹងសិទ្ធិ ព្រមទាំងនីតិវិធីតុលាការដែលតម្រូវឲ្យគោរពប្រសិនបើមិនដូចនេះទេទាំងគោលការណ៍ និងសិទ្ធិនឹងត្រូវបានរកឃើញថាមានការបំពាន។ ក្នុងករណីធ្ងន់ធ្ងរ ជនរងគ្រោះក៏អាចនឹងប្តឹងទាមទារសំណងផងដែរ។

# ការបដិសេធភស្តុតាង៖ ករណីការថតសម្លេងតាមទូរស័ព្ទ

បទអត្ថាធិប្បាយលើសាលក្រម សំណុំរឿង ៣៣៦/២០០៥ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០៥ និងលេខ ៤៦៣/២០០៥ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូលប្រទេស អេស្ប៉ាញ (ផ្នែកព្រហ្មទណ្ឌ)

ដោយលោកចៅក្រម Michael BOHLANDER[23] ក្នុងទស្សនាវដ្ដី ច្បាប់ព្រហ្មទណ្ឌ (Journal of Criminal Law) ភាគ ៧០ (៣) ឆ្នាំ ២០០៦

**បកប្រែដោយបណ្ឌិត មាស ប៉ូវ៉ា ដោយមានការអនុញ្ញាតពីលោកចៅក្រម Michael BOHLANDER**

នៅក្នុងសំណុំរឿងទាំងពីរនេះ តុលាការបានពិចារណានូវដីកាអនុញ្ញាតឲ្យថតសម្លេងទូរស័ព្ទចេញដោយចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងទាក់ទិននឹងការចោទប្រកាន់អំពីបទល្មើសថ្នាំញៀនធ្ងន់ធ្ងរ។ ក្នុងនីតិវិធីមួយនៃដំណើរការនៃនីតិវិធីចំនួនហេរ៉ូអ៊ីន ១៦ គីឡូក្រាម ត្រូវបានជួញដូរដែលជាចំនួនដ៏ច្រើនចរាចរក្នុងទីផ្សារ។ ក្នុងករណីទាំងពីរនេះ ភស្តុតាងចោទប្រកាន់មួយចំនួនភ្ជាប់ជនត្រូវចោទនឹងបទល្មើសជាចម្បងបានមកពី ការថតសម្លេងឆ្លងឆ្លើយតាមទូរស័ព្ទផ្អែកតាមដីកាអនុញ្ញាត។ តុលាការវិនិច្ឆ័យក្នុងរឿងទាំងពីរ បានប្រើប្រាស់ភស្តុតាងទាំងនេះដើម្បីកាត់ទោស និងដាក់ពន្ធនាគាររយៈពេលយូរ។ ជនល្មើសបានប្ដឹងសារទុក្ខទៅតុលាការកំពូល ដោយអះអាងថា ដីកាបំពានសិទ្ធិជីវិតឯកជនដែលជាលទ្ធផលការដាក់ទោសនេះបំពានគោលការណ៍សន្មត់ថាមិនទាន់មានទោស (presumption of innocence) ដោយសារតុលាការផ្អែកលើភស្តុតាងដែលមិនអាចទទួលយកបាន(inadmissible evidence) ហើយប្រសិនបើគ្មានភស្តុតាងនេះវានឹងមិនមានការចោទប្រកាន់ទេ (no case to answer)។ តុលាការកំពូលបានសម្រេចលុបចោលការផ្ដន្ទាទោសទាំងពីរ ដោយគ្មានតម្រូវឲ្យមានការកាត់សេចក្ដីជាថ្មី៖ ដីកាមិនមានភាពជាក់លាក់ និងហាក់ទំនងជាគ្រាន់តែសម្រាប់ប្រថាប់ត្រាដល់ប្រតិបត្តិការរបស់ប៉ូលីស។ ក្នុងសំណុំរឿងលេខ ៤៦៣/២០០៥ តុលាការ អះអាងក្នុងចំណុចលេខ ៤ ជាផ្នែកនៃការវាយតម្លៃអង្គច្បាប់នៃសំណុំរឿងថា៖ *ជាការអនុវត្ត ផ្អែកតាមចរិតការិយាធិបតេយ្យដីកានេះគ្រាន់តែជា ការប្រថាប់ត្រាលើសំណុំរឿងប៉ូលីស ដោយគ្រាន់តែសរសេរប្រាប់ថា (អនុវត្តទៅ!)*។

---

[23] លោកចៅក្រម Michael BOHLANDER ជាសហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ទោះបីជាទទួលស្គាល់យ៉ាងជាក់លាក់ថា ប៉ូលីសបានប្រតិបត្តិការងារប្រកបដោយវិជ្ជាជីវៈ និង សុទ្ធចិត្តក៏ដោយ ក៏ប៉ុន្តែក្នុងការរិះគន់ដល់សហការីជាតុលាការក្នុងអង្គរបស់ខ្លួនថៅក្រមតុលាការកំពូលបានអះអាងថា កិច្ចនោះមិនមែនជាសកម្មភាពស៊ើបអង្កេតរបស់ថៅក្រមស៊ើបអង្កេតទេ។ តុលាការកំពូលប្រើពាក្យជាការមិនគោរព/ប្រមាថ (disgrace ful) និងអះអាងនូវកង្វះភាពសកម្មដ៏អាក្រក់ (lamentable lack of rigour) ក្នុងសំណុំរឿងមួយ ដែលថៅក្រមម្នាក់អសកម្មបំផុត។

## យោបល់

វាជាការពិចារណាដ៏ចម្លែកមួយស្ដីពី ច្បាប់របស់យើង ប្រសិនបើបុគ្គលម្នាក់បានទទួលស្គាល់ការចូលរួមក្នុងការនាំចូលខុសច្បាប់នូវគ្រឿងញៀនហេរ៉ូអ៊ីនក្នុងចំនួនច្រើន ប្រសិនបើពិរុទ្ធភាពត្រូវបានបដិសេធ ផ្អែកតាមមូលដ្ឋានថា សិទ្ធិជីវិតឯកជនរបស់គាត់ត្រូវបានបំពារបំពាន។

សេចក្ដីថ្លែងនេះ ដោយថៅក្រម Lord Nolan ក្នុងសុំរឿងក្នុងសំណុំរឿង *R v Khan* [1996] 1 WLR 162 ត្រង់ទំព័រ ១៧៥ ហាក់តំណាងនូវជំហរទូទៅ ក្នុងចំណោមថៅក្រមព្រហ្មទណ្ឌរបស់អង់គ្លេសពាក់ព័ន្ធនឹងសំណួរថាតើភស្តុតាងទទួលបានតាមមធ្យោបាយមិនសមស្រប ឬមិនស្របច្បាប់ គួរត្រូវបានទទួលយក ឬបដិសេធនាពេលសវនាការ...។

វិធីសាស្ត្រនេះ(ឲ្យរួចខ្លួន) នាំឲ្យមានភាពភ័យខ្លាចរបស់ពលរដ្ឋជាច្រើនព្រមទាំងមេធាវីក្នុងចំណោមប្រជាជន ដោយសារមានអារម្មណ៍ថា ឧក្រិដ្ឋជននឹងមានសេរីភាព ដោយសារមន្ត្រីបានធ្វេសប្រហែស (constable has blundered)។ នេះប្រសិនបើប្រើប្រាស់នូវសេចក្ដីថ្លែងការណ៍ដ៏ពេញនិយមលើកឡើងដោយថៅក្រម Cardozo ក្នុងឆ្នាំ ១៩៦២ ក្នុងសំណុំរឿង *People v Defore* 242 NY 13 ក្នុងទំព័រ ២១ (...ប្រជាជនស្រដៀងនេះភាគច្រើន នឹងសម្ដែងនូវសេចក្ដីប្រាថ្នាយ៉ាងខ្លាំង ដើម្បីការពារនូវសិទ្ធិរបស់ពួកគេនាពេលដែលពួកគេខ្លួនឯងកំពុងទទួលរងនូវផលវិបាក នៃការកាត់ទោសផ្អែកតាមភស្តុតាងប្រភេទនេះ)។ អារម្មណ៍ព្រួយថា ឧក្រិដ្ឋជនអាចរួចខ្លួនវាមានពិតប្រាកដជាពិសេសក្នុងករណីបទល្មើសធ្ងន់ធ្ងរ ដូចជារំលោភសេពសន្ថវៈ ឬមនុស្សឃាត។ ក្នុងរឿងក្ដី *Leon* តុលាការកំពូលសហរដ្ឋអាមេរិកអះអាងថា វិធានបដិសេធភស្តុតាង (exclusionary rule) ចែងក្នុងវិសោធនកម្មទី៤ នឹងមិនអនុវត្តចំពោះករណីភស្តុតាងទទួលបានដោយសមហេតុផល និងជាសត្យានុម័តផ្អែកលើដីកាឆែកឆេរ ដែលក្រោយមកដីកានេះត្រូវបានមោឃៈភាពទេ (468 US at 922, 104 SCt at 3420)។ ក្នុងរឿងក្ដី Moore 956 F2d843 សាលាឧទ្ធរណ៍អាមេរិកCircuit ទី៨ បានពន្យល់ថា តម្លៃខ្ពស់សង្គមនៃវិធានបដិសេធ

នាំឲ្យឧក្រិដ្ឋជនមានសេរីភាព ដោយសារមន្ត្រីបានធ្វេសប្រហែស។ ចៅក្រម Cardozo បានថ្លែងទាមទារមិនឲ្យអនុវត្តវិធាន ចំពោះស្ថានភាពដែលមន្ត្រីបានធ្វើការងារដោយហ្មត់ចត់។ ដូចនេះដរាបណាប៉ូលីស ឬរដ្ឋអាជ្ញាធ្វើការងារដោយសុទ្ធចិត្តកំហុសបន្ទាប់មក ឬទង្វើខុសច្បាប់ ដែលអាចកើតមានដោយមន្ត្រីតុលាការក្នុងការផ្តល់នូវដីកាឆែកឆេរ ឬដីកាស្រដៀងគ្នាជ្រៀតជ្រែកដល់សិទ្ធិឯកជននោះ វាមិនមែនជាវិធានទេ ដែលភស្តុតាងនឹងត្រូវបដិសេធដោយតុលាការ។ ជាការពិត ការលើកលែងដោយមូលហេតុសុទ្ធចិត្ត (good faith exception) គឺទទួលយកបានក្នុងទម្រង់ចំបង ប្រសិនបើវិធានបដិសេធជាវិធីសាស្ត្រដាក់ពិន័យ ។ ដូចនេះ វាមិនមានអត្ថន័យទេ ដែលដាក់ពិន័យលើប៉ូលីសខណៈដែលពួកគេមិនបានប្រព្រឹត្តកំហុស។ ក៏ប៉ុន្តែបញ្ហាអាចត្រូវបានមើលឃើញខុសគ្នាបន្តិចពីជ្រុងផ្សេងៗ ដោយសារថា សកម្មភាពកាត់ទោសទាំងអស់ចេញមកពីអំណាចរដ្ឋហើយរដ្ឋមិនមានសិទ្ធិលើកសំអាងសុទ្ធចិត្តភាព នៅពេលដែលរដ្ឋបំពានសិទ្ធិជីវិតឯកជនរបស់ពលរដ្ឋខ្លួនឡើយ។ នេះដោយសាររដ្ឋមានកាតព្វកិច្ច គោរពសិទ្ធិប្រជាពលរដ្ឋក្នុងលក្ខណៈជាការទទួលខុសត្រូវតឹងរឹង (strict liability)។ គេត្រូវទទួលស្គាល់ថា ការអះអាងនេះមិនបានឆ្លើយតបនឹងសំណួរបន្ទាប់ថា តើអ្វីទៅជាជាផលវិបាកអាចកើតមានបន្ទាប់ពីមានការរំលោភសិទ្ធិ និងថាតើការបដិសេធភស្តុតាង វាជាវិធីសាស្ត្រល្អបំផុត ក្នុងគ្រប់កាលៈទេសៈដែរឬទេ?។

វិធីសាស្ត្រនេះ (បដិសេធភស្តុតាង) មិនមានក្នុងប្រព័ន្ធច្បាប់ទាំងអស់ទេ។ ជាពិសេសប្រទេសដែលធ្លាប់ឆ្លងកាត់រយៈពេលនៃរបបផ្តាច់ការនិយម ឬការបង្ក្រាបគាំទ្រដោយរដ្ឋ នឹងមានភាពទោមនស្ស ចំពោះភាពមិនអាចបំពានបាននៃសិទ្ធិស៊ីវិលឬសិទ្ធិចម្បង។ ប្រទេសអេស្ប៉ាញក្រោយពីងើបចេញពីការគ្រប់គ្រងដោយលោក ហ្វ្រង់ ស៊ីស្កូ ហ្វ្រង់កូ (Francisco Franco) នៃប្រទេសទាំងឡាយដែលដាក់តម្លៃសង្គមខ្ពស់ លើសិទ្ធិស៊ីវិល សូម្បីតម្រូវឲ្យមានការដោះលែងឧក្រិដ្ឋជនឲ្យរួចខ្លួនក្តី។ ករណីទាំងពីរសម្រេចដោយតុលាការកំពូល ផ្អែកជាស៊ីសង្វាក់តាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញអេស្ប៉ាញ បានបង្ហាញនូវផលវិបាកនៃវិធីសាស្ត្រនេះ។ វិធីសាស្ត្រនេះ ទំនងទទួលឥទ្ធិពលខ្លាំងពីយុត្តិសាស្ត្រតុលាការធម្មនុញ្ញសហព័ន្ធអាឡឺម៉ង់ ក៏ប៉ុន្តែតុលាការអេស្ប៉ាញហាក់មានជំហរ រ៉ាឌីកាល់(radical) ជាងក្នុងការអនុវត្តគោលការណ៍នេះ។ ជំហរប្រកាន់យកដោយតុលាការកំពូលរបស់អេស្ប៉ាញ ទទួលបាននូវការសរសើរក្នុងពេលដែលការការពារសិទ្ធិចំបងតាមផ្លូវតុលាការមិនមានតម្លៃខ្ពស់ក្នុងសង្គមដោយសារភាពចាំបាច់នៃសង្គ្រាមប្រឆាំងភេរវកម្ម ដែលអំណាចប្រតិបត្តិមាន អំណាចទូលំទូលាយ។ ការសរសើរនេះ មានជា

ពិសេសដោយពិចារណាលើអង្គហេតុថា អេស្ប៉ាញ បានទទួលរងនូវការវាយប្រហារភេរវកម្មធំក្រោយ ថ្ងៃទី១១ ខែកញ្ញា ហើយសាលក្រមត្រូវបានចេញក្រោយពីមានព្រឹត្តិការណ៍(ភេរវកម្ម) ក្នុងទីក្រុងម៉ាទ្រីត។

ខ្លឹមសារសង្ខេបនៃការយល់ឃើញរបស់តុលាការក្នុងរឿងទាំងនេះ បានបង្ហាញថា ការខកខានត្រួតពិនិត្យតាមផ្លូវតុលាការ ប្រកបដោយប្រសិទ្ធភាពលើវិធានការកម្រិតសិទ្ធិបុគ្គលមានអត្ថន័យក្នុងធម្មនុញ្ញ ហើយការខកខាននេះត្រូវតែនាំឲ្យមាននូវមោឃកម្មនៃវិធានការ។ ធាតុផ្សំចំបង នៃការត្រួតពិនិត្យ គឺការពិនិត្យថាតើវិធានការ វាមានភាពចាំបាច់ ហើយការចាត់ចែងភស្តុតាង ត្រូវតែផ្អែកតាមវិធានទាំងនោះ ឬយ៉ាងណា។ ធាតុផ្សំទាំងនេះនៅបន្តមានរហូតក្នុងអំឡុងពេលទាំងស្រុងនៃវិធានការនោះ។ វាមិនគ្រាន់តែយោងឡើងវិញនៅក្នុងដីកាដែលមានហេតុផលគ្រប់គ្រាន់ ដើម្បីអនុម័តនូវវិធានការ ឬមិនគ្រប់គ្រាន់ទេក្នុងការយោងដល់ឯកសាររបស់ប៉ូលីស (ទោះបីការយោងដល់ឯកសារតុលាការកម្រិតត្រឹមការអនុញ្ញាត) ក៏ប៉ុន្តែមូលដ្ឋាននៃការវាយតម្លៃនេះត្រូវតែចែងយ៉ាងច្បាស់លាស់ និងជាក់លាក់ក្នុងសំអាងហេតុនៃចៅក្រម។

គោលការណ៍ សមាមាត្រនៃច្បាប់រដ្ឋធម្មនុញ្ញតម្រូវឲ្យចៅក្រមពិចារណាដោយហ្មត់ចត់ថាតើការចោទប្រកាន់តម្រូវនូវវិធានការជ្រៀតជ្រែក ដូចនោះ ដូចជាការថតសំឡេងសន្ទនាតាមទូរស័ព្ទព្រមទាំងថាតើ វិធីសាស្ត្រនៃការស៊ើបអង្កេតដទៃទៀត មិនអាចធ្វើទៅបានឬ?។ ការពិចារណាត្រូវបានពន្យល់ផងដែរនូវមូលហេតុនៃការចេញដីកា។ វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា តុលាការកំពូលកំណត់នូវភាពជាក់លាក់យ៉ាងច្បាស់រវាងអង្គហេតុដែលបានចោទ និងមូលដ្ឋានភស្តុតាងសម្រាប់ការចោទប្រកាន់។ ទោះបីមានការបរិយាយលម្អិតនូវសកម្មភាពដែលបានចោទលើជនសង្ស័យ វានឹងមិនទាន់គ្រប់គ្រាន់ទេ ប្រសិនបើតុលាការមិនបានកំណត់ជាក់លាក់នូវការយល់ឃើញថា មានការសង្ស័យសមស្របប្រឆាំងនឹងជនសង្ស័យ ផ្អែកតាមភស្តុតាងផ្តល់ក្នុងពាក្យសុំរបស់ប៉ូលីស។ តុលាការបាននិយាយយ៉ាងច្បាស់ថា ការកំណត់ចោទប្រកាន់មិនអាចជាយុត្តិកម្មសម្រាប់វាយតម្លៃថាមានសំណុំរឿងគ្រប់គ្រាន់ប្រឆាំងនឹងជនសង្ស័យថាគាត់បានប្រព្រឹត្ត នូវសកម្មភាពចោទនោះទេ។ ការធ្វើដូចនេះ នាំឲ្យធ្លាក់ចូលក្នុងអន្ទាក់នៃអំណះអំណាងដដែលៗ (circular argument)។ ជាមួយនឹងការប្រើប្រាស់ពាក្យដាច់ខាតបន្តិចចៅក្រមតុលាការកំពូលបានយោងជាក់លាក់ដល់ការប្រើពាក្យញុះញង់ (magic trigger words) ដូចជា "*ក្រុមមានការចាត់តាំង*" "*ជួញដូរគ្រឿងញៀនក្នុងទម្រង់ធំ*" "*បញ្ជីថ្កោលទោសពី*

*មុន" "ទំនាក់ទំនង"* ជាដើម នៅក្នុងពាក្យសុំ និងបទបញ្ជាអនុញ្ញាតជាធាតុផ្សំដែលធ្វើឲ្យពាក្យសុំត្រូវបានចាត់ថាមានហេតុផល។ ដោយគ្មានការពិចារណាឬត់ចត់នូវភស្តុតាងផ្តល់ជូន ដោយប៉ូលីស វាមានន័យថា វាជាការផ្ទេរអំណាចតុលាការពិតមួយទៅដល់ប៉ូលីស។

តុលាការកំពូលសង្កត់ធ្ងន់ថា ការពិចារណាណាមួយលើពាក្យសុំ សម្រាប់វិធានការជ្រៀតជ្រែក ត្រូវតែផ្អែក តាមទស្សនៈជាមុន (*ex-ante* view) នៃភស្តុតាងផ្តល់ជូន។ ដើម្បីផ្តល់យុត្តិកម្មដល់វិធានការ ដែលអនុវត្តប្រតិសកម្ម ក្រោយពីភាពជោគជ័យនៃការស៊ើបអង្កេត វាមានន័យថា ជាការផ្អាកការអនុវត្តដ៏មានប្រសិទ្ធភាព នូវមាត្រា ១១(១) នៃច្បាប់ Ley Organica Del Poder Judicial ច្បាប់ស្តីពីអង្គតុលាការ ដែលបានចែងថា ភស្តុតាងណាមួយ ទទួលបានដោយបំពានសិទ្ធិសេរីភាពចំបង ទោះបីដោយផ្ទាល់ ឬប្រយោលក្តី នឹងមិនទទួលយកឡើយ។ ប្រសិនមិនត្រូវបានលុបបំបាត់ទេ វានឹងកម្រិតយ៉ាងធ្ងន់ធ្ងរនូវការការពារក្រោមមាត្រា២៤ នៃច្បាប់ធម្មនុញ្ញ អេស្ប៉ាញ ដែលធានានូវសិទ្ធិត្រួតពិនិត្យ ដោយតុលាការមានប្រសិទ្ធភាព ទៅលើទង្វើរបស់រដ្ឋ។

វាតម្រូវឲ្យមានការចងចាំថា ការពិនិត្យជាមុន ជាការទាមទារដោយច្បាប់រដ្ឋធម្មនុញ្ញដែលថា សកម្មភាពណាមួយរបស់រដ្ឋ ហើយជាពិសេសវិធានការបំពារបំពានត្រូវតែអនុលោមតាមគោលការណ៍សមាមាត្រ (តុលាការអេស្ប៉ាញប្រើនិយមន័យសមាមាត្រ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញសហព័ន្ធអាឡឺម៉ង់)៖ វិធានការទាមទារ៖ ទី១. សមត្ថភាពនៃការបង្កើតនូវផលវិបាកដែលចង់បាន។ ទី២. វាចាំបាច់ ដោយសារថា មិនមានវិធីដែលបំពារបំពានតិចតួចអាចធ្វើបានដែលបង្កើតបានផលវិបាកដូចគ្នា និងទី ៣ បើទោះបី ចំណុចទី១ និង ទី២ ត្រូវបានបំពេញការបំពារបំពាន ដោយមានបំណងត្រូវតែសមាមាត្រនឹងផលប្រយោជន៍ទទួលបានពីវិធានការដែលពេលខ្លះអាចត្រូវបានចាត់ថា "*សមាមាត្រក្នុងន័យចង្អៀត*"។ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញ អេស្ប៉ាញ លក្ខខណ្ឌទាំងនេះត្រូវតែមានក្នុងគ្រប់ដំណាក់កាលនៃវិធានការ ហើយនេះត្រូវតែបានពិនិត្យ នៅពេលពិចារណា ការដាក់ចេញវិធានការអនុវត្តថ្មី។

តុលាការដដែលបានប្រើប្រាស់នូវទ្រឹស្តី ការបំពុលជាក់ច្បាស់(unequivocal contamination) ហើយតុលាការបានពិនិត្យថា តើមានភស្តុតាងសេសសល់ទទួលបានផ្អែកតាមភស្តុតាងទទួលបានតាមរយៈការថតសម្លេងទូរស័ព្ទ និងថាតើការដាក់ទោសអាចរក្សាទុកដោយគ្មានភស្តុតាងប្រភេទក្រោយនេះទេ។ ការអនុវត្តតាមទ្រឹស្តីនេះតុលាការកំពូលបានប្រកាសថា ការដាក់ទោសនេះធ្វើឡើងដោយផ្អែកទាំងស្រុងលើភស្តុតាងបំពុល ហើយបាន

បដិសេធការដាក់ទោស ព្រមទាំងបានបញ្ជាឲ្យដោះលែងជនត្រូវចោទទាំងអស់។ តុលាការមិនបានពិចារណាជាក់លាក់ថាវាចាំបាច់ក្នុងការពិភាក្សាហេតុផលផ្សេងៗទៀត មានក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ដែលអះអាងដល់តម្លៃខ្ពស់ដល់ការការពារសិទ្ធិចម្បងក្នុងទ្រឹស្តីច្បាប់អេស្ប៉ាញទេ។ វាជារឿងថ្មីក្នុងការប្រកាន់យកនូវជំហរដ៏ជាក់លាក់ ឲ្យប្រយោជន៍ដល់សិទ្ធិ និងសេរីភាពចម្បង ផ្ទុយនឹងតម្លៃដទៃទៀតដែលត្រូវបានបង្ហាញព្រមទាំងការធ្វើតុល្យភាពនូវតម្លៃកំពុងកើតមានក្នុងនយោបាយសម័យទំនើប។ បុគ្គលអាចមានការងឿងឆ្ងល់ថាតើរហូតដល់ពេលណាដែលប្រព័ន្ធតុលាការអេស្ប៉ាញនឹងអាចឈរជើងទល់នឹងសំពាធនៃការភ័យខ្លាច នៃការបំពានអំណាចនេះ។

<u>សេចក្តីសម្រេចទាំងស្រុងអាចរកមាននៅ គេហទំព័ររបស់តុលាការ www.poderjudicial.es.</u>

# មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ

ដោយលោកមេធាវី ទៀង វុទ្ធា*

## ១–សេចក្តីផ្តើម

ការលើកយកប្រធានបទ មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ នៃអត្ថបទនេះ គឺសំដៅទៅលើការកំណត់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌដែលព្រះរាជអាជ្ញាចាំបាច់ត្រូវមានមូលដ្ឋានក្នុងការកំណត់បទល្មើស ឬធាតុផ្សំបទល្មើសនូវការអនុវត្តតាមបញ្ញត្តិច្បាប់ក្នុងដំណើរការនីតិវិធីនៅចំពោះមុខយុត្តាធិការស៊ើបសួរ, យុត្តាធិការជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌ ក៏ដូចជាការអនុវត្តនូវវិធានទាំងឡាយនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

ប្រទេសនីមួយៗចាំបាច់ត្រូវមានច្បាប់ ច្បាប់បានដើរតួនាទីយ៉ាងសំខាន់ ក្នុងសង្គមមនុស្ស មានចំណងទាក់ទងទាំងទិដ្ឋភាពនយោបាយ និងទិដ្ឋភាពសង្គមក្នុងការគ្រប់គ្រងរដ្ឋ។ ដើម្បីការពារផលប្រយោជន៍ សិទ្ធិសេរីភាព ក៏ដូចជាការសម្រុះសម្រួលវណ្ណៈដល់សាធារណៈជនទូទៅនៃសង្គមជាតិទាំងមូល ស្របតាមឆន្ទៈរបស់ច្បាប់ ច្បាប់ការពារដល់ពួកគេ ក៏ដូចជាការបង្ក្រាបបទល្មើសផ្សេងៗ ដែលជនគ្រប់រូបត្រូវការយុត្តិធម៌ មានតែតុលាការទេដែលប្រកាសទោស និងលើកយកមកអនុវត្តបាន[24] ជាការស្វែងរក ឬផ្តល់យុត្តិធម៌ស្មើៗគ្នាចំពោះមុខច្បាប់ជាសមភាពនៃការទទួលបាននូវសិទ្ធិស្មើៗគ្នាឲ្យការពារច្បាប់ដល់ពួកគេដោយគ្មានការរើសអើងបែងចែក ក្នុងការរកយុត្តិធម៌ដ៏មានប្រសិទ្ធិភាពមួយនៅចំពោះមុខតុលាការមានសមត្ថកិច្ច[25]។

មូលដ្ឋានចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌជាវិធាន ឬបទដ្ឋានគតិយុត្តិដែលបានបញ្ញាត្តិដោយច្បាប់ជាធរមាន ដើម្បីឲ្យស្ថាប័នអយ្យការអនុវត្ត ឬប្រតិបត្តិតាម ។

រឿងក្តីព្រហ្មទណ្ឌគឺមានចរិកលក្ខណៈគតិយុត្តនៃប្រតិកម្មសង្គម គ្រប់សម័យកាលទាំងអស់ការគ្រប់គ្រងប្រទេសនៃរដ្ឋនីមួយៗ កាលណាវិធានច្បាប់ជាមូលដ្ឋាននៃជីវិតសង្គមត្រូវបានរំលោភ សង្គមត្រូវចាត់វិធានការពារខ្លួនស្របតាមព្រំដែនកំណត់នៃវិធានច្បាប់ ឬដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌសន្មត់ហៅថា "រឿងក្តីព្រហ្មទណ្ឌ"។

---

* លោកមេធាវី ទៀង វុទ្ធា ជាប្រធានការិយាល័យនៃនាយកដ្ឋានអធិការកិច្ចនៃគណៈមេធាវី

[24] មាត្រា៦ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[25] មាត្រា៣១រដ្ឋធម្មនុញ្ញ មាត្រា៧ មាត្រ៨សេចក្តីថ្លែងការសកលស្តីពីសិទ្ធិមនុស្ស

សង្គមមានប្រតិកម្មប្រកបដោយគតិបណ្ឌិត ស្របទៅតាមក្របខណ្ឌច្បាប់។ ច្បាប់មានចរិតលក្ខណៈគតិយុត្ត មានឆន្ទៈការការសន្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ទប់ស្កាត់បទល្មើស។

នៅក្នុងស្ថាប័នតុលាការមានអង្គការអយ្យការមួយនៅអមជានិច្ចព្រះរាជអាជ្ញាដើរតួយ៉ាងសំខាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ជាអ្នកធ្វើការចោទប្រកាន់ទៅលើជនទាំងឡាយណាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

## ២ –ខ្លឹមសារ

### ២.១ –អំពីអង្គការអយ្យការ

ដោយសារអង្គការអយ្យការជាស្ថាប័នចោទដ៏សំខាន់នៅក្នុងតុលាការព្រហ្មទណ្ឌ យើងនឹងត្រូវលើកយកមកសិក្សានូវដំណើរការ នៃការប្រព្រឹត្តទៅរបស់សាលាជម្រះក្តីផ្នែកព្រហ្មទណ្ឌនេះ ត្រូវមានស្ថាប័នអយ្យការស្ថិតនៅអមតុលាការគ្រប់ជាន់ថ្នាក់ មានព្រះរាជអាជ្ញា ព្រះរាជ-អាជ្ញារង, អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង, ជាតំណាងអង្គការអយ្យការនៅអមតុលាការគ្រប់ជាន់ថ្នាក់ គឺតុលាការខេត្ត–ក្រុង, តុលាការយោធា, សាលាឧទ្ធរណ៍, តុលាការកំពូលសុទ្ធតែមានស្ថាប័នអយ្យការមួយនៅអមជានិច្ចគឺ៖

- ស្ថាប័នអយ្យការអមសាលាដំបូងនៃតុលាការខេត្ត–ក្រុង៖ ហៅថាអយ្យការថ្នាក់ក្រោម មានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ធ្វើកិច្ចការរបស់ខ្លួនជាតំណាងអយ្យការអមតុលាការនៃសមត្ថកិច្ចដែនដីដែលតុលាការនោះតាំងនៅ[26]។
- ស្ថាប័នអយ្យការអមតុលាការយោធា៖ មានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងជាតំណាងអយ្យការអមតុលាការយោធា មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ស្ថាប័ននេះជាអ្នកកំណត់បទល្មើសដែលមានលក្ខណៈយោធា តាមក្រឹតច្បាប់លេខ០៤ របស់អគ្គស្នងការនយោបាយក្រសួងការពារប្រទេសលេខ១២៧១/៨៤ន.ប ភ្នំពេញថ្ងៃទី២៨.០៨.១៩៨៤ នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលបានកំណត់សញ្ញាណបទល្មើសមានលក្ខណៈយោធា, អំពីបទល្មើស និង ទណ្ឌកម្មក្នុងនោះមានបទល្មើសចំនួន៩គឺៈ –១.ទោសប្រឆាំងនឹងបទបញ្ជាថ្នាក់លើ, –២.បទល្មើសចុះចូលខ្មាំង, –៣.ទោសលួចទិញអាវុធបរិក្ខារសឹក, –៤.ទោសគំរាមកំហែងភ្នាក់ងាររដ្ឋការ, –៥.ទោសឃោសនាបំផ្លិចបំផ្លាញបំបែក

[26] មាត្រា៣៦ក្រមនីតិវិធីព្រហ្មណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និង មាត្រា៤៩ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជាឆ្នាំ១៩៩៣។

បំបាក់កងទ័ព, –៦.ទោសប្រព្រឹត្តអំពើហឹង្សា, –៧.ទោសធ្វើឲ្យបែកបាក់ការសម្ងាត់យោធា ឬធ្វើឲ្យបាត់ឯកសារសម្ងាត់, –៨.ទោសខ្វះស្មារតីទទួលខុសត្រូវ ឬមិនយកចិត្តទុកដាក់ក្នុងការងារដែលបានប្រគល់ បណ្ដាលឲ្យមានផលវិបាកអាក្រក់ និងគ្រោះថ្នាក់ធ្ងន់ធ្ងរ, –៩.ទោសគេចវេះពីបរិចារកិច្ចយោធា។

•ស្ថាប័នអង្គការអយ្យការអមសាលាឧទ្ធរណ៍៖ នៅសាលាឧទ្ធរណ៍មានអង្គការអយ្យការអមសាលាឧទ្ធរណ៍មានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង, ព្រះរាជអាជ្ញាជាតំណាងអង្គ-ការអយ្យការ អមសាលាឧទ្ធរណ៍នោះ[27] បច្ចុប្បន្នមហាអយ្យការអមសាលាឧទ្ធរណ៍មានទីតាំងនៅភ្នំពេញមាន សមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។

សម្គាល់៖ អ្នកច្បាប់បានឲ្យឈ្មោះស្ថាប័នអង្គការអយ្យការអមសាលាឧទ្ធណ៍ជាមហា-អយ្យការអមសាលាឧទ្ធរណ៍ទៅតាមស្ថានភាពជាក់ស្ដែងនៃសមត្ថកិច្ចដែនដី ដោយសន្មត់ថាសមត្ថកិច្ចសាលាឧទ្ធរណ៍លាតសន្ធឹងលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា[28] និងបានកំណត់ទីតាំងតែមួយគត់នៅរាជធានីភ្នំពេញ។ តែក្រោយមកអ្នកច្បាប់បានកំណត់ស្ថាប័នអង្គការអយ្យការមួយដែលជាអ្នកឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍[29] គឺមានន័យថាសាលាឧទ្ធរណ៍អាចនឹងបង្កើតឡើងច្រើនជាងមួយ និង(អាចមានពីរ ឬបី) ទៅតាមស្ថានការអភិវឌ្ឍន៍ជាក់ស្ដែងនៃរបត់សង្គម ហើយក៏អាចបង្កើតឲ្យមានអង្គការអយ្យការអមសាលាឧទ្ធរណ៍ ឬទៅតាមសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នោះតាំងនៅ (គេអាចកំណត់បានថាសាលាឧទ្ធរណ៍តំបន់)។

•មហាអយ្យការអមតុលាការកំពូល៖ នៅតុលាការកំពូលមានមហាអយ្យការអមតុលា-ការកំពូលមួយដែលមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលជាតំណាងនៃអង្គការអយ្យការអមតុលាការកំពូល។

### ២.២– តំណាងអយ្យការ និង តំណាងមហាអយ្យការ

ដូចបានដឹងខាងលើរួចមកហើយថា អង្គការអយ្យការជាស្ថាប័នមួយអមតុលាការគ្រប់-ជាន់ថ្នាក់ និង គ្រប់ខេត្ត–ក្រុង មានតំណាងអយ្យការ ឬ តំណាងមហាអយ្យការមានដូចជា៖

[27] មាត្រា៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និង មាត្រា១៥៦—១៥៩ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ (រដ្ឋកម្ពុជា១៩៩៣)។

[28] មាត្រា១៥៦ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ (រដ្ឋកម្ពុជា១៩៩៣)។

[29] មាត្រា៣៣–៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

- ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងអមសាលាដំបូង។
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញាអមតុលាការកំពូល។

មាន អំណាច និង តួនាទី ដូចខាងក្រោមនេះ ÷

### ក/–តួនាទី និង អំណាចតំណាងអយ្យការអមសាលាដំបូងខេត្ត–ក្រុង

ព្រះរាជអាជ្ញាមានអំណាច និងតួនាទីចោទប្រកាន់នូវរាល់ប្រព្រឹត្តកម្មនៃបទល្មើសព្រហ្មទណ្ឌនានា ក្នុងនាមតំណាងអង្គការអយ្យការជាអ្នកទទួលខុសត្រូវលើការសុំឲ្យអនុវត្តទណ្ឌកម្ម និងធានារ៉ាប់រងសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៅចំពោះមុខតុលាការព្រហ្មណ្ឌ មានន័យថា អង្គការអយ្យការជាអ្នកធានារ៉ាប់រង និងទទួលខុសត្រូវចំពោះធ្វើសេចក្តីសន្និដ្ឋានមួយក្នុងនាមចៅក្រមអយ្យការ[30] ដើម្បីឲ្យតុលាការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌទៅតាមគោលការណ៍ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ។

ដើម្បីធានារ៉ាប់រងកិច្ចការគ្រប់យ៉ាងនូវដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាសេចក្តីសម្រេចខាងព្រហ្មទណ្ឌ[31] ប្រកបដោយយុត្តិធម៌ ស្ថាប័នអង្គការអយ្យការត្រូវប្រតិបត្តិនូវគោលការណ៍ច្បាប់ជាមូលដ្ឋានប្រកបដោយចរិតលក្ខណៈគតិយុត្ត។

ដូចបានដឹងរួចមកហើយថានៅក្នុងអង្គការអយ្យការនីមួយៗមានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងជាតំណាងអយ្យការអមសាលាដំបូងនៃ សមត្ថកិច្ចដែនដីដែលតុលាការតាំងនៅ។ ដំណើរការនីតិវិធី នៃរឿងក្តីព្រហ្មទណ្ឌមួយត្រូវបានធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។

ដោយតំណាងអយ្យការត្រូវសម្អាងភស្តុតាងច្បាស់លាស់ ស៊ីសង្វាក់នឹងសកម្មភាពល្មើសដែលត្រូវធ្វើឲ្យលើសពីវិមតិសង្ស័យ[32] មានន័យថាមិនស្ថិតក្នុងវិមតិសង្ស័យ គឺការបកស្រាយច្បាប់ត្រូវធ្វើឡើងដោយលក្ខណៈតឹងរឹង ត្រូវអនុវត្តតាមតួនាទីទៅតាមសមត្ថកិច្ចដែនដីដែលខ្លួនមាន[33]ជាមូលដ្ឋាន។

ការកំណត់នូវអត្ថិភាពនៃបទល្មើស[34] ក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាខាងបទព្រហ្មទណ្ឌមិនត្រឹមតែកំណត់បទល្មើស ចង្អុលបង្ហាញសកម្មភាពនៃអំពើល្មើសរបស់ជនប្រព្រឹត្ត

---

[30] មាត្រា២៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[31] មាត្រា២៧ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និង មាត្រា១ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[32] មាត្រា១៤ មាត្រា១៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល(អ៊ុនតាក់) , មាត្រា៦០ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា ១៩៩៣, មាត្រា៣៧រដ្ឋធម្មនុញ្ញ (ស្តីពីគោលការណ៍បុរេសន្និដ្ឋានអពិរុទ្ធភាព)។

[33] មាត្រា១៣ កឋាខណ្ឌ២ ចំណុច(១).(២) ច្បាប់ព្រហ្មទណ្ឌUNTAC។

[34] មាត្រា១ មាត្រា៤ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

បទល្មើស(ធាតុផ្សំបទល្មើស) កំណត់ទោស និងនីតិវិធីនៃការអនុវត្តទោស[35] មានលក្ខណៈស៊ីសង្វាក់គ្នានឹងភស្តុតាង ក្នុងការសុំឲ្យអនុវត្តចំពោះមុខយុត្តាធិការស៊ើបសួរ យុត្តាធិការជំនុំជម្រះ និងធ្វើសេចក្តីសន្និដ្ឋានបង្ហាញពីពិរុទ្ធភាពឲតុលាការអនុវត្តតាមច្បាប់[36] តែប៉ុណ្ណោះទេ គឺត្រូវធ្វើសេចក្តីសង្ខេបនៃអង្គហេតុ, កំណត់ឈ្មោះបទល្មើស, បង្ហាញអត្ថបទច្បាប់ដែលកំណត់បទ-ល្មើស, កំណត់ឈ្មោះ ឬអត្តសញ្ញាណ ឬ សាវតាជាតិបុគ្គលដែលត្រូវចោទ[37]។

នៅសាលាដំបូងមាន **ព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង** ជាតំណាងស្ថាប័នអយ្យការអមតុលាការនៃយុត្តាធិការដែនដីនោះ[38] ការិយាល័យនៃអង្គការអយ្យការនីមួយៗត្រូវស្ថិតនៅដោយឡែកពីមុខងារតុលាការ[39] មានកាតព្វកិច្ចអនុវត្តតួនាទីរបស់ខ្លួនក្នុងបណ្តឹងព្រហ្មទណ្ឌ។ ដើម្បីអាចដំណើរការនូវនីតិវិធីនៃការស៊ើបអង្កេត(ស៊ើបសួរ) និងជំនុំជម្រះសេចក្តី បង្ហាញឲ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសនៅតុលាការព្រហ្មទណ្ឌណាមួយ លុះត្រាត្រូវចាប់ផ្តើមចោទដោយព្រះរាជអាជ្ញា ជាអ្នកធ្វើការចោទប្រកាន់ក្នុងនាមតំណាងអយ្យការ[40] ដោយសម្អាងលើមូលដ្ឋានច្បាស់តាមច្បាប់។

ដូច្នេះហើយទើបគេសន្មត់ថាៈ ព្រះរាជអាជ្ញាជាគូ ដើមជានិច្ច[41] ដោយសារតែព្រះរាជ-អាជ្ញាជាអ្នកចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញា សុំអនុវត្តចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ព្រះរាជអាជ្ញាមិនអាចដើរតួជាគូក្តីរណបក្នុងរឿងក្តីព្រហ្មទណ្ឌ ដូចរឿងក្តីរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបានទេ។ អាចនាំឲ្យខូចនីតិវិធី និងធ្វើកិច្ចការណាមួយអាចបណ្តាលឲ្យដោះបន្ទុកដល់ជនត្រូវចោទបាន ជាហេតុថាអាចនាំឲ្យមានការលើកទឹកចិត្តដល់ជនល្មើសហ៊ានប្រព្រឹត្តអំពើល្មើសអ្វីមួយផ្សេងទៀត ក្នុងកំឡុងពេលកំពុងដំណើរការ

[35] មាត្រា១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

[36] មាត្រា៤ មាត្រា២៧ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[37] មាត្រា៤៤ និង មាត្រា៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[38] សូមមើលមាត្រា៣៦ និង មាត្រា២៨៩ (វាក្យខណ្ឌ៥)ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និង មាត្រា៤៩ច្បាប់ស្តីពីនីតិវិធីព្រហ្មណ្ឌរដ្ឋកម្ពុជាឆ្នាំ១៩៩៣ ។

[39] គោលការ១០ ស្តីពីការណែនាំរបស់ព្រះរាជអាជ្ញា បានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ក្រាបបទឧក្រិដ្ឋ និង ការគ្រប់ គ្រងជនល្មើស នៅទីក្រុងហាវ៉ាណាប្រទេសគុយបា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩០។

[40] សូមមើលមាត្រា២ មាត្រា៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[41] សូមមើលមាត្រា៥២ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា ឆ្នាំ១៩៩៣ និង មាត្រា៤ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

នីតិវិធីតាមផ្លូវតុលាការ ជាហេតុអាចនាំឲ្យមានការភ័យខ្លាចដល់ជនរងគ្រោះ និងអាចនាំឲ្យជនរងគ្រោះបាត់ជំនឿចិត្តលើតុលាការមិនហ៊ានបង្ហាញភស្តុតាង និងជូនសាក្សីជាដើម។

**①/ព្រះរាជអាជ្ញារង៖** ប្រើប្រាស់អំណាចទាំងអស់ ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើសស្ថិតក្រោមអំណាចព្រះរាជអាជ្ញា គឺប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន[42]។

**②/អំណាចព្រះរាជអាជ្ញាចំពោះភ្នាក់ងារនគបាលយុត្តិធម៌៖** ព្រះរាជអាជ្ញាមានអំណាចដឹកនាំ សម្របសម្រួលសកម្មភាពមន្ត្រីនគបាលយុត្តិធម៌ ក្នុងសមត្ថកិច្ចដែនដីនៃតុលាការដែលខ្លួនតាំងនៅ ចុះដល់ទីកន្លែងស៊ើបអង្កេត ណែនាំដល់ភ្នាក់ងារមន្ត្រីនគរបាលយុត្តធម៌ក្នុងការស៊ើបអង្កេតអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគបាលយុត្តិធម៌ និងរៀបចំអ្នកជំនួសក្នុងករណីចាំបាច់។

ករណីមានការឃាត់ខ្លួនជនល្មើស ព្រះរាជអាជ្ញាអាចចូលរួមស្តាប់ចម្លើយអាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ការគោរពទម្រង់ច្បាប់ និងការកាន់កាប់កន្លែងឃាត់ខ្លួន[43]។

**លើកលែងតែដីកាសម្រេចចាត់តាំងឲ្យស៊ើបសួរជំនួស ស្ថិតក្រោមអំណាចចៅក្រមស៊ើបសួរ។**

**③/គោលការណ៍បណ្តឹងទាក់ទងនឹងអំពើល្មើសព្រហ្មទណ្ឌ**

•អំពើល្មើសព្រហ្មទណ្ឌណាមួយត្រូវបានប្រព្រឹត្តកម្ម បណ្តឹង២ប្រភេទអាចកើតឡើងគឺបណ្តឹងអាជ្ញា និង ព្យសនកម្ម(បណ្តឹងរដ្ឋប្បវេណី)៖

–**បណ្តឹងអាជ្ញា**:សំដៅលើការចោទប្រកាន់(ដាក់ទណ្ឌកម្ម)[44] កំណត់បទល្មើសតាមច្បាប់កំណត់[45] អាស្រ័យលើប្រព្រឹត្តកម្មនៃអំពើល្មើស និងបុគ្គលិកលក្ខណៈរបស់ចារី ដែលធ្វើឲ្យពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈបង្កភាពវឹកវរដល់សង្គម។

–**បណ្តឹងរដ្ឋប្បវេណី៖** សំដៅលើការជួសជុលព្យសនកម្ម ដែលជាផលវិបាកផ្ទាល់នៃបទល្មើស(ព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬ ខាងផ្លូវចិត្ត)[46]។

---

[42] មាត្រា៣៨ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[43] មាត្រា៣៧ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[44] មាត្រា១ មាត្រា៣ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[45] មាត្រា២ មាត្រា៤ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[46] មាត្រា១៣ មាត្រា១៤ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

### ខ/—តួនាទី និង អំណាចតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

–អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃតំណាងអយ្យការអមសាលាឧទ្ធរណ៍ជាអ្នកធ្វើអធិការកិច្ច និងឃ្លាំមើលនូវអង្គការអយ្យការអមសាលាដំបូងនានាដែលស្ថិតក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[47]។ អគ្គព្រះរាជអាជ្ញាធ្វើការឃ្លាំមើលត្រួតពិនិត្យមន្ត្រីនគរបាលយុត្តិធម៌, អាចកោះអញ្ជើញអ្នកទទួលខុសត្រូវមកពិភាក្សាទាក់ទង នឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលយុត្តិធម៌។

–ព្រះរាជអាជ្ញាអាចប្រគល់ភារកិច្ចដល់មន្ត្រីនគបាលយុត្តិធម៌ ឲ្យបំពេញកិច្ចការមានប្រយោជន៍ដល់ការគ្រប់គ្រងនៃដំណើរការនគបាលយុត្តធម៌។ អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅនគបាលយុត្តិធម៌។ ក្នុងករណីមានការឃាត់ខ្លួននៅនគបាល ព្រះរាជអាជ្ញាអាចចូលរួមការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ទីកន្លែងឃាត់ខ្លួនដែលចាំបាច់មន្ត្រីនគរបាលយុត្តធម៌ត្រូវគោរពតាមអធិបញ្ញា[48] និងទាក់ទងដល់ការគោរពទម្រង់ច្បាប់។

### គ/–តួនាទី និង អំណាចអគ្គព្រះរាជ្ញាអមតុលាការកំពូល

តួនាទី និង អំណាចអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ពិនិត្យលើបណ្តឹងសារទុក្ខ បណ្តឹងសើរើ បណ្តឹងសុំតវ៉ាទៅតុលាការកំពូលដែលកើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចណាមួយរបស់តុលាការថ្នាក់ក្រោម ដែលសាម៉ីបណ្តឹងយល់ឃើញថាអយុត្តិធម៌ ឬមិនត្រឹមត្រូវតាមច្បាប់[49]។

## ២.៣ –វិធានកំណត់អត្តិភាពនៃបណ្តឹងអាជ្ញា

### ក/វិធាន និង គោលការណ៍អត្តិភាពកំណត់បទល្មើសព្រហ្មទណ្ឌ

①.កំណត់បទល្មើសតាមច្បាប់បញ្ញតិ: ចង្អុលបង្ហាញ និងកំណត់សម្គាល់ជនប្រព្រឹត្តបទល្មើស(ស្គាល់អត្តសញ្ញាណ ឬសាវតាជាតិជនល្មើស), វាយតម្លៃសកម្មភាពអំពើល្មើសត្រឹមត្រូវ, សម្អាងភស្តុតាង, កំណត់ធាតុផ្សំបទល្មើស, កំណត់ទោស(កំណត់ឈ្មោះបទល្មើស)[50]។

---

[47] មាត្រា៣៨ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[48] មាត្រា៣៥ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[49] មាត្រា៣២ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[50] មាត្រា១ មាត្រា២ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា៥៤ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

②.គោលការណ៍ត្រឹមត្រូវនៃច្បាប់ព្រហ្មទណ្ឌ: **(គ្មានច្បាប់អាជ្ញា=គ្មានបទល្មើស=គ្មានទណ្ឌកម្ម)**

ជាគោលការណ៍នីត្យានុកូលមួយដែលរាល់បណ្តឹងអាជ្ញាទាំងអស់ តំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់លើជនណាម្នាក់ ដោយគ្មានមូលដ្ឋានច្បាប់ គ្មានការកំណត់បទល្មើសតាមបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌបានទេ ទោះបីជាបទឧក្រិដ្ឋ មជ្ឈិម ឬលហុក៏ដោយ។ ដូច្នេះបណ្តឹងអាជ្ញាត្រូវតែបញ្ញត្តិកំណត់ដោយច្បាប់ ចែងនូវរាល់បទល្មើសទាំងអស់។ ការផ្តន្ទាទោសត្រូវតែប្រព្រឹត្តទៅតាមឆន្ទៈរបស់ច្បាប់ មានចរិតលក្ខណៈគតិយុត្ត ទប់ស្កាត់អំពើទុច្ចរិតរបស់ជនខិលខូចធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សង្គមជាតិ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គមប្រឆាំងច្បាប់ជាធរមាន[51]។

③.គោលការណ៍គ្មានប្រតិសកម្ម: ការអនុវត្តទោសណាមួយ ត្រូវអនុវត្តទៅតាមសុពលភាពនៃនីតិវិធី។ ដំណើរការនៃបណ្តឹងអាជ្ញា ឬនីតិវិធីនៃការស្វែងរកពិរុទ្ធភាព ចំពោះបទល្មើសអាជ្ញាអាចប្រព្រឹត្តទៅបាន គឺត្រូវអនុវត្តភ្លាមនូវច្បាប់ថ្មីដែលចូលជាធរមាន ច្បាប់ថ្មីបាននិរាករណ៍នូវអនុភាព អនុវត្តបញ្ញត្តិព្រហ្មទណ្ឌពីមុន[52] តុលាកាព្រហ្មទណ្ឌមិនអាចលើកយកច្បាប់ចាស់(មុន) ដែលបាននិរាករណ៍មកផ្តន្ទាទោស ឬដាក់ទោសទណ្ឌដោយប្រការណាមួយ ឬបទល្មើដែលកើតឡើងមុនពេលច្បាប់ថ្មីចូលជាធរមានមកអនុវត្តទេ។

④.គោលការណ៍ត្រឹមត្រូវនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ: ការលើកយកមកសិក្សានូវមូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញា ក្នុងរឿងក្តីព្រហ្មទណ្ឌនៃអត្ថបទនេះតំណាងអង្គការអយ្យការត្រូវចង្អុលបង្ហាញលក្ខខណ្ឌកំណត់បទល្មើស តាមច្បាប់បញ្ញត្តិ(កំណត់ទោស), ចង្អុលបង្ហាញពីសកម្មភាពល្មើស(វាយតម្លៃសកម្មភាពអំពើល្មើសត្រឹមត្រូវ), ស្គាល់អត្តសញ្ញាណ ឬសាវតាជាតិជនល្មើសច្បាស់លាស់, បង្ហាញភស្តុតាងដាក់បន្ទុក, កំណត់ធាតុផ្សំបទល្មើសស្របតាមវិធាននៃការកំណត់អត្ថិភាពបណ្តឹងអាជ្ញា ហើយរាល់ការលើកយកមាត្រាណានីមួយនៃបញ្ញត្តិច្បាប់ព្រហ្មទណ្ឌមកវែកញែក ត្រូវចង្អុលបង្ហាញឲ្យឃើញពីពិរុទ្ធភាពដែលប្រឆាំងច្បាប់ជៀសវាងការភ័ន្តច្រឡំ (អង្គហេតុ, អង្គច្បាប់) ។ ប៉ុន្តែរាល់ការការលើកយកមាត្រាណាមួយមកអនុវត្តទោសព្រហ្មទណ្ឌ ត្រូវតែគោរពតាមគោលការណ៍ត្រឹមត្រូវនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ ដែលការបកស្រាយត្រូវធ្វើយ៉ាងតឹងរឹងមិនអាចធ្វើតាមគំនិតយល់ឃើញមានលក្ខណៈប្រហាក់ប្រហែល ឬស្រដៀងគ្នា ឬតាមការប្រៀបប្រដូចករណីណាមួយដូចគ្នានឹងករណីណា

[51] មាត្រា៣ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[52] មាត្រា១១ មាត្រា៦៧១ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

មួយផ្សេងទៀត ឬប្រៀបធៀបករណីនៃអំពើល្មើសណាមួយដែលធ្លាប់បានកើតមានដើម្បីពង្រីកវិសាលភាពអនុវត្ត ប្រព្រឹត្តទៅដោយបុរេសន្ទត់នៃពិរុទ្ធភាព ស្ថិតក្នុងលក្ខណៈវិមតិសង្ស័យនោះទេ[53]។ ដូច្នេះគោលការណ៍មិនត្រឹមនៃ ការបកស្រាយច្បាប់ត្រូវតែលើកយកបញ្ញត្តិច្បាប់ជាធរមានមកអនុវត្តប៉ុណ្ណោះទេ ថែមទាំងត្រូវគោរពតាមគោលការណ៍នេះជាមូលដ្ឋានក្នុងការចោទប្រកាន់ សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។

កាលពីសម័យដើមមានការបកស្រាយប្រកបដោយលក្ខណៈវិទ្យាសាស្រ្ត តាមទស្សនៈមូលដ្ឋានសម្រាប់ធ្វើការផ្តន្ទាទោសផងដែរ។

- ទស្សនៈមូលដ្ឋានសំរាប់ធ្វើការផ្តន្ទាទោស

–សិក្សាតាមផ្នែកចិត្តសាស្រ្តៈ ប្រព័ន្ធនីតិសាស្រ្តផ្នែកព្រហ្មទណ្ឌជាមួយនឹងបុគ្គលវិទ្យាសាស្រ្តអាចផ្តល់នូវការពិចារណាយល់ដឹងយ៉ាងល្អិតល្អន់ដល់បុគ្គលដែលមានការប្រព្រឹត្ត ឬចេតនាប្រព្រឹត្តបទល្មើស (ទោសនេះមានលក្ខណៈធ្ងន់ធ្ងរមិនដូចបណ្តឹងរដ្ឋប្បវេណីទេ)។

- ទស្សនៈទេវលោក

–ក្នុងច្បាប់សីលធម៌ គេលើកយកច្បាប់សីលធម៌នេះ ដើម្បីវែកញែកទៅលើកំហុសតាម

សីលធម៌២បែបគឺៈ

1. កំហុសដែលនាំឲ្យធ្វើទោសតាមច្បាប់សីលធម៌ៈ កំហុសនេះគឺគេសង្កត់ធ្ងន់ទៅលើ ទណ្ឌកម្មផ្លូវចិត្តដែលពុំមានរូបរាងច្បាស់លាស់ ដោយសារការធ្វើទោសមិនមែនសម្រាប់ពេល បច្ចុប្បន្នភ្លាមៗទេ វាសម្រាប់អនាគតកាល(ឧ.អំពើបាបត្រូវទទួលជាតិក្រោយ)។
2. ចំពោះអំពើខ្លះ ដូចជាការជេរប្រមាថ ការភូតកុហក ការសម្លាប់សត្វបែបនេះ សុទ្ធតែត្រូវបានទទួលទណ្ឌកម្មផ្លូវសីលធម៌ ប៉ុន្តែគ្មានជាប់ផ្លូវអាជ្ញាទេ នៅពេលដែលអំពើទាំងនោះ មិនត្រូវបានបញ្ញត្តិព្រហ្មទណ្ឌនៅឡើយ។

- ទស្សនៈដាច់ខាត

–តាមការសិក្សាសង្គមវិជ្ជាៈ

[53] មាត្រា៥ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ និង ៣៨ វាក្យខណ្ឌ៦ នៃរដ្ឋធម្មនុញព្រះរាជាណាចក្រកម្ពុជា។

1.អាចផ្តល់លទ្ធភាពទាក់ទងយ៉ាងជិតស្និតទៅនឹងច្បាប់ព្រហ្មទណ្ឌ និង សង្គមមនុស្ស,

2. ច្បាប់សង្គម(រដ្ឋ) ជនប្រព្រឹត្តបទល្មើសត្រូវតែទទួលទោសតាមបញ្ញត្តិច្បាប់រដ្ឋជាធរមាន។

–តាមការសិក្សាជាតិសាស្ត្រនៃមនុស្ស ឬ បរមត្ថវិជ្ជាៈ តម្រូវឲ្យច្បាប់ព្រហ្មទណ្ឌទទួលស្គាល់ព្រំដែនជុំវិញបញ្ហាគោរពសិទ្ធិ និង សេរីភាពរបស់បុគ្គល។

–តាមការសិក្សានីតិវេជ្ជសាស្ត្រៈ វិជ្ជានេះផ្តល់ជំនួយគ្រប់យ៉ាងដល់ការស្វែងរកហេតុផល នៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនប្រព្រឹត្តបទល្មើស ផ្តល់អត្ថប្រយោជន៍ ក្នុងការស្វែងរកភស្តុតាងបទល្មើស និងជនល្មើស ក៏ដូចជាការធ្វើកោសល្យវិច្ច័យ ផ្សេងៗ។

## ខ/•ធាតុផ្សំបទល្មើស

ធាតុផ្សំបទល្មើសជាផ្នែកមួយនៃ គោលការណ៍ដ៏សំខាន់ដែលត្រូវគោរពតាមដោយហ្មត់ចត់ដើម្បីកំណត់ឲច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ក៏ដូចជាមូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញា នៅចំពោះមុខតុលាការព្រហ្មទណ្ឌ។

និយមន័យៈ និយមន័យបទល្មើសព្រហ្មទណ្ឌ កើតចេញពីសកម្មភាពសត្យានុម័តនូវរាល់ប្រព្រឹត្តកម្មទាំងឡាយដែលល្មើសនឹងវិធាន ឬបទដ្ឋាននានាដែលបញ្ញត្តិកំណត់ដោយច្បាប់ជាធរមានជាអំពើមានលក្ខណៈព្យាបាទ បង្កភាពរឹករវប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម។ អាចជាបទល្មើសសកម្ម សំដៅទៅលើសកម្មភាពវិជ្ជមាន (ស្តែងចេញនូវអំពើជាក់ស្តែង និងចេតនាប្រព្រឹត្តដោយចារី សហចារី ឬជនសមគំនិត)។ បទល្មើសអកម្មសំដៅលើសកម្មភាពអវិជ្ជមាន(ស្តែងចេញនូវចេតនា ទុកបណ្តោយឲ្យជនរងគ្រោះ ទទួលរងគ្រោះថ្នាក់ហើយមិនព្រមជួយសង្គ្រោះ)។

បទល្មើសៈ ជាសកម្មភាពប្រព្រឹត្តដោយបំពានប្រឆាំងច្បាប់ជាធរមាន ដែលបានបញ្ញត្តិកំណត់ទុកជាវិធាន។ ជាអំពើ និងចេតនាប្រព្រឹត្ត ប៉ះពាល់ដល់សន្តាប់ធ្នាប់សាធារណៈ ប្រឆាំងសាធារណៈជន សន្តិសុខសង្គម ផ្ទុយនឹងច្បាប់ ដែលប្រព្រឹត្តកម្មទាំងនោះត្រូវបានកំណត់ការដាក់ទោសទណ្ឌដោយច្បាប់បញ្ញត្តិជាធរមាន។

### ដើម្បីកំណត់អំពើណាមួយជាបទល្មើស ចាំបាច់ត្រូវមានមូលដ្ឋានកំណត់ធាតុ៣

**–ធាតុនីត្យានុកូលៈ** ជាវិធានកំណត់ដោយច្បាប់នូវបទល្មើស និង ទោស (ជាធាតុច្បាប់។ បទល្មើស និងទោសនេះចាំបាច់ត្រូវតែមានចែងក្នុងច្បាប់ (តាមគោល

ការណ៍ គ្មានច្បាប់អាជ្ញា គ្មានបទល្មើស គ្មានទណ្ឌកម្ម "គ្មានអំពើណាមួយត្រូវបានកំណត់បទល្មើសដោយគ្មានច្បាប់ចែងទេ") មានតែអំពើដែលប្រព្រឹត្តផ្ទុយ ឬល្មើសនឹងមាត្រាណាមួយនៃបទបញ្ញត្តិព្រហ្មទណ្ឌប៉ុណ្ណោះទើបអាចកំណត់បទល្មើស និងអនុវត្តទោសបាន[54]។

**-ធាតុសត្យានុម័តៈ** ជាសកម្មភាពនៃអំពើល្មើសពិតប្រាកដ ឬការប៉ុនប៉ងប្រាកដ ឬការប៉ុនប៉ងប្រព្រឹត្តដោយអំពើល្មើសសកម្ម ឬ អំពើអកម្ម គឺជាការកំណត់បទល្មើសមួយដែលស្តែងចេញពីសកម្មភាពរបស់ជនល្មើស ដែលប្រព្រឹត្តផ្ទុយមាត្រានីមួយៗ (គេសន្មត់ថាជាធាតុនៃអំពើ) ។

**-ធាតុអត្តនោម័តៈ** គឺជាការយល់ដឹងរបស់ជនល្មើស នូវការហាមឃាត់ដោយច្បាប់ និងការប្រព្រឹត្តផ្ទុយច្បាប់។ ជនល្មើសមានចេតនា និង ឆន្ទៈ និង មានបំណងបង្កភាពវឹកវរធ្វើឲ្យប៉ះពាល់សន្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គមមានចរិតព្យាបាទបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ។ ជាមូលដ្ឋានចិត្តសាស្ត្រក្នុងការកំណត់ស្ថានភាពផ្លូវចិត្តកម្រិតយល់ដឹង សមត្ថភាពបរិបូរណ៍ក្នុងការទទួលខុសត្រូវរបស់ជនល្មើស។ ពុំមានបទល្មើសទេ ក្នុងករណីជនត្រូវចោទគ្មានចេតនាប្រព្រឹត្ត។ លើកលែងតែបទល្មើសដែលកើតចេញពីធ្វេសប្រហែស ការខ្ជីខ្ជារ ឬការមិនគោរពកាតព្វកិច្ច ក្នុងករណីច្បាប់បានបញ្ញត្តទុកជាមុន[55]។

## ៣ -សេចក្តីសន្និដ្ឋាន

មូលដ្ឋានសម្រាប់ការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ តំណាងអង្គការអយ្យការជាស្ថាប័នចោទមួយ ត្រូវប្រតិបត្តិតួនាទីប្រកបដោយភាពត្រឹមត្រូវតាមបញ្ញត្តិច្បាប់ប្រកបដោយយុត្តិធម៌ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ជាការអ្នកធានារ៉ាប់រងសេចក្តីសម្រេចខាងព្រហ្មទណ្ឌចំពោះមុខតុលាការព្រហ្មទណ្ឌ ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយត្រូវគោរពតាមគោលការណ៍នៃដែនអនុវត្តច្បាប់ព្រហ្មទណ្ឌសម្រាប់មូលដ្ឋានចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ។

[54] មាត្រា៣ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[55] មាត្រា៤ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

►គោលការណ៍នៃដែនអនុវត្តច្បាប់សម្រាប់មូលដ្ឋានចោទប្រកាន់៖

①.វាយតម្លៃអំពើល្មើសបញ្ជាក់អត្ថបទច្បាប់ (កំណត់បទល្មើសតាមច្បាប់ព្រហ្មទណ្ឌ)

– ចង្អុលបង្ហាញ វាយតម្លៃអំពីសកម្មភាពនៃអំពើល្មើស។
– កំណត់អង្គហេតុ(សេចក្តីសង្ខេបនៃអង្គហេតុ)[56] ឬធាតុផ្សំបទល្មើសឲ្យបានត្រឹមត្រូវច្បាស់លាស់។
– អនុវត្តតាមគោលការណ៍ត្រឹមត្រូវនៃច្បាប់ព្រហ្មទណ្ឌ។
– អនុវត្តតាមគោលការណ៍ត្រឹមត្រូវនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ។
– អនុវត្តគោលការណ៍គ្មានប្រតិសកម្ម។

②.ចង្អុលបង្ហាញភស្តុតាង ឬ សាក្សី។

③.ចង្អុលបង្ហាញជនប្រព្រឹត្តបទល្មើស ឬ ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស។

– កំណត់ឈ្មោះ ឬអត្តសញ្ញាណ ឬសាវតាជាតិបុគ្គលប្រព្រឹត្តបទល្មើសច្បាស់លាស់។

④. កំណត់ទោស និង កំណត់ការអនុវត្តទោស(កំណត់ឈ្មោះបទល្មើស)[57]។

សរុបសេចក្តីមក ព្រះរាជអាជ្ញាជាអ្នកកាន់ច្បាប់អាជ្ញានៃច្បាប់រដ្ឋ ក្នុងការការពារផលប្រយោជន៍សិទ្ធិសេរីភាព ក៏ដូចជាការបង្ក្រាបបទល្មើស ប្រកបដោយចរិតលក្ខណៈគតិយុត្តិ ស្របតាមឆន្ទៈរបស់ច្បាប់។ តំណាងអង្គការអយ្យការត្រូវប្រតិបត្តិតួនាទី ភារកិច្ចដោយសម្អាងលើមូលដ្ឋានច្បាស់លាស់សម្រាប់ការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ។ ក្នុងទិដ្ឋភាពសង្គមមនុស្សដែលឆ្លុះបញ្ចាំងឲឃើញភាពត្រឹមត្រូវ យុត្តិធម៌ និងអាចទទួលយកបានទាំងជនរងគ្រោះ ទាំងការបង្ក្រាបបទល្មើស។

[56] មាត្រា៤៤ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

[57] មាត្រា១ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៤៤ វាក្យខណ្ឌទី៣ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

# ផ្នែកពាណិជ្ជកម្ម

# ការតែងតាំងមជ្ឈត្តករផ្នែកពាណិជ្ជកម្ម

*( Appointment of Arbitrators )*

**ដោយមេធាវី គឹម សាន***

## ១. សេចក្តីផ្តើម

អត្ថបទនេះធ្វើការពិភាក្សាអំពីបញ្ហាទាក់ទងនឹងការតែងតាំងមជ្ឈត្តករ ដែលចាប់ផ្តើមពីការសម្ភាសន៍មជ្ឈត្តករ ដើម្បីកំណត់ពីលក្ខណៈសម្បត្តិ និងគុណភាពរបស់មជ្ឈត្តករ និង វិធានស្តីពីការតែងតាំងដែលពាក់ព័ន្ធ។ ទោះបីជាអត្ថបទនេះមិនពិភាក្សាអំពីភាពខុសគ្នានៃ វិធានរបស់ស្ថាប័នមជ្ឈត្តការនីមួយៗ អ្នកនិពន្ធបានធ្វើការវិភាគ អំពីនីតិវិធីក្នុងការតែងតាំង មជ្ឈត្តករតាមវិធានស្តីពី មជ្ឈត្តការនៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា ដែលត្រូវបានអនុម័តនៅថ្ងៃទី១១ កក្កដា ឆ្នាំ២០១៤។

ការដោះស្រាយទំនាស់ពាណិជ្ជកម្មតាមរយៈមជ្ឈត្តការ ផ្តល់ឲ្យភាគីនូវសេរីភាពក្នុងការជ្រើសរើស និងស្នើឲ្យតែងតាំងមជ្ឈត្តករដែលខ្លួនចូលចិត្តបំផុត លើកលែងតែភាគីខកខានមិនបានតែងតាំង។ គោលការណ៍សេរីភាពនេះឆ្លុះបញ្ចាំងពីសុចរិតភាពនៃនីតិវិធី នៅពេលដែលគូភាគីបានជ្រើសរើសអ្នកសម្រេចរឿងរបស់ខ្លួន (មជ្ឈត្តករ) ដោយខ្លួនឯង។ សុចរិតភាព នៃនីតិវិធីដែលត្រូវគេមើលឃើញពីដំបូងផ្សារភ្ជាប់នឹងគុណភាព (Efficiency) និងប្រសិទ្ធិភាព (Effectiveness) នៃការដោះស្រាយទំនាស់។ ជារឿយៗមេធាវីជាតំណាងរបស់កូនក្តី (ភាគី) របស់ខ្លួនក្នុងការធ្វើការស្រាវជ្រាវ សម្ភាសន៍ និងណែនាំឲ្យកូនក្តីរបស់ខ្លួនធ្វើការសម្រេចអំពីមជ្ឈត្តករណាម្នាក់ដែលសក្តិសមបំផុតសម្រាប់សម្រេចរឿងក្តីរបស់ខ្លួន។ ដោយហេតុថា មេធាវីជាអ្នកបានសិក្សាច្បាប់ មជ្ឈត្តករដែលត្រូវបានជ្រើសរើសជារឿយៗ គឺជាអ្នកមានវិជ្ជាជីវៈច្បាប់ដែរ ដូចជាមជ្ឈត្តករជាមេធាវី មជ្ឈត្តករជាសាស្រ្តាចារច្បាប់ ជាដើម។

មជ្ឈត្តករខ្លះជាអ្នកជំនាញខាងវិស័យណាមួយពិតប្រាកដ (ឧទាហរណ៍ ខាងសំណង់ ព្រោះគាត់ជាវិស្វករ) តែមិនធ្លាប់បានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ទេ ដូចមេធាវី និងសាស្រ្តាចារផ្នែកច្បាប់ទេ។ មជ្ឈត្តករខាងជំនាញផ្សេងក្រៅពីច្បាប់អាចមិនយល់ដឹងពីច្បាប់បានទូលំទូលាយទេ ប៉ុន្តែយល់ដឹងច្បាស់ជាងគេពីខ្លឹមសារលម្អិតតាមន័យបច្ចេកទេសដែលអ្នក

---

* មេធាវី **គឹម សាន** បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកច្បាប់សេដ្ឋកិច្ចអន្តរជាតិ ពីសកលវិទ្យាល័យ Victoria University of Wellington (VUW) ប្រទេសណូវែលហ្សេឡង់។ លោក គឹម សាន ប្រកបវិជ្ជាជីវៈច្បាប់ ដើម្បីលុបបំបាត់ឧបសគ្គនានានៅក្នុងការធ្វើពាណិជ្ជកម្ម។ លោកគឹម សាន ជាមេធាវីក្នុងក្រុមមេធាវីខេមលីហ្គលអាស៊ី Camlegal Asia (www.camlegal.asia)។

ច្បាប់មិនយល់អស់។ ឧទាហរណ៍មជ្ឈត្តករជាវិស្វករ យល់ដឹងពីបញ្ហាដែលកើតឡើងជារឿយៗ នៅក្នុងកិច្ចសន្យាសាងសង់ខុនដូ និងអាចដឹងយ៉ាងច្បាស់ថាបញ្ហាកិច្ចសន្យានោះបណ្តាលមកពីមូលហេតុអ្វី ហើយវាជាកំហុសផ្នែកបច្ចេកទេស កំហុសស្តីពីការព្រងើយកន្តើយ ឬកំហុសដោយចេតនា។ មជ្ឈត្តករជាវិស្វករ អាចជួយកំណត់ចំណុចវិវាទបានឆាប់រហ័ស ទាក់ទងនឹងបញ្ហាបច្ចេកទេស ទាំងឡាយ។ ទោះបីជាយ៉ាងណាក៏ដោយ គូភាគីមួយចំនួននៅតែត្រូវការ មជ្ឈត្តករជាអ្នកច្បាប់ ដោយអះអាងថាខ្លួនអាចរកសាក្សីជំនាញ (សាក្សីជាវិស្វករ) មកបំភ្លឺ ដើម្បីទទួលបានចំណេះដឹងពីវិស័យណាមួយ នៅក្នុងរឿងក្តីរបស់ខ្លួន ដោយមិនចាំបាច់មានមជ្ឈត្តករតាមវិស័យដូចជាវិស្វករជាដើម។ ជារឿយៗគេយល់ថា មជ្ឈត្តករដែលមិនមែនជាមេធាវីមិនយល់ពីមូលដ្ឋាននៃការសម្រេចបែបនីតិវិធី និងជាលក្ខណៈសារធាតុទេ ហើយវេទិកានឹងខាតបង់ពេលវេលាជាច្រើនពន្យល់មជ្ឈត្តករមិនមែនមេធាវីអំពីច្បាប់។[58]

ទោះបីជាយ៉ាងណាក៏ដោយ គូភាគីខ្លះជ្រើសរើសផ្លូវកណ្តាលមួយ ឆ្ពោះទៅរកការតែងតាំងមជ្ឈត្តករ ដូចជាគេជ្រើសរើសមជ្ឈត្តរជំនាញលើវិស័យណាមួយ ដែលទទួលបានការអប់រំច្បាប់ខ្លះៗ ឬគ្រប់គ្រាន់ ឬជ្រើសរើសមជ្ឈត្តករជាមេធាវីដែលធ្លាប់ទទួលបានការអប់រំខាងវិស័យណាមួយ ក្នុងរឿងក្តី។ ជាតួយ៉ាង ក្នុងវេទិការដែលមានគ្នា៣នាក់ គេអាចរើសមជ្ឈត្តករម្នាក់ជាមេធាវី ម្នាក់ជាវិស្វករ និងម្នាក់ទៀតជាសាស្ត្រាចារច្បាប់។ យើងសង្កេតឃើញថា គ្មានវិធានណាមួយដែលតម្រូវឲ្យមានសមាសភាពមជ្ឈត្តករដាច់ខាតនោះទេ។ ស្ថាប័នមជ្ឈត្តការមិនតម្រូវឲ្យមជ្ឈត្តករត្រូវមានលក្ខណៈសម្បត្តិជាមេធាវី ឬជាអ្នកជំនាញក្នុងវិស័យណាមួយឡើយ។ ដូច្នេះការជ្រើសរើសសមាសភាព (ភាពចម្រុះ) នៃមជ្ឈត្តករ គឺអាស្រ័យលើការចូលចិត្ត ការព្រមព្រៀង និងការជ្រើសររើសរបស់គូភាគី។

## ២. ដំណើរការតែងតាំងមជ្ឈត្តករ

### ២. ១ ការសម្ភាសន៍មជ្ឈត្តករ

ខុសពីចៅក្រមក្នុងតុលាការពាណិជ្ជកម្ម មជ្ឈត្តករអាចជួបសម្ភាសន៍ជាមួយភាគី ឬមេធាវីរបស់ភាគី តាមការស្នើរបស់ភាគីដើម្បីភាគីសម្រេចចិត្តជ្រើសរើស ឬមិនជ្រើសរើស ដើម្បីសម្រេចសេចក្តីលើវិវាទពាណិជ្ជកម្ម។ ក្នុងករណីភាគច្រើន មេធាវីរបស់ភាគីធ្វើការជួប និងផ្តល់អនុសាសន៍រើសមជ្ឈត្តករណាម្នាក់ឲ្យភាគី។ ការអនុញ្ញាតិឲ្យសម្ភាសន៍ គឺផ្អែកលើគោលការណ៍

[58] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, page 118.

ស្វ័យភាពរបស់ភាគី ដែលភ្ជាប់នឹងសេរីភាពក្នុងការជ្រើសរើស និងដែលអាចធ្វើឡើងដោយភាគីណាមួយឬទាំងអស់លើមជ្ឈត្តករតែម្នាក់។ ប៉ុន្តែជារឿយៗ មេធាវីរបស់ភាគីចូលចិត្តសម្ភាសន៍ជាមួយមជ្ឈត្តករដែលខ្លួនបម្រុងនឹងជ្រើសរើស ជាជាងជាមួយមជ្ឈត្តករដែលភាគីម្ខាងទៀតបម្រុងនឹងជ្រើសរើស។ ប្រសិនបើគូភាគីជ្រើសរើសមជ្ឈត្តករតែមួយរូប ជាទូទៅគូភាគីជួបមជ្ឈត្តកររូបនោះ ជាមួយគ្នា ដើម្បីកាត់បន្ថយនៅភាពសង្ស័យអំពីថាភាគីណាមួយមានឥទ្ធិពលលើមជ្ឈត្តករមុន។ នៅក្នុងវេទិការដែលមានមជ្ឈត្តករ៣រូប គូភាគីតែងចង់ជួបជាមួយមជ្ឈត្តករដែលគេបម្រុងនឹងជ្រើសរើស ប្រសិនបើមជ្ឈត្តកររូបនោះមានឆន្ទៈធ្វើដូច្នេះដែរ។[59]

ទោះបីជាយ៉ាងណាក៏ដោយ ជាទូទៅនៅមានភាពតានតឹងកើតឡើងរវាងកាតព្វកិច្ចរក្សាភាពមិនលម្អៀងរបស់មជ្ឈត្តករដែលទទួលការសម្ភាសន៍ និងតម្រូវការចង់បានព័ត៌មានរបស់មេធាវីរបស់ភាគី។ មជ្ឈត្តករដែលមានបទពិសោធន៍ច្រើនមួយចំនួនមិនចង់ទទួលសម្ភាសន៍ជាមួយភាគីទេ ប៉ុន្តែបានត្រឹមផ្ញើរប្រវត្តិរូប និងគុណវឌ្ឍន៍នានាឲ្យគូភាគីពិនិត្យ និងសម្រេចចិត្តជ្រើសរើសខ្លួន។[60] គោលការណ៏មួយចំនួន ត្រូវបានតាក់តែងឡើងដើម្បីកំណត់ដែននៃការសម្ភាសន៍មជ្ឈត្តករ ដើម្បីធានាមិនឲ្យប៉ះពាល់ដល់ភាពមិនលម្អៀងរបស់មជ្ឈត្តករនៅពេលចូលកាន់រឿងក្តី។ ដែនកំណត់ នៃការសម្ភាសន៍នោះ គឺមិនត្រូវហួសពីការសាកសួរព័ត៌មានស្តីពីគុណសម្បត្តិ (Qualifications) បទពិសោធន៍ និងភាពទំនេរដើម្បីបំពេញការងារជាមជ្ឈត្តករ។ ជាក់ស្តែងណាស់ ក្រមសីលធម៌សម្រាប់មជ្ឈត្តករ ដែលបានចុះបញ្ជី ឬប្រតិបត្តិក្រោមវិធានរបស់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា កំណត់ល័ក្ខខ័ណ្ឌ៤ ដើម្បីមជ្ឈត្តករអាចទទួលយកការតែងតាំងបាន។[61] *ទី១៖* មិនត្រូវស្នើសុំឲ្យភាគីតែងតាំងខ្លួនក្នុងវេទិការមជ្ឈត្តកម្ម *ទី២៖* ទទួលស្គាល់ថាខ្លួនមានសមត្ថភាពពេញលេញក្នុងការដោះស្រាយវិវាទ *ទី៣៖* ផ្តល់ពេលវេលា (Availability) និងការយកចិត្តទុកដាក់ពេញលេញ

---

[59] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, page 128.

[60] See Gerald Aksen, The Tribunal′s Appointment, 35, in THE LEADING ARBITRATORS GUIDE TO INTERNATIONAL ARBITRATION, ed. Lawrence W. Newman (2004)

[61] គោលការណ៍ទាំងនេះ ក៏មានចែងក្នុងក្រមសីលធម៌សម្រាប់មជ្ឈត្តករដែលបានចុះបញ្ជី ឬប្រតិបត្តិក្រោមវិធានរបស់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយហត្ថលេខារបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥

ចំពោះដំណើរការមជ្ឈត្តការតាមការរំពឹងទុករបស់គូភាគី និង *ទី៤៖* អនុវត្តតួនាទីរបស់ខ្លួន ផ្អែកតាមក្រមសីលធម៌នេះ ដោយមិនលំអៀង និងដោយឯករាជ្យភាព។

### ២. ២ ចំនួនមជ្ឈត្តករ

មជ្ឈត្តករដើរតួដូចជាចៅក្រមផ្នែកពាណិជ្ជកម្ម ប៉ុន្តែសេចក្តីសម្រេចរបស់មជ្ឈត្តករជារឿយៗ មិនត្រូវបានសម្រេចសាជាថ្មីដោយហេតុផលខុសអង្គហេតុ ឬហេតុផលច្បាប់ឡើយ។ ជាតួយ៉ាងមជ្ឈត្តករអាចបង្កើតកំហុសក្នុងមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ដោយការបកស្រាយរបស់ខ្លួន ឬមានកំហុសលើអង្គហេតុនៃរឿងក្តី ហើយមេធាវីជាទូទៅមិនអាចឈ្នះក្នុងការបដិសេធមជ្ឈ-វិនិច្ឆ័យនោះដោយសារហេតុផលកំហុសទាំងនោះឡើយ។[62] ម៉្យាងវិញទៀតច្បាប់កម្ពុជា មិនតម្រូវឲ្យមជ្ឈត្តករ ត្រូវជាអ្នកច្បាប់ ជាមេធាវី ឬអ្នកមានសញ្ញាប័ត្រច្បាប់ឡើយ។ មជ្ឈត្តករចាំបាច់ត្រូវយល់ពីវិធានរបស់ស្ថាប័នដែលខ្លួនត្រូវបានតែងតាំង ដែលទាក់ទងនឹងការដឹកនាំនីតិវិធី ដើម្បីសម្រេចលើរឿងក្តីប្រកបដោយភាពរលូន ។

ជាទូទៅមជ្ឈត្តករ១ ឬ៣រូប ត្រូវបានជ្រើសរើសដើម្បីកាត់សេចក្តីលើវិវាទផ្នែកពាណិជ្ជកម្ម ទោះបីជាច្បាប់នីមួយៗអាចអនុញ្ញាតឲ្យមានចំនួនលើសពីនេះក៏ដោយ ឲ្យតែចំនួនសេស។[63] ការជ្រើសរើសចំនួន១រូបទាក់ទងនឹងការចំណាយអស់តិច និង៣រូប ទាក់ទងនឹងការចំណាយអស់ច្រើនលើការជួលមជ្ឈត្តករដើម្បីសិក្សា និងដោះស្រាយសំណុំរឿង។[64] ក្នុងករណីខ្លះ ភាគីជម្លោះអាចឯកភាពគ្នាជ្រើសរើសមជ្ឈត្តករ៣រូប នៅពេលដែលទឹកប្រាក់ ដែលជាកម្មវត្ថុនៃទំនាស់មានទំហំធំ ដែលផ្តល់ហេតុផលសមស្របក្នុងការធ្វើដូច្នេះ។

នៅពេលដែលការប្រើមជ្ឈត្តករ១រូប ផ្តល់ភាពបត់បែនផ្នែកពេលវេលាច្រើនជាពិសេសក្នុងការកំណត់កម្មវិធីជម្រះ ការប្រើមជ្ឈត្តករ៣រូបនឹងធ្វើឲ្យទទួលបានការយល់ពីដំណើរការនៃរឿងក្តីបានគ្រប់ជ្រុងជ្រោយ ដោយម៉ត់ចត់ជាង។[65] គេអាចចំណាយពេលតិចជាង

---

[62] Lucy Reed & Phillip Riblett, Expansion of Defenses to Enforcement of International Arbitral Awards in U.S Courts? 13 Sw.J.L.& Trade Am. 121 (2006)

[63] មាត្រា ១៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម អនុម័តនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៦ ចែងថា "ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករ នៃវេទិកាមជ្ឈត្តកម្ម។ មជ្ឈត្តករត្រូវមានចំនួនសេស។ បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួន បី (៣) នាក់។"

[64] ទោះបីជាមជ្ឈត្តករមានតួនាទីស្រដៀងគ្នា នឹងចៅក្រម មជ្ឈត្តករជាវិជ្ជាជីវៈដែលមិនទទួលប្រាក់បៀវត្សពីរដ្ឋទេ តែទទួលបានសេវាពីភាគី។

[65] Margaret L. Moses, the Principles and Practice of International Commercial Arbitration, 2008, page 117.

នៅក្នុងវេទិកាដែលមានគ្នាមួយរូប តែភាពខ្វែងគំនិតគ្នានៅក្នុងវេទិកា៣រូប អាចចោទជាបញ្ហាពេលវេលា។ ទោះជាយ៉ាងណាក៏ដោយ ភាពចម្រុះនៃជំនាញ ចំណេះដឹង និងសមត្ថភាពក្នុងការវិនិច្ឆ័យក៏សំបូរបែបជាងដែរនៅ ក្នុងវេទិកានៃមជ្ឈត្តករ៣រូប។

### ២.៣ លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ

មជ្ឈត្តការផ្នែកពាណិជ្ជកម្មផ្តល់លទ្ធភាព ឲ្យគូភាគីជ្រើសរើសយកមជ្ឈត្តករដែលមានចំណេះដឹង និងបទពិសោធន៍ នៅក្នុងផ្នែកទាក់ទងនឹងចំណុចវិវាទ។ ការជ្រើសរើសមជ្ឈត្តករត្រូវតាមបទពិសោធន៍ និងចំណេះដឹងធ្វើឲ្យចំណេញពេលវេលាជាច្រើន ដែលគូភាគីត្រូវពន្យល់គាត់នៅក្នុងនីតិវិធីមជ្ឈត្តការ។ ដោយឡែកវិធាន១១ នៃវិធានស្តីពីមជ្ឈត្តការ នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) តម្រូវលក្ខខណ្ឌអប្បរមាដូចជា ថាតើបុគ្គលនោះបានចុះបញ្ជីជាមួយ ម.ជ.ម. ឬទេ ឬមួយថា តើ *"បុគ្គលនោះ បានបំពេញតួនាទីឬបានចុះបញ្ជីជាមជ្ឈត្តករផ្នែកពាណិជ្ជកម្ម ជាមួយស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងប្រទេសឬអន្តរជាតិ"* ដែលម.ជ.ម. ធ្លាប់បានទទួលស្គាល់។[66] តាមទិដ្ឋភាពជាក់ស្តែង បុគ្គលដែលម.ជ.ម. បានចុះបញ្ជីក្នុងស្រុក ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសម្រេចសេចក្តី ក៏ដូចជាច្បាប់ដែលពាក់ព័ន្ធ ពីម.ជ.ម. ដោយផ្ទាល់ ឬក្រោមការសម្របសម្រួលពីម.ជ.ម។[67] ទោះបីជាយ៉ាងណាក៏ដោយការធ្លាប់ទទួលការបណ្តុះបណ្តាលមិនមែនសុទ្ធសឹងជាកត្តាសំខាន់ជាងគេ សម្រាប់ការជ្រើសរើសរបស់គូភាគីឡើយ។[68]

---

66 វិធានស្តីពីមជ្ឈត្តការ ធ្វើនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា

67 សំណុំឯកសារពាក់ព័ន្ធមជ្ឈត្តការនៅកម្ពុជា ឆ្នាំ២០១៧ រៀបចំដោយ ម.ជ.ម. ទំព័រទី១ ដល់ទី ១៣។ សិក្ខាកាមដែលបានចូលរួមការបណ្តុះបណ្តាលមានជាង៣០នាក់និងភាគច្រើនបានប្រលងជាប់និងបំពេញបែបបទផ្សេ ងៗដើម្បីចុះបញ្ជីជាមជ្ឈត្តករ តាមតម្រូវការរបស់ម.ជ.ម.។ ក្រៅពីនេះ មានមជ្ឈត្តករមួយចំនួនទៀតដែលបានចុះបញ្ជីមុនឆ្នាំ២០១៧ ប៉ុន្តែឆ្លងកាត់ការបណ្តុះបណ្តាលមួយចំនួនតាមការសម្របសម្រួលរបស់ម.ជ.ម.ដែរ

68 ការស្រាវជ្រាវមួយរបស់សមាគម មជ្ឈត្តការរបស់អាមេរិកកាំង (AAA) បានរកឃើញថា ភាពជំនាញលើវិស័យអ្វីមួយ គឺជាគុណសម្បត្តិសំខាន់បំផុត ក្នុងចំណោមគុណសម្បត្តិទាំងប្រាំ ដែលគូភាគីត្រូវការ។ គុណសម្បត្តិទាំង៥នោះគឺ ជំនាញលើវិស័យអ្វីមួយ ការបណ្តុះបណ្តាលផ្នែកច្បាប់ បទពិសោធន៍ពីមុនក្នុងមជ្ឈត្តការ ការបណ្តុះបណ្តាលធ្វើឡើងដោយ AAA និង ចារិករបស់បុគ្គល។ តាមពិត ការបណ្តុះបណ្តាលផ្នែកច្បាប់ និងបទពិសោធន៍ពីមុនក្នុងមជ្ឈត្តការ ឈរលើលំដាប់ទី២ បន្ទាប់ពីភាពជំនាញលើវិស័យអ្វីមួយ និងការបណ្តុះបណ្តាលធ្វើឡើងដោយ AAA ឈរលើលំដាប់បន្ទាប់ និងចារិកទូទៅរបស់បុគ្គលឈរលើលំដាប់ចុងក្រោយ ។ សូមមើល Non-

ទោះបីជាវិធាននានារួមទាំងវិធានរបស់ម.ជ.ម. ផង មិនតម្រូវឲ្យមជ្ឈត្តករ ត្រូវតែជាមេធាវី គូភាគីតែងជ្រើសរើសយកមេធាវីឲ្យធ្វើជាមជ្ឈត្តករក្នុងរឿងក្តីរបស់ខ្លួន។

## ២.៤ វិធានស្តីពីការតែងតាំងមជ្ឈត្តករ

គូភាគីធ្វើការជ្រើសរើស មជ្ឈត្តករតាមការព្រមព្រៀង ហើយនីតិវិធីក្នុងការជ្រើសរើសខុសៗគ្នា ទៅតាមវិធានរបស់ស្ថាប័នដែលគូភាគីជ្រើសរើស នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ។ ប្រសិនបើគូភាគីមិនបានព្រមព្រៀងពីរបៀបដែលគូភាគីរើសមជ្ឈត្តករនៅក្នុងខចែងស្តីពីមជ្ឈត្តករទេ តែបានជ្រើសរើសវិធានក្នុងការគ្រប់គ្រងនីតិវិធី ការជ្រើសរើសនោះនឹងធ្វើឡើងតាមវិធានរបស់ស្ថាប័នដែលគេបានជ្រើសរើសនោះ។[69] ទោះបីជាយ៉ាងណាក៏ដោយ បើគូភាគីមិនបានព្រមព្រៀងលើរបៀបជ្រើសរើសមជ្ឈត្តករជាមុនទេ គូភាគីអាចព្រមព្រៀងជ្រើសរើសនៅមុនពេលចាប់ផ្តើមមជ្ឈត្តការពាណិជ្ជកម្ម។ ប្រសិនបើគូភាគីមិនអាចឈានដល់ការព្រមព្រៀងទេ ស្ថាប័នដែលអនុម័តវិធាននោះនឹងជ្រើសរើសមជ្ឈត្តករ។

វិធានស្តីពីមជ្ឈត្តការរបស់ប្រទេសកម្ពុជា រួមមានបទបញ្ញត្តិស្តីពី ការជ្រើសរើសមជ្ឈត្តកររបស់គូភាគី ក៏ដូចជាការជ្រើសរើសដោយស្ថាប័នមានសមត្ថកិច្ច ដែលជាគណៈកម្មាធិការតែងតាំងនៃម.ជ.ម.។[70] វិធាននេះអនុញ្ញាតឲ្យគូភាគីជ្រើសរើសមជ្ឈត្តករមួយរូប បីរូប ឬច្រើនជាងនេះ ឲ្យតែជាចំនួនសេស។[71] ប្រសិនបើគូភាគី មិនអាចព្រមព្រៀង លើចំនួនមជ្ឈត្តករ ម.ជ.ម. ត្រូវកំណត់ចំនួនមជ្ឈត្តករ៣រូប។ នៅក្នុងមជ្ឈត្តកម្មដែលមានមជ្ឈត្តករបីរូប ភាគីម្ខាងត្រូវជ្រើសតាំងមជ្ឈត្តករមួយរូប ហើយមជ្ឈត្តករទាំងពីរនេះត្រូវបន្តជ្រើសតាំងមជ្ឈត្តករទីបី។ *"ប្រសិនបើការតែងតាំងមិនត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេនោះ ភាគីនីមួយៗត្រូវតែងតាំងមជ្ឈត្តករម្នាក់មួយរូបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការទទួលបានការឆ្លើយតបចំពោះសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។"*[72]

---

Lawyers in International Commercial Arbitration: Gathering Splinters on the Bench, Issue 1, Spring 1991, North western Journal of International Law & Business, ទំព័រ ៣១

[69] Margaret L. Moses, the Principles and Practice of International Commercial Arbitration, 2008, page 120.

[70] វិធាន ១០.២ នៃវិធានស្តីពីមជ្ឈត្តការ

[71] វិធាន ៩ នៃវិធានស្តីពីមជ្ឈត្តការ

[72] វិធាន ១០.២ កថាខ័ណ្ឌ១ នៃវិធានស្តីពីមជ្ឈត្តការ

### ២.៥ ភាពទំនេរដើម្បីបំពេញការងារ

គូភាគីតែងចង់បាន មជ្ឈត្តករដែលល្បីល្បាញ ដែលធ្លាប់មានបទពិសោធន៍សម្រេចសេចក្ដីលើសំណុំរឿងច្រើន។ តាមពិតមជ្ឈត្តករដែលល្បីអាចមិនមានពេលគ្រប់គ្រាន់ក្នុងការចូលរួមប្រកបដោយអត្ថន័យនៅក្នុងនីតិវិធីនីមួយៗទេ។ ដើម្បីបញ្ចៀសបញ្ហានេះ គូភាគីត្រូវស្វែងយល់ពីពេលវេលារបស់មជ្ឈត្តករដែលខ្លួនមានបំណងចង់តែងតាំងជាមុនសិន បន្ទាប់មកធ្វើការប្រៀបធៀប រវាងពេលទំនេរសម្រាប់រឿងក្ដី និងសមត្ថភាពរបស់គាត់។

### ២.៦ គុណភាពអរូបរបស់មជ្ឈត្តករ (Intangible Quality)

ក្នុងផ្នែកនេះ គុណភាពអរូបិយមិនសំដៅលើ ស្ថានភាពសង្គម វប្បធម៌ ការអប់រំ និងប្រភេទការងារដែលមជ្ឈត្តករធ្វើក្រៅពីនោះឡើយ។[73] "ភាពស្មោះត្រង់" "ភាពមិនលម្អៀង" និង" សុចរិតភាព" ជាគុណភាពអរូបរបស់មជ្ឈត្តករដែលគូភាគីត្រូវការ។ "ភាពស្មោះត្រង់" ជាគុណភាពមួយដែលផ្សារភ្ជាប់នឹងជំនឿរបស់មជ្ឈត្តករ។ ប្រសិនបើគាត់ជឿជាក់ថា អ្វីដែលខ្លួនគាត់ធ្វើត្រូវ នោះគាត់មានភាពស្មោះត្រង់ ដែលជាតម្រូវការរបស់គូភាគី។ ប្រសិនបើ ភាគីស្វែងយល់ដោយខ្លួនឯងថា មជ្ឈត្តករនោះនឹងប្រកាន់យកគោលជំហរ និងសម្រេចតាមភាពស្មោះត្រង់របស់ខ្លួន នោះគូភាគីនឹងគោរពភាពស្មោះត្រង់របស់មជ្ឈត្តករនោះមិនថាការសម្រេចចិត្តនោះមិនតំណាងឲ្យប្រយោជន៍របស់ខ្លួនក៏ដោយ។[74] ដោយឡែក "ភាពមិនលម្អៀង" ក៏ជាគុណភាពសំខាន់មួយទៀត ដែលមជ្ឈត្តករត្រូវផ្សារភ្ជាប់នឹងជំនាញ និងបទពិសោធន៍របស់ខ្លួន។ ជាទូទៅ "ភាពមិនលម្អៀង" មានន័យថា មជ្ឈត្តករមិនត្រូវលម្អៀង ដោយហេតុផលថា មានសញ្ញាណដឹងមុនអំពីបញ្ហាទាំងនេះមុន ឬដោយហេតុផលណាមួយធ្វើឲ្យពេញចិត្តភាគីម្ខាងជាងភាគីម្ខាងទៀត។[75] នៅពេលដែលគូភាគីមើលឃើញកេរ្តិ៍ឈ្មោះរបស់មជ្ឈត្តករជាមុន ភាពមិនលម្អៀងរបស់មជ្ឈត្តករកើតចេញពីបទពិសោធន៍ និងជំនាញពីមុនៗមក ក្នុងការគិតថាការសម្រេចចិត្តណាមួយត្រឹមត្រូវ។ គូភាគីអាចផ្ទៀងផ្ទាត់កម្រិតលម្អៀង ឬមិនលម្អៀងរបស់មជ្ឈត្តករណាមួយ

---

[73] Non-Lawyers in International Commercial Arbitration: Gathering Splinters on the Bench, Issue 1, Spring 1991, North western Journal of International Law & Business, ទំព័រ ៤១

[74] Non-Lawyers in International Commercial Arbitration: Gathering Splinters on the Bench, Issue 1, Spring 1991, North western Journal of International Law & Business, ទំព័រ ៤២

[75] Margaret L. Moses, the Principles and Practice of International Commercial Arbitration, 2008, page 130.

តាមមជ្ឈត្តវិនិច្ឆ័យដែលគាត់បានចេញពីមុនៗ។ ក្រៅពីនេះ "សុច្ចរិតភាព" គួរតែជាគុណភាពដ៏សំខាន់បំផុត។ គេអាចចោទសួរសំណួរខាងក្រោម ដើម្បីកំណត់ថាតើមជ្ឈត្តករណាម្នាក់មាន

បញ្ហាផ្នែក "សុចរិតភាព" ឬទេ?[76]

*១. តើមជ្ឈត្តករនោះមានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុ ឬពាណិជ្ជកម្មពីភាគីខាងណាឬទេ? តើមជ្ឈត្តករ ធ្លាប់ទទួលប្រយោជន៍បែបនេះពីពេលមុនឬទេ?*

*២. តើមជ្ឈត្តករមានទំនាក់ទំនងផ្ទាល់ខ្លួន មិនថាផ្ទាល់ ឬមិនផ្ទាល់ទេ ជាមួយភាគីខាងណាមួយ?*

*៣. តើមជ្ឈត្តករ ផ្តល់យោបល់គាំទ្រភាគីណាមួយខ្លាំងឬទេ?*

*៤. តើប្រវត្តិការងារជាមជ្ឈត្តករពីមុនៗរបស់គាត់យ៉ាងណាដែរ?*

## ៣. សេចក្តីសន្និដ្ឋាន

គូភាគីធ្វើការជ្រើសរើសមជ្ឈត្តករ តាមរយៈការស្វែងយល់ពីចំណេះដឹង និងបទពិសោធន៍របស់មជ្ឈត្តករ និងគុណភាពអរូបរបស់មជ្ឈត្តករ។ គុណភាពអរូបមិនសំដៅលើស្ថានភាពសង្គម វប្បធម៌ ការអប់រំ និងប្រភេទការងារដែលមជ្ឈត្តករធ្វើក្រៅពីវិជ្ជាជីវៈមជ្ឈត្តករនោះឡើយ។ ស្ថាប័នផ្នែកមជ្ឈត្តការជាអ្នកកំណត់ល័ក្ខខ័ណ្ឌអប្បរមាដើម្បីកំណត់ថា ជនណាអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីសម្រេចលើរឿងក្តីពាណិជ្ជកម្មសម្រាប់គូភាគីជ្រើសរើស។ ប៉ុន្តែការជ្រើសរើសពីកម្រិតផ្នែកជំនាញ និងបទពិសោធន៍ បូករួមទាំង"ភាពស្មោះត្រង់" "ភាពមិនលម្អៀង" និង"សុចរិតភាព" ត្រូវស្វែងចេញ ពីសមត្ថភាពត្រួតពិនិត្យរបស់គូភាគីទៅវិញទេ។ ទោះបីជាក្រមសីលធម៌សម្រាប់មជ្ឈត្តករនានាបានធ្វើការធានាពី"ភាពស្មោះត្រង់" "ភាពមិនលម្អៀង" និង"សុចរិតភាព" នៅក្នុងបញ្ញត្តិនីមួយៗក៏ដោយ ក៏បញ្ញត្តិទាំងនោះបានជាការក្រើនរំលឹកដល់មជ្ឈត្តករថា ខ្លួននឹងអាចត្រូវជំទាស់នៅពេលណាមួយដោយភាគីចំពោះការមិនប្រកាសរបស់ខ្លួន។ គុណភាពអរូបរបស់មជ្ឈតករគឺមិនអាចមើលឃើញដោយភ្នែកទទេ ដោយសារការគិត និងការយល់ឃើញរបស់មនុស្សគឺមិនអាចមើលឃើញរហូតដល់សម្តែងចេញមកខាងក្រៅ។ ដោយហេតុថា គុណភាពរបស់មជ្ឈត្តករទាក់ទងដោយផ្ទាល់នឹងពេលវេលាដោះស្រាយ (វែង ឬខ្លី) និងចំណាយ (តិច ឬច្រើន) និងភាពដែលអាចទទួល ឬមិនទទួលយកបាន

[76] **F. Elkouri and E. Elkouri,** តើមជ្ឈត្តការដំណើរការដោយរបៀបណា? How **ARBITRATION WORKS 140-41 (1985).**

នៅក្នុងការសម្រេចសេចក្តីរបស់គូភាគី(គុណភាពមជ្ឈត្តវិនិច្ឆ័យ) ការជ្រើសរើសមជ្ឈត្តករជៀសមិនផុតពីការពិនិត្យមើលឲ្យគ្រប់ជ្រុងជ្រោយឡើយ។

# សេចក្តីជូនដំណឹងអំពីការកែតម្រូវអត្ថបទដែលបានចុះផ្សាយ

ក្រុមបណ្ណាធិការនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សុំធ្វើការកែតម្រូវ នូវចំណងជើងអត្ថបទដែលចុះផ្សាយលេខ ១៧ (មេសា-មិថុនា ២០១៨) នៅទំព័រទី១ ដែលមានចំណងជើងថា **ការរំលាយកិច្ចសន្យាមានកំណត់ថេរវេលា** ទៅជា **ការរំលាយកិច្ចសន្យាការងារមិនកំណត់ថេរវេលា។**

អាស្រ័យដូចបានជូននូវការកែតម្រូវនេះ សហភាតា ឯកឧត្តមលោកជំទាវ និងអស់លោក លោកស្រីទាំងអស់ជ្រាបជាព័ត៌មាន។

# សកម្មភាពរបស់គណៈមេធាវី

# ១. កិច្ចប្រជុំផ្ទៃក្នុង

## កិច្ចប្រជុំបុគ្គលិកពិនិត្យការងារប្រចាំខែធ្នូ និងលើកទិសដៅការងារប្រចាំខែថ្មី

នាថ្ងៃសុក្រ ១៥រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក, ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រជុំបុគ្គលិកប្រចាំខែធ្នូ។

នៅក្នុងកិច្ចប្រជុំនេះមានរបៀបវារៈពីរសំខាន់ៗគឺ ១) ការផ្សព្វផ្សាយគោលនយោបាយហិរញ្ញវត្ថុរបស់គណៈមេធាវីដែលក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចកាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ២) ការរាយការណ៍របស់បុគ្គលិកដែលបានសម្រេចក្នុងខែកន្លងមក បញ្ហាប្រឈមមុខ និងផែនការបន្ទាប់សម្រាប់នាយកដ្ឋាននីមួយៗ។ នៅក្នុងកិច្ចប្រជុំក៏មានការចូលរួមពីលោកមេធាវី យឹម សារី នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី អគ្គលេខាធិការរង និងបុគ្គលិកគ្រប់នាយកដ្ឋានទាំងអស់។ នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោកប្រធានគណៈមេធាវីបានផ្តល់អនុសាសន៍ល្អៗដល់បុគ្គលិកគ្រប់នាយកដ្ឋាន រួមទាំងបុគ្គលិកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើយ៉ាងណាបម្រើការងារតាមផ្នែកនីមួយៗរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។



## កិច្ចប្រជុំពិភាក្សាការងាររបស់ប្រតិភូគណៈមេធាវី ប្រចាំត្រីមាស

នៅថ្ងៃសុក្រ ៦ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាការងារប្រតិភូប្រចាំត្រីមាស ។

នៅក្នុងកិច្ចពិភាក្សានេះ បានផ្តោតលើបញ្ហាប្រឈមមុខ នៃការអនុវត្តការងារកន្លងមក របៀបនៃសរសេររបាយការណ៍រឿងក្តី នីតិវិធីទូទាត់ថវិកា បទបង្ហាញអំពីការប្រើប្រាស់ Database និងផែនការយុទ្ធសាស្រ្តសម្រាប់ឆ្នាំបន្ទាប់។ នៅក្នុងកិច្ចប្រជុំនេះផងដែរ លោកប្រធានគណៈមេធាវីបានផ្តល់នូវអនុសាសន៍ល្អៗ
សម្រាប់ឲ្យសមាជិក-សមាជិកាប្រតិភូ និងលេខាធិការគណៈមេធាវីធ្វើយ៉ាងណាឲ្យដំណើរការនៃការងារប្រតិភូប្រកបដោយគុណភាព និងការទទួលខុសត្រូវខ្ពស់។



## ២. កិច្ចប្រជុំគណៈកម្មការជំនាញ

### កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ជាលើកទី២

នៅថ្ងៃអាទិត្យ ១៤រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំ សមាជិក គណៈ-កម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ជាលើកទី២ ក្រោមការដឹកនាំ ប្រជុំដោយ លោកមេធាវី គង់ សំអុន ប្រធានគណៈកម្មការ។នៅក្នុងកិច្ចប្រជុំ សមាជិក-សមាជិការគណៈកម្មការបានពិភាក្សាលើការកែសម្រួលបទបញ្ជាផ្ទៃក្នុង ផែនការសកម្មភាពការងារ ដែលទាក់ទងនឹងការធ្វើជាវាគ្មិនសម្រាប់សិក្ខាសាលា ការបណ្តុះបណ្តាលមេធាវីចូល ប្រកបតាមមាត្រា ៣២ ការធ្វើជាវាគ្មិនក្នុងប៉ុស្តិ៍ទូរទស្សន៍បាយ័ន ការសរសេរអត្ថបទដាក់ចូលព្រឹត្តិបត្រ គណៈមេធាវី ការវាយតម្លៃពីការយល់ដឹងរបស់សហភាតា អំពីសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ការទៅទស្សនៈកិច្ចនៅក្រៅប្រទេស បញ្ហាការសរសេរសារណារបស់សហភាតានៅ តុលាការកំពូលនិងទាក់ទងការកំណត់ចំនួនសមាជិកចូលរួចសិក្ខាសាលា។



## គណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការរដ្ឋប្បវេណី

នៅថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិក គណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី។

សមាជិក-សមាជិកានៃគណៈកម្មការបានជជែកពិភាក្សាអំពី ផែនការសម្រាប់ធ្វើ វីដេអូផ្សព្វផ្សាយច្បាប់ និងពិភាក្សាមេរៀនស្តីពីសន្តតិកម្ម ដែលត្រូវលើយកមកធ្វើបទបង្ហាញ តាមទូរទស្សន៍។




## គណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី

នៅថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំ កិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការកិច្ចការរដ្ឋប្បវេណីលើកទី០៥ ក្រោមការដឹកនាំប្រជុំ ដោយ

លោកមេធាវី អ៊ីវ ប៉ូលី ប្រធានគណៈកម្មការ។ នៅក្នុងកិច្ចប្រជុំសមាជិក-សមាជិកា គណៈកម្មការបានពិភាក្សាផ្តោតសំខាន់លើប្រធានបទសម្រាប់កម្មវិធីផ្សព្វផ្សាយច្បាប់តាមរយៈ ទូរទស្សន៍ វិទ្យុ សិក្ខាសាលា និងព្រឹត្តិបត្រគណៈមេធាវី ។



## គណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី

នៅថ្ងៃអង្គារ ៥រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការ កិច្ចការរដ្ឋប្បវេណី ក្រោមការដឹកនាំប្រជុំដោយ លោកមេធាវី អ៊ីវ ប៉ូលី ប្រធានគណៈកម្មការ។

នៅក្នុងកិច្ចប្រជុំនេះ លោកមេធាវី អ៊ីវ ប៉ូលី បានធ្វើបទបង្ហាញប្រធានបទស្តីពី “ការប្រាក់” ដល់សមាជិក-សមាជិកានៃអង្គប្រជុំ ដើម្បីចែករំលែកនូវចំណេះដឹង សម្រាប់ សមាជិកនៃគណៈកម្មការកិច្ចការរដ្ឋប្បវេណីផងដែរ។ ក្រោយបញ្ចប់នូវបទបង្ហាញនោះមក អង្គប្រជុំក៏

បានសម្រេចក្នុងការដាក់សំណើបញ្ចូលនូវសមាជិក-សមាជិកាថ្មី ដើម្បីឲ្យលោក ប្រធាន គណៈមេធាវីសម្រេចផងដែរ។




## គណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការពាណិជ្ជកម្ម

នាថ្ងៃច័ន្ទ ៥រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការពាណិជ្ជកម្មប្រចាំខែតុលា ក្រោមការដឹកនាំប្រជុំដោយលោកស្រីមេធាវី យូ សួនទី ប្រធានគណៈកម្មការ។ នៅក្នុងកិច្ចប្រជុំ សមាជិក-សមាជិការគណៈកម្មការបានពិភាក្សា ផ្តោតសំខាន់លើប្រធានបទសម្រាប់កម្មវិធីផ្សព្វផ្សាយច្បាប់តាមទូរទស្សន៍ និងតាមរយៈសិក្ខា-សាលា។ នៅក្នុងកិច្ចប្រជុំនេះ ក៏បានកំណត់ចំពោះអ្នកទទួលខុសត្រូវក្នុងការស្រាវជ្រាវ លើប្រធានបទនីមួយៗផងដែរ។




## គណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិការគណៈកម្មការកិច្ចការការងារ

នៅថ្ងៃសុក្រ ៩កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំកិច្ចប្រជុំសមាជិក -សមាជិកាគណៈកម្មការកិច្ចការការងារលើកទី០៣ ក្រោមការដឹកនាំប្រជុំដោយ លោកស្រី មេធាវី អាន វីរៈ ប្រធានគណៈកម្មការ។ នៅក្នុងកិច្ចប្រជុំសមាជិក-សមាជិកា គណៈកម្មការបាន ពិភាក្សា ផ្តោតសំខាន់លើ ប្រធានបទសម្រាប់កម្មវិធីផ្សព្វផ្សាយច្បាប់តាមរយៈ ទូរទស្សន៍ វិទ្យុ សិក្ខាសាលា និងព្រឹត្តិបត្រគណៈមេធាវី។

# ៣. ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ៣.១ ទំនាក់ទំនងជាតិ

### លោកមេធាវី សួន វិសាល បានដឹកនាំមេធាវីចំនួន ៩៩រូប ចូលរួមសិក្ខាសាលាជាលើកទី២ស្តីពីការលើកកម្ពស់ការយល់ដឹងស្តីពីវប្បធម៌សារពើពន្ធដល់វិស័យយុត្តិធម៌

នៅថ្ងៃអង្គារ ៤កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំមេធាវីចំនួន៩៩ រូបចូលរួមសិក្ខាសាលាស្តីពីការលើកកម្ពស់ការយល់ដឹងស្តីពី វប្បធម៌សារពើពន្ធដល់វិស័យយុត្តធម៌ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



### កិច្ចពិភាក្សាស្តីអំពី៖ ការពង្រឹងវិជ្ជាជីវៈមេធាវីលើប្រព័ន្ធយុត្តិធម៌

កិច្ចពិភាក្សាស្តីអំពី៖ ការពង្រឹងវិជ្ជាជីវៈមេធាវីលើប្រព័ន្ធយុត្តិធម៌ ដែលមានការចូលរួមពីលោកមេធាវី សួន វិសាល ជាប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ផិន ម៉ាលីន អនុរដ្ឋលេខាធិការ និងអ្នកនាំពាក្យ នៃក្រសួងយុត្តិធម៌ នៅកម្មវិធី Asean Connect នៃស្ថានីយទូរទស្សន៍ PNN។

## កិច្ចសំណេះសំណាលរវាងលោកមេធាវីសួន វិសាល ជាមួយនិស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

នាថ្ងៃអង្គារ ១១ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកិច្ចសំណេះសំណាលជាមួយនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ កិច្ចសំណេះសំណាលនេះផ្តោតសំខាន់លើ តួនាទីរបស់គណៈមេធាវីក្នុងការជួយកិច្ចការសង្គមពិសេសក្នុងវិស័យ យុត្តិធម៌ និងកំណែទម្រង់ស៊ីជម្រៅនៅក្នុងស្ថាប័នគណៈមេធាវីនៅក្នុងអាណត្តិដឹកនាំរបស់លោកផងដែរ។ លោកមេធាវី សួន វិសាលក៏បានលើកទឹកចិត្តឲ្យនិស្សិតប្រឹងប្រែងរៀនសូត្រ និងប្រលងចូលសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីដែលបាននឹងកំពុងធ្វើការជ្រើសរើសនិស្សិតចូលរៀនជារៀងរាល់ឆ្នាំ។



## លោកមេធាវី សួន វិសាល បានចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន

នាថ្ងៃសុក្រ ១៤ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៨ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អមដោយលោកមេធាវី កុយ នាម ជាអគ្គលេខាធិការរង នៃគណៈមេធាវី និងលោកមេធាវី វ៉ា ពិសី ជាប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្របានចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៨-២០២០ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



## លោកអគ្គលេខាធិការរងជួបសំណេះសំណាលជាមួយនិស្សិតមកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចខេត្តបាត់ដំបង

នៅថ្ងៃអង្គារ ៣ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី កុយ នាម អគ្គលេខាធិការរងនៃគណៈមេធាវីបានជួបសំណេះសំណាលជាមួយនិស្សិតពូកែ ឆ្នាំទី៣ មកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) ខេត្តបាត់ដំបង និងនិស្សិតសាកលវិទ្យាល័យបាត់ដំបង (UBB) ចំនួន៣០ នាក់ ដើម្បីធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់ និង ទទួលបានបទពិសោធន៍អំពីតួនាទី និងភារៈ

កិច្ចរបស់ គណៈមេធាវី។ នៅក្នុងកិច្ចសំណេះសំណាលនេះ លោកមេធាវី កុយ នាម ក៏បានធ្វើបទបង្ហាញអំពីគណៈមេធាវី និងផ្ដល់ឱកាសសម្រាប់និស្សិតសួរសំណួរដើម្បីជជែកពិភាក្សាផងដែរ។






## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានដឹកនាំគណៈប្រតិភូ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

នៅព្រឹកថ្ងៃព្រហស្បត្តិ៍ ៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនិងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្តីការក្រសួងយុត្តិធម៌ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានដឹកនាំគណៈប្រតិភូ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើរបៀបវារៈចំនួន ៤ គឺ៖

១-ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

២-ការរៀបចំសិក្ខាសាលារួមគ្នាក្នុងគោលបំណងពង្រឹងវិស័យយុត្តិធម៌។

៣-ជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រ។

៤-អគាររដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ជាលទ្ធផលនៃជំនួបពិភាក្សាអង្គប្រជុំបានសម្រេច៖

១-ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបន្តអនុវត្តតាមយន្តការក្រុមការងារដែលមានស្រាប់ ដោយសហការជាមួយក្រសួងពាណិជ្ជកម្ម និងធ្វើរបាយការណ៍ មកក្រសួងយុត្តិធម៌ឲ្យបានឆាប់។

២-ឯកឧត្តមរដ្ឋមន្ត្រីបានឯកភាពជាគោលការណ៍ រៀបចំសិក្ខាសាលារួមគ្នារវាង គណៈមេធាវី និងក្រសួងយុត្តិធម៌ ដើម្បីពង្រឹងវិស័យយុត្តិធម៌។

៣-ចំពោះជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រ អង្គប្រជុំបានឯកភាពគ្នាថានឹងស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសុំបង្កើនថវិកាជួយសំណុំរឿងក្តីជនក្រីក្រ បន្ទាប់ពីបានទទួលរបាយការណ៍លទ្ធផលការងារលម្អិតពីគណៈមេធាវី។

៤-ចំពោះអគាររដ្ឋបាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឯឧត្តម រដ្ឋមន្ត្រីស្នើឲ្យបង្កើតក្រុមការងារមួយដើម្បីពិភាក្សាលម្អិតពីករណីនេះ។ កិច្ចប្រជុំបានបញ្ចប់ទៅក្រោមបរិយាកាសយោគយល់ និងស្និតស្នាលជាទីបំផុត។





## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បានរៀបចំកម្មវិធីបិទវគ្គបណ្តុះបណ្តាលសុក្រិតការវិជ្ជាជីវៈមេធាវីវគ្គ៦

នៅថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលបណ្តុះ បណ្តាលវិជ្ជាជីវៈមេធាវីបានរៀបចំកម្មវិធីបិទវគ្គបណ្តុះបណ្តាលសុក្រិតការវិជ្ជាជីវៈមេធាវីវគ្គ៦ ក្រោមអធិបតីភាពរបស់លោកមេធាវី សួន វិសាល ប្រធាន គណៈមេធាវី លោកមេធាវី យឹម សារី នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងសមាជិក-សមាជិកក្រុមប្រឹក្សាគណៈមេធាវី។ វគ្គបណ្តុះបណ្តាលសុក្រិតការវិជ្ជាជីវៈមេធាវីវគ្គទី៦ មានកម្មសិក្សាការីចំនួន៨៩រូប ដែលបានចូលសិក្សាលើជំនាញឯកទេសបន្ថែមចំនួន១៨០ម៉ោង សម្រាប់ប្រកបវិជ្ជាជីវៈមេធាវីប្រកបដោយការទទួលខុសត្រូវ និងសេចក្តីថ្លៃថ្នូរ។ លោកមេធាវី សួន វិសាល ក៏បានផ្តាំផ្ញើដល់កម្មសិក្សាការីទាំងអស់យកជំនាញ និងចំណេះដឹងសម្រាប់ផលប្រយោជន៍សង្គម និងពង្រឹងនូវការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ នៅចុងបញ្ចប់នៃកម្មវិធីបិទវគ្គនេះ លោកគណៈអធិបតីក៏បានចែកជូននូវកម្រងអនុស្សាវរីយ៍សម្រាប់កម្មសិក្សាការីនិងថតរូបទុកជាអនុស្សាវរីយផងដែរ។



# ៣.២ ទំនាក់ទំនងអន្តរជាតិ

## សន្និសីទអន្តរជាតិស្តីពី "ធ្វើឲ្យការប្រកបវិជ្ជាជីវៈរបស់លោកអ្នកទៅជាសកល ៖ ឱកាស និងការប្រឈម"

នៅថ្ងៃព្រហស្បតិ៍ ៨ រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានសហការជាមួយសមាគមគណៈមេធាវីអន្តរជាតិ (International Bar Association), LAWASIA និង មូលនិធិមេធាវីអឺរ៉ុប (European Lawyer Foundation) បានរៀបចំសន្និសីទអន្តរជាតិស្តីពី "ធ្វើឲ្យការប្រកបវិជ្ជាជីវៈរបស់លោកអ្នកទៅជាសកល ៖ ឱកាស និងការប្រឈម" ដែលប្រព្រឹត្តនៅសណ្ឋាគារសូហ្វីតែលអង្គរ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឱកាសនេះលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានថ្លែងចំណាប់អារម្មណ៍ស្វាគមន៍ដល់ភ្ញៀវ ជាតិនិងអន្តរជាតិ ដែលបានចូលរួម នៅព្រឹត្តការណ៍សំខាន់នេះ។ នៅព្រឹត្តការណ៍នេះមាន ការចូលរួមពីវាគ្មិនអន្តរជាតិជាច្រើនដែលបានចែករំលែកក្នុងផ្តល់ចំណេះដឹង និងបទពិសោធន៍ ពាក់ព័ន្ធនឹងឧបករណ៍ស្តីពីពាណិជ្ជកម្មអន្តរជាតិក្នុងសេវាកម្មច្បាប់ និងការអនុវត្តន៍ការងារ មេធាវីនៅក្នុងតំបន់អាស៊ី និន្នាការនៃការគ្រប់គ្រងក្រុមហ៊ុនមេធាវីមជ្ឈត្តការ នៃការជម្លោះ ពាណិជ្ជកម្មអន្តរជាតិជាដើម។






## កម្ពុជាធ្វើជាម្ចាស់ផ្ទះសន្និសីទលើកទី៣១ នៃសមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៅខេត្តសៀមរាប

(សៀមរាប)៖ សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA) សហការជាមួយគណៈមេធាវីនៃកម្ពុជា និងគណៈកម្មាធិការជាតិ នៃសមាគមច្បាប់អាស៊ានកម្ពុជា បានប្រារព្ធសន្និសីទលើកទី៣១របស់ខ្លួន ក្រោមអធិបតីភាព ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តំណាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែល ប្រព្រឹត្តទៅនៅខេត្តសៀមរាប ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

ក្នុងសន្និសីទនេះ ក៏មានការចូលរួមពី លោក អ៊ុក សាវុធ អគ្គព្រះរាជអាជ្ញានៃ មហាអយ្យ ការអមសាលាឧទ្ធរណ៍ តំណាងប្រធានតុលាការកំពូល, តំណាងអង្គភាពប្រឆាំងអំពើពុករលួយ, លោក មេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃកម្ពុជា, លោក គ្រីស្តូហ្វឺ លុង ប្រធាន សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA), លោក ឃឹម ប៊ុនសុង អភិបាលខេត្តសៀមរាប

និងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃកម្ពុជា ជាអ្នកសម្របសម្រួលការងារ។

លោក គ្រីស្តូហ្វើ លុង ប្រធានសមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA) បានរាយការណ៍ដោយសង្ខេប ពីសកម្មភាពការងាររបស់សមាគមច្បាប់ សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA) និងបានលើកឡើងថា ការសម្រេចយកកម្ពុជាជាម្ចាស់ផ្ទះ នៃការរៀបចំសន្និសីទលើកទី៣១នេះ ក៏ដោយសារកម្ពុជា មានសុខសន្តិភាព និងសុវត្ថិភាពពេញលេញ ជាពិសេសកម្ពុជាជាគោលដៅ ទាក់ទាញអ្នកវិនិយោគពីគ្រប់ មជ្ឈដ្ឋាន។

លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃកម្ពុជា និងជាប្រធានសមាគមច្បាប់អាស៊ានកម្ពុជា បានគូសបញ្ជាក់ថា សន្និសីទលើកទី៣១ របស់សមាគមច្បាប់ សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA) នេះ អាចប្រព្រឹត្តទៅបាន គឺដោយសារមានការគាំទ្រពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ហើយជាប្រវត្តិសាស្ត្រហើយដែលកម្ពុជា ត្រូវបានជ្រើសរើសឲ្យធ្វើជាម្ចាស់ផ្ទះនៃសន្និសីទនេះ។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានថ្លែងទៅកាន់អង្គសន្និសីទថា កម្ពុជាកំពុងដើរលើផ្លូវដ៏ត្រឹមត្រូវមួយ ដែលមានកំណើនសេដ្ឋកិច្ចជាង៧% រយៈពេល៣ឆ្នាំបន្តបន្ទាប់គ្នា ដែលនេះកើតចេញពីស្ថេរភាពនយោបាយ សុវត្ថិភាពសង្គម និងសន្តិសុខគតិយុត្តិ ដែលកម្ពុជាកំពុងមាន។

រាជរដ្ឋាភិបាលអាណត្តិទី៦ ដែលទើបតែទទួលបានការគាំទ្រពីប្រជាពលរដ្ឋកម្ពុជាដ៏ច្រើនលើសលប់ ក្នុងការបោះឆ្នោតជាសាកល កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨កន្លងមកនេះ បាននិងកំពុងខិតខំជំរុញបន្ថែមទៀត នូវក្របខណ្ឌច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ច ការវិនិយោគក្នុងប្រទេស ការការពារសិទ្ធិមនុស្ស ការការពារបរិស្ថាន ការពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ការដោះស្រាយបញ្ហាដីធ្លី ជាពិសេសពង្រឹងយន្តការពាណិជ្ជកម្ម អន្តរប្រទេស និងការខិតខំធ្វើឲ្យមានសុខដុមនីយកម្មនៃ ច្បាប់ក្នុងក្របខណ្ឌតំបន់ និងសាកលលោក។

សូមបញ្ជាក់ថា សន្និសីទលើកទី៣១ នៃសមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (LAWASIA)នេះ ប្រព្រឹត្តិទៅរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី០២ រហូតដល់ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសណ្ឋាគារសូហ្វីតែលអង្គរភូគីត្រា ខេត្តសៀមរាប ដែលមានអ្នកច្បាប់អន្តរជាតិចូលរួមប្រមាណជាង៥០០នាក់។

សន្និសីទលើកទី៣១នេះ នឹងលើកយកប្រធានបទមួយចំនួនមកពិភាក្សា ដូចជា បញ្ហាសេដ្ឋកិច្ច ការវិនិយោគក្នុងប្រទេស ការការពាសិទ្ធិមនុស្ស ការកាពារបរិស្ថាន ការពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ការដោះស្រាយបញ្ហាដីធ្លី ជាពិសេស ពង្រឹងយន្តការពាណិជ្ជកម្មអន្តរប្រទេស និងការខិតខំធ្វើឲ្យមានសុខដុមនីយកម្មនៃច្បាប់ ក្នុងក្របខណ្ឌតំបន់។






LAWASIA
SOFITEL
HOTELS & RESORT
ANGKOR PHOKEETHRA



# ការបោះឆ្នោតជ្រើស តាំងប្រធានគណៈ មេធាវីសម្រាប់អាណត្តិ ទី ១២

# និង

# ជ្រើសតាំងក្រុមប្រឹក្សា គណៈមេធាវីសម្រាប់ អាណត្តិទី៩

## លទ្ធផលបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី ១២ និងជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩

នៅថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខារ៉េស៊ីដង់ភ្នំពេញ បានរៀបចំមហាសន្និបាតលើកទី ២៣ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងការអញ្ជើញចូលរួមជាអធិបតីពីសំណាក់ ឯកឧត្តម អង្គវង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងឯកឧត្តម អ៊ិក សារុធ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងសមាជិកក្រុមប្រឹក្សាគណៈមេធាវីផងដែរ។

បន្ទាប់ពីលោកមេធាវី ព្រហ្ម វិចិត្រក្ខរា អគ្គលេខាធិការគណៈមេធាវី រាយការណ៍ពីសកម្មភាពការងាររយៈពេលមួយឆ្នាំរបស់គណៈមេធាវី អង្គសន្និបាតបានដំណើរការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី១២ និងជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩។ ជាលទ្ធផល លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី ១១ ត្រូវបានអង្គសន្និបាតបោះឆ្នោតឱ្យបន្តធ្វើជាប្រធានគណៈ មេធាវីសម្រាប់អាណត្តិទី ១២ ទៀត។ ទន្ទឹមនឹងនេះ អង្គសន្និបាតក៏បានបន្តបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩ សរុបចំនួន ៣៣ រូបដូចមានរាយនាមដូចខាងក្រោមនេះ៖

| | | |
|---|---|---|
| ១ មេធាវី កុយ នាម | ១២ មេធាវី ហុង គឹមសួន | ២៣ មេធាវី ស៊ុយ ឈុនហាក់ |
| ២ មេធាវី ទេព បូផល | ១៣ មេធាវី ឌុយ សុខសូលីដា | ២៤ មេធាវី គង់ សំអុន |
| ៣ មេធាវី ពេជ្រ សូរិយា | ១៤ មេធាវី សួន ប៊ុនធឿន | ២៥ មេធាវី ហាក់ សៀកលី |
| ៤ មេធាវី ជុំ សុវណ្ណាលី | ១៥ មេធាវី កេង សុម៉ារតន៍ | ២៦ មេធាវី គង់ សុភ័ក្ត្រ |
| ៥ មេធាវី ប៉ា ងួនគា | ១៦ មេធាវី ពិន វណ្ណៈ | ២៧ មេធាវី គាន តារា |
| ៦ មេធាវី ចេង ប៉េងហាប់ | ១៧ មេធាវី ច័ន្ទ វិចិត្រ | ២៨ មេធាវី ហ៊ាង ហុង |
| ៧ មេធាវី យុង ផានិត | ១៨ មេធាវី ព្រហ្ម វិចិត្រសុភា | ២៩ មេធាវី ឈរ លីថៃ |
| ៨ មេធាវី ចៅ ប៊ុនហួន | ១៩ មេធាវី ណុប គុណថុល | ៣០ មេធាវី ម៉ុម ពិសី |
| ៩ មេធាវី រស់ មុនិន្ទៈ | ២០ មេធាវី យឹម ចារី | ៣១ មេធាវី ទ្រី សំរស់ |
| ១០ មេធាវី តៃ ចំណាន | ២១ មេធាវី ឌឹម ចៅសេង | ៣២ មេធាវី នួន ផានិត |
| ១១ មេធាវី ខូវ ចន្ថា | ២២ មេធាវី លី សុខឡាយ | ៣៣ មេធាវី យុត កែវសុវត្ថា |





## ពិធីផ្ទេរតំណែងសមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាថ្ងៃច័ន្ទ ១៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំការផ្ទេរដំណែងរវាងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៨ ជូនសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩ ក្រោមអធិបភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី១២នេះ។ សូមរំលឹកផងដែរថា កាលពីថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាវ៉េស៊ីដង់ភ្នំពេញ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំមហាសន្និបាតលើកទី២៣ របស់ខ្លួនដើម្បីជ្រើសតាំងប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ លោកមេធាវីមេធាវីសួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី១១ ត្រូវបានមហាសន្និបាតបានបោះឆ្នោតគាំទ្របន្តដំណែងសម្រាប់អាណត្តិទី២(២០១៨-២០២០)។



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃីម ចាន់ធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-លោកមេធាវី ហួត សុវណ្ណ | បុគ្គលិកស្ម័គ្រចិត្ត |
| ៧-កញ្ញា តាន់ ចរណី | បណ្ណារក្ស |
| ៨-លោក ថា ប៊ុនថៃ | បុគ្គលិកបច្ចេកទេស |
| ៩-លោក ខន សុខេង | បុគ្គលិកស្ម័គ្រចិត្ត |
| ១០-លោក ស្រេង សីហាប៊ុននុត | បុគ្គលិកហាត់ការ |
| ១១-លោក ជុំ ប៉ុនណារាយ | បុគ្គលិកហាត់ការ |
| ១២.លោក នួន រ៉ា | បុគ្គលិកហាត់ការ |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា